**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់
# និងបរិស្ថានខណ្ឌព្រែកព្នៅ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ស៊ុន យ៉េកឈុន**

**ក. មុំ មុយឡេង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា**



| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលរៀន | ២០២០ |
| ជំនាន់ទី២៤ | | ឆ្នាំសរសេរសារណា | ២០២៤ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានខណ្ឌព្រែកព្នៅ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ស៊ុន យ៉េកឈុន**

**ក. ម៉ុំ មុយឡេង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ក្រុមនាងខ្ញុំឈ្មោះ **ស៊ីន យ៉េកឈុន** និងនាងខ្ញុំឈ្មោះ **មុំ មុយឡេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២៤។ នាងខ្ញុំសូមលំឱនកាយនូវការគោរព និងកតញ្ញូតាធម៌ចំពោះទៅដល់អ្នកមានគុណៈ

**លោកឪពុក ហួ ចាន់ធី** **លោកឪពុក សំ សុធី**

**អ្នកម្ដាយ ជា ចាន់ដានី** **អ្នកម្ដាយ ឡុក ពៅ**

ដែលបានផ្ដល់កំណើតដល់រូបកូនៗ និងខិតខំបីបាច់ថែរក្សាកូនតាំងពីនៅក្នុងគភ៌រហូតដល់ធំពេញវ័យ ប្រកបទៅដោយព្រហ្មវិហារធម៌ មេត្តា ករុណា មុទិតា ឧបេក្ខា ដែលផ្ដល់នូវក្ដីស្រឡាញ់ផ្ដល់នូវភាពកក់ក្ដៅ ការយល់ចិត្ត និងតែងតែអធ្យាស្រ័យដល់កូនរាល់កំហុសខុសឆ្គងដោយអចេតនា ព្រមទាំងពុះពាររាល់គ្រប់ឧបសគ្គក្នុងការទំនុកបម្រុង កូនៗគ្រប់សព្វបែបយ៉ាងទាំងផ្នែកសម្ភារៈ និងស្មារតី។ ជាពិសេស តែងតែជម្រុញក្នុងការលើកទឹកចិត្តដល់រូបកូនៗក្នុងការសិក្សារៀនសូត្រ និងតែងតែបង្រៀនពីការរស់នៅក្នុងសង្គមប្រកបដោយភាពថ្លៃថ្នូរដើម្បីឱ្យកូនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គមជាតិ។

**ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំសាកលវិទ្យាល័យទាំងមូល ឆ្ពោះទៅរកភាពល្អប្រសើរមានគុណភាពសម្រាប់និស្សិតបន្តការសិក្សារបស់ខ្លួនដើម្បីខ្លួនឯង គ្រួសារ សង្គមជាតិទាំងមូល។

ជាពិសេសសូមថ្លែងអំណរគុណចំពោះ**លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា** បង្រៀនផ្នែកនីតិនគរូបនីយកម្ម និងសំណង់ ដែលបានធ្វើការចំណាយពេលវេលាយ៉ាងមានតម្លៃទាំងកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី ដែលជួយបំភ្លឺណែនាំអំពីដំណាក់កាលជាច្រើនទាំងផ្នែក អត្ថន័យ ខ្លឹមសារ គំនិតយោបល់សម្រាប់រៀបរៀងប្រធានបទនេះឱ្យកាន់តែមានខ្លឹមសារទាំងពីរចាប់ផ្ដើមរហូតដល់បញ្ចប់ជាស្ថាពរ។

ជាចុងបញ្ចប់នេះ នាងខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមប្រសិទ្ធពរជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការចូលកើតមានចំពោះអ្នកមានគុណ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ ព្រមទាំងក្រុមគ្រួសារទាំងអស់ ឱ្យជួបប្រទះនូវពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមក្នុងនាមខ្ញុំ ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ នាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយនាងខ្ញុំទាំងពីរនាក់ បានមូលមតិគ្នាពិភាក្សាចងក្រងនូវប្រធានបទថ្មីមួយដែលនាងខ្ញុំបានរៀបរៀងនៅក្នុងមុខវិជ្ជានគរូបនីយកម្ម និងសំណង់ដែលបានជ្រើសរើសលើប្រធានបទស្តីអំពីការ"**ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានខណ្ឌព្រែកព្នៅ**"។ ដើម្បីអាចលេចចេញនូវស្នាដៃមួយនេះឡើងបាននាងខ្ញុំមានការខិតខំរួបរួមកម្លាំងទាំងផ្នែកផ្លូវកាយ និងបញ្ញាស្មារតី ខិតខំយ៉ាងណាធ្វើការស្រាវជ្រាវនេះឱ្យបានល្អ ដែលបានលើកយកប្រភពឯកសារផ្សេងៗពាក់ព័ន្ធនឹងប្រធានបទដូចជា លិខិតបទដ្ឋានគតិយុត្ត បណ្តាញគេហទំព័រតាមអ៊ីនធឺណេតដែលមានប្រភពច្បាស់លាស់ ការចុះទៅសិក្សាស្រាវជ្រាវដោយផ្ទាល់ ដោយបានទាក់ទងជាមួយរដ្ឋបាលនៅក្នុងសាលាខណ្ឌ ដើម្បីធ្វើការសិក្សាចងក្រងឡើងជាអត្ថបទបញ្ចប់សារណានេះមកបាន។

ចំពោះគោលបំណងក្នុងការស្រាវជ្រាវប្រធានបទការរៀបចំផ្នែកសណ្តាប់ធ្នាប់ និងបរិស្ថានខណ្ឌព្រែកព្នៅឡើងនេះ គឺដើម្បីបង្កើននូវការយល់ដឹងដែលទាក់ទងនឹងកិច្ចការរបស់រដ្ឋបាលខណ្ឌព្រែកព្នៅ ចំពោះការឆ្លើយតបក្នុងការបំពេញតម្រូវការនានានៅក្នុងខណ្ឌព្រែកព្នៅរបស់ប្រជាពលរដ្ឋដើម្បីសម្រេចបាននូវអភិបាលកិច្ចល្អ ស្របតាមលទ្ធិប្រជាធិបតេយ្យដើម្បីផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋជាពិសេសនោះ នៅពេលប្រជាពលរដ្ឋនិងអាជ្ញាធរពាក់ព័ន្ធនានា បានចូលរួមក្នុងការរៀបចំសណ្តាប់ធ្នាប់បានល្អនោះ និងនាំមកនូវសោភ័ណភាពដែលស្រស់ស្អាត និងបានចូលរួមនៅក្នុងការបង្កើននូវលទ្ធភាពនៃការកៀងគរប្រភពធនធានទៅមូលដ្ឋាន សម្រាប់អភិវឌ្ឍបន្ថែមទៀត ដូចជាការកៀរគរធនធានផ្នែកវិស័យឯកជននានា មកចូលរួមជាមួយអាជ្ញាធរនៅមូលដ្ឋាននឹងប្រជាពលរដ្ឋក្នុងការវិនិយោគលើការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

ជាទីបញ្ចប់នាងខ្ញុំទាំងពីរនាក់ ដែលបានស្រាវជ្រាវសារណានេះ សូមអភ័យទោសទុកជាមុនផងដែលនូវចំណុចខ្វះខាតពាក់ព័ន្ធនឹងអក្ខរាវិរុទ្ធិ ពាក្យពេចន៍ និងរងចាំទទួលការ រិះគន់ កែប្រែនូវកំហុសអចេតនាណាមួយដែលមាននៅក្នុងអត្ថបទពីសំណាក់អ្នកអាន អ្នកសិក្សាទាំងអស់ ដែលជាកត្តាជម្រុញភាពវិជ្ជមានមួយដើម្បីការស្រាវជ្រាវនេះឱ្យកាន់តែមានភាពប្រសើរឡើងជាងមុនផងដែរ។

## មាតិកា

ទំព័រទី

**សេចក្តីផ្តើម** ……………………………………………………………………………………១

**ជំពូកទី១**

**សញ្ញាណនៃការរៀបចំខណ្ឌព្រែកព្នៅ**

**១.១. ទិដ្ឋភាពទូទៅ** ……………………………………………………………………… ៤

១.១.១. ទីតាំងភូមិសាស្រ្ត ……………………………………………………………………៧

១.១.២. ចំនួនប្រជាជន …………………………………………………………………………… ៨

១.១.៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខណ្ឌព្រែកព្នៅ ……………………………………… ៩

១.១.៣.១. ក្រុមប្រឹក្សាខណ្ឌ …………………………………………………………… ១១

១.១.៣.២. គណៈអភិបាលខណ្ឌ ………………………………………………………………១១

១.១.៤. មូលហេតុនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់……………………………………………១៣

១.១.៤.១. កំណើនប្រជាជន …………………………………………………………… ១៣

១.១.៤.២. ភាពក្រីក្រ ……………………………………………………………………… ១៣

១.១.៤.៣. កម្រិតជីវភាពនៃការរស់នៅ ………………………………………………………១៤

១.១.៤.៤. គមនាគមន៍ ……………………………………………………………………១៤

១.៤.៤.៥. ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ………………………………………………១៥

**១.២. បច្ចុប្បន្នភាពនិងទិសដៅអនាគតនៃការរៀបចំខណ្ឌព្រែកព្នៅ** ……………………១៨

១.២.១. បច្ចុប្បន្នភាពនៃការរៀបចំ ……………………………………………………………………១៨

១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ……………………………………………………១៨

១.២.១.២. ការអភិវឌ្ឍគមនាគមន៍ ……………………………………………………………១៨

១.២.១.៣. ការអភិវឌ្ឍនៃសំណង់អគារ ........ ២១
១.២.១.៤. ការរៀបចំលំនៅឋាន ........ ២៣
១.២.១.៥. ការរៀបចំប្រព័ន្ធលូសាធារណៈ ........ ២៤
១.២.២. ទិសដៅរៀបចំពេលអនាគតនៅខណ្ឌព្រែកព្នៅ ........ ២៥
១.២.២.១. ការរៀបចំប្រព័ន្ធទឹកស្អាត ........ ២៥
១.២.២.២. ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ ........ ២៦
១.២.២.៣. ការអភិវឌ្ឍលើវិស័យពាណិជ្ជកម្ម ........ ២៨
១.២.២.៤. ការអភិវឌ្ឍលើវិស័យឧស្សាហកម្ម........ ២៩
១.២.២.៥. ការអភិវឌ្ឍវិស័យដឹកជញ្ជូន ........ ៣២

## ជំពូកទី២

## ការរៀបចំបរិស្ថាននៅខណ្ឌព្រែកព្នៅ

**២.១. ការបំពុលបរិស្ថាននៅខណ្ឌព្រែកព្នៅ** ........ ៣៥
២.១.១. ការបំពុលទឹក ........ ៣៦
២.១.១.១. មូលហេតុនៃការបំពុលទឹក ........ ៣៦
២.១.១.២. ផលវិបាកនៃការបំពុលទឹក........ ៣៨
២.១.២. ការបំពុលដី ........ ៣៨
២.១.២.១. មូលហេតុនៃការបំពុលដី ........ ៣៨
២.១.២.២. ផលវិបាកនៃការបំពុលដី ........ ៤០
២.១.៣. ការបំពុលខ្យល់........ ៤០
២.១.៣.១. មូលហេតុនៃការបំពុលខ្យល់ ........ ៤០
២.១.៣.២. ផលវិបាកនៃការបំពុលខ្យល់ ........ ៤១

២.១.៤. ការបំពុលសំណល់រឹង រាវ ........................................................................ ៤២

២.១.៤.១. មូលហេតុនៃការបំពុលសំណល់រឹង រាវ ........................................................ ៤២

២.១.៤.២. ផលវិបាកនៃសំណល់រឹង រាវ ........................................................................ ៤៦

២.១.៥. ការបំពុលសំឡេង ........................................................................ ៤៦

២.១.៥.១. មូលហេតុនៃការបំពុលសំឡេង ........................................................................ ៤៦

២.១.៥.២. ផលវិបាកនៃការបំពុលសំឡេង ........................................................................ ៤៦

**២.២. ដំណោះស្រាយនៃការបំពុលបរិស្ថាន ........................................................................ ៤៧**

២.២.១. ដំណោះស្រាយការបំពុលទឹក ........................................................................ ៤៧

២.២.២. ដំណោះស្រាយនៃការបំពុលដី ........................................................................ ៤៩

២.២.៣. ដំណោះស្រាយនៃការបំពុលខ្យល់ ........................................................................ ៥០

២.២.៤. ការដោះស្រាយនៃសំណល់រឹង រាវ ........................................................................ ៥១

២.២.៥. ដំណោះស្រាយការបំពុលសំឡេង ........................................................................ ៥២

**សេចក្តីសន្និដ្ឋាន ........................................................................ ៥៣**

**អនុសាសន៍ ........................................................................ ៥៤**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហាការស្រាវជ្រាវ

ប្រទេសនៅលើពិភពលោកទាំងអស់ គឺសុទ្ធតែមានអ្នកដឹកនាំដែលមានចក្ខុវិស័យយកចិត្តទុកដាក់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ប្រទេសជាតិ ទៅលើការកសាងខាងនគរូបនីយកម្ម ដែលមានការរៀបចំការបែងចែកទៅជាតំបន់ភូមិ ស្រុក រាជធានី ជាដើមតាំងពីបុរាណកាលមកម្ល៉េះ។ មិនខុសពីអ្នកដឹកនាំ នៅបណ្តាប្រទេសនានាលើសកលលោកបច្ចុប្បន្នទេ បើសិនជាយើងក្រឡេកមកមើលតថភាពពីសម័យបុរាណរបស់ខ្មែរយើងវិញចេះរៀបចំការគ្រប់គ្រងបែងចែករចនាសម្ព័ន្ធជារាជធានី ក្រុង ស្រុក ភូមិ ឃុំផងដែរ។ ជាពិសេស គឺមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើផ្នែករៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពយ៉ាងស្រស់ត្រកាលរហូតបន្តមកដល់សម័យបច្ចុប្បន្នទៀតផង។

ប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ មានការបែងចែកជា ២៥រាជធានី ខេត្ត និងមាន ២៧ ២០៩ក្រុង ស្រុក ខណ្ឌ ១ ៦៥២ ឃុំ សង្កាត់ និង១ ៤៥៧៧ ភូមិ ដោយយោងទៅតាមប្រភពឯកសារនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ (បើគិតត្រឹម ខែមករា ឆ្នាំ២០២៤)។ ហើយខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នីមួយៗនេះ មានការរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធថ្មីៗជាច្រើនដូចជាការបង្កើតស្ពាន ប្រព័ន្ធធារាសាស្ត្រ ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ពាក់ព័ន្ធនឹងការបង្កើតឱ្យមានខេត្ត ក្រុង មានការកើនឡើងនៅពេលបច្ចុប្បន្ន គេតែងតែចូលរួមយកចិត្តទុកដាក់ទៅលើការថែរក្សានូវសណ្តាប់ធ្នាប់ និងបរិស្ថានឱ្យល្អប្រសើរទៅផងដែរ។ ដូច្នេះធ្វើឱ្យអភិបាលខណ្ឌ និងមន្ត្រីរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការរៀបចំកែលម្អសណ្តាប់ធ្នាប់ រក្សាសុខសុវត្ថិភាព ពិសេស គ្រប់គ្រងលើបរិស្ថានឱ្យកាន់តែល្អប្រសើរ ដើម្បីស្របទៅតាមស្តង់ដារជាភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព។

យ៉ាងណាមិញ ក្នុងដំណើរការរៀបចំនៃការកែលម្អដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់ និងបរិស្ថានមានផលវិបាកច្រើនណាស់ដែរ។ យើងដឹងហើយថាទន្ទឹមនឹងការអភិវឌ្ឍវាក៏បូកបញ្ចូលជាមួយការកើតមានឡើងនូវបញ្ហាប្រឈមនានាដូចជា ប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង និងអចលនទ្រព្យដីធ្លី ការកកស្ទះបញ្ហាចរាចរណ៍នៅអំឡុងពេលសាងសង់ ជាពិសេស គឺធនធានធម្មជាតិរបស់យើងផងដែរ។ ដូច្នេះ វាពិតជាមានការបង្កផលវិបាកខ្លះផងដែរនៅក្នុងការខិតខំរកមធ្យោបាយស្រាយបញ្ហាប្រឈមផ្សេងៗដែលកើតមានឡើង។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ខណ្ឌព្រែកព្នៅ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញដែលត្រូវបានកំណត់ជាតំបន់កំពុងអភិវឌ្ឍន៍ នៅក្នុងចំណោមតំបន់ជាយក្រុងផ្សេងៗទៀតពីខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ ខណ្ឌសែនសុខ ព្រមទាំងខណ្ឌផ្សេងៗទៀត។ ខណ្ឌព្រែកព្នៅនេះជាមជ្ឈមណ្ឌលនៃទីតាំងវប្បធម៌ នយោបាយ សេដ្ឋកិច្ច សន្តិសុខ ដែលមានការអភិវឌ្ឍប្រកបដោយសក្តានុពលប្រកួតប្រជែងនឹងនិរន្តរភាពលើគ្រប់វិស័យ។ ដូច្នេះ ខណ្ឌព្រែកព្នៅ គឺចាំបាច់ត្រូវតែយកចិត្តទុកដាក់លើការអភិវឌ្ឍផ្នែកគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់ ព្រមទាំងបរិស្ថានស្អាតដើម្បីឱ្យមានកំណើននៃអ្នកវិនិយោគិនទាំងក្នុងស្រុក និងក្រៅប្រទេសមកបណ្តាក់ទុនវិនិយោគ។ ហេតុនេះហើយ ទើបមានសំណួរជាច្រើនបានចោទសួរឡើងមកថា តើមន្ត្រីមានសមត្ថកិច្ចនៅក្នុងខណ្ឌព្រែកព្នៅមានការរៀបចំផ្នែកសណ្តាប់ធ្នាប់ និងបញ្ហាបរិស្ថានបែបណាខ្លះដើម្បីធ្វើឱ្យមានការអភិវឌ្ឍក្នុងគោលដៅទាក់ទាញវិស័យសេដ្ឋកិច្ច? តើការរៀបចំនូវគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព សន្តិសុខល្អ បរិស្ថានស្អាតបែបណា? តើនៅពេលអនាគតខណ្ឌព្រែកព្នៅនេះមានការអភិវឌ្ឍអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទមួយនេះឡើងមក គឺមានគោលបំណងចង់បង្ហាញឱ្យឃើញពីទិដ្ឋភាពទូទៅនៃរបៀបរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាននៅខណ្ឌព្រែកព្នៅ ពិសេសសកម្មភាពនៃការចូលរួមដោះស្រាយជាមួយនិងរដ្ឋាភិបាលដែលកើតមាននៅបញ្ហាមួយចំនួននៅថ្នាក់រដ្ឋបាលក្រោមជាតិ។ ម្យ៉ាងទៀតដើម្បីចែករំលែកនូវចំណេះដឹងពីផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រផ្សេងៗទៅកាន់និស្សិតជំនាន់ក្រោយៗសម្រាប់សិក្សាស្វែងយល់សិក្សាបន្ថែមដើម្បីជាចំណេះដឹង និងផ្តល់ជាឯកសារសំខាន់ផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវប្រធានបទ ដែលនិយាយពីខណ្ឌព្រែកព្នៅទាំងមូលវាមានបញ្ហាដែលត្រូវចោទឡើងជាច្រើនធ្វើឱ្យមានកម្រិតភាពធំទូលាយណាស់។ ដូច្នេះនាងខ្ញុំសូមធ្វើការពិពណ៌នាអំពីការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាននៅក្នុងខណ្ឌព្រែកព្នៅតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះក្រុមនាងខ្ញុំក៏ដូចជាចំពោះសាធារណជនគ្រប់ៗរូប ជាពិសេសសិស្សនិស្សិត ដើម្បីធ្វើជាឯកសារជំនួយស្មារតី និងសិក្សាបន្ថែមដើម្បីឱ្យកាន់តែដឹងច្បាស់អំពីការរៀបចំផ្នែកនគរូបនីយកម្ម សណ្តាប់ធ្នាប់ និងបរិស្ថាន ជាពិសេសទៅលើ សុវត្ថិភាព

សន្តិសុខ និងការយល់ដឹងទៅលើមូលហេតុនៃដំណោះស្រាយធំៗ ដែលទាក់ទងនឹងការបំពុលបរិស្ថានទាំង ០៥ ផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីអាចលេចចេញជាស្នាដៃនៃការស្រាវជ្រាវមួយក្បាលនេះឡើងមក ដែលទាក់ទងទៅនឹងប្រធានបទ "ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានខណ្ឌព្រែកព្នៅ" មួយនេះនាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើឯកសារដែលពាក់ព័ន្ធបានមកពីគេហទំព័រក្នុងផ្លូវការ មានប្រភពច្បាស់លាស់ផ្សេងៗ ច្បាប់ អនុក្រឹត្យ សេចក្តីសម្រេចនានា លិខិតបទដ្ឋានគតិយុត្តដែលមានចែងពាក់ព័ន្ធឯកសារតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋបាលខណ្ឌ និងចុះទៅសាកសួរព័ត៌មាននឹងសុំឯកសារដោយផ្ទាល់ពីសាលាខណ្ឌព្រែកព្នៅ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះសារណាមួយនេះនាងខ្ញុំបានធ្វើការបែងចែកជា០២ជំពូករួមមាន៖

- **ជំពូកទី១ "ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌព្រែកព្នៅ"** ដែលជំពូកនេះនាងខ្ញុំផ្តោតសំខាន់ទៅលើបីចំណុចសំខាន់អំពីស្ថានភាពទូទៅ រចនាសម្ព័ន្ធគ្រប់គ្រងនៅខណ្ឌព្រែកព្នៅ និងមូលហេតុនាំឱ្យមានការរៀបចំខណ្ឌ។
- **ជំពូកទី២ "ការរៀបចំបរិស្ថាននៅខណ្ឌព្រែកព្នៅ"** នៅក្នុងជំពូកនេះផ្តោតសំខាន់ទៅលើការរៀបចំបរិស្ថាននៅក្នុងខណ្ឌព្រែកព្នៅលើបញ្ហាការបំពុល និងដំណោះស្រាយពីការបំពុលទាំង០៥ ដែលមានការបំពុលទឹក បំពុលខ្យល់ បំពុលសំណល់រឹង រាវ បំពុលដី និងបំពុលដោយសំឡេង។

# ជំពូកទី១
# ការរៀបចំសណ្ដាប់ធ្នាប់
# ក្នុងខណ្ឌព្រែកព្នៅ

# ជំពូកទី១
# សញ្ញាណនៃការរៀបចំខណ្ឌព្រែកព្នៅ

ការរៀបចំនូវសណ្តាប់ធ្នាប់ និងបរិស្ថាននៅខណ្ឌព្រែកព្នៅ ពេលបច្ចុប្បន្នឃើញថាសាលាខណ្ឌព្រែកព្នៅ គឺមានការខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងលើការរៀបចំការអភិវឌ្ឍនានាក្នុងមូលដ្ឋានដែនដីរដ្ឋបាលរបស់ខ្លួន ដោយបង្កើតឱ្យមានសណ្តាប់ធ្នាប់ សោភ័ណភាព សន្តិសុខ និងបរិស្ថានល្អ ជូនដល់ប្រជាពលរដ្ឋ ដើម្បីចូលរួម គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព។ ម្យ៉ាងទៀតបានចូលរួមកសាងផងដែរ នៅក្នុងការរៀបចំផ្នែក ហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាបានអភិវឌ្ឍន៍វិស័យគមនាគមន៍ កសាងជួសជុលផ្លូវថ្នល់ ផ្លូវបេតុង ក្រាលគ្រួស ក្រហម និងរៀបចំដាក់ប្រព័ន្ធលូរំដោះទឹកភ្លៀងនៅរដូវវស្សាជាច្រើន ដើម្បីបញ្ចៀសការលេចលង់តាមសាលារៀន ផ្សារលក់ដូរ លំនៅឋានប្រជាពលរដ្ឋ និងការគ្រប់គ្រងសំណល់ដោយសារទឹកភ្លៀងផងដែរ ។

តែទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការរៀបចំសណ្តាប់ធ្នាប់នៅតែអាចមានបញ្ហាដែលកើតមានឡើង ពីកត្តាមួយចំនួនដែលមានដូចជា កង្វះការចូលរួមសហការរបស់ប្រជាពលរដ្ឋក្នុងដែនដីរដ្ឋបាលរបស់ខ្លួន ដែល អាចមកពីការយល់ដឹងរបស់ប្រជាពលរដ្ឋ នៅមានកម្រិតក្នុងការចូលរួមសម្អាតបរិស្ថាន ទៅលើការគ្រប់គ្រង កាកសំណល់នានា។ ម្យ៉ាងទៀតកត្តាពីធម្មជាតិមានទឹកជំនន់ ខ្យល់កន្ត្រាក់ ក៏បណ្តាលធ្វើឱ្យប៉ះពាល់ទៅដល់ ហេដ្ឋារចនាសម្ព័ន្ធដែរ។

## ១.១. ទិដ្ឋភាពទូទៅក្នុងខណ្ឌព្រែកព្នៅ

ខណ្ឌព្រែកព្នៅ គឺជាខណ្ឌមួយដែលស្ថិតនៅក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ដែលមាន សមាហរណកម្មឆ្ពោះទៅកាន់ការអភិវឌ្ឍជឿនលឿនឆាប់រហ័ស រួមមានការរៀបចំនូវបណ្តាញហេដ្ឋារចនាសម្ព័ន្ធ ជាច្រើនដែលត្រូវបានវិនិយោគដោយផ្ទាល់ពីរាជរដ្ឋាភិបាល និងវិស័យឯកជនដែលបានបង្កើនការលើកកម្ពស់ សក្តានុពលក្នុងតំបន់ ដែលផ្តល់អំណោយផលទៅដល់ផ្នែកវិនិយោគ មិនតែប៉ុណ្ណោះខណ្ឌព្រែកព្នៅ គឺមានតំបន់ ទាក់ទាញភ្ញៀវទេសចរជាច្រើនផងដែលមាន វត្តភ្នំរាប ឬហៅថាវត្តសុវណ្ណធម្មរាជ រមណីយដ្ឋានវប្បធម៌ភ្នំប្រសិទ្ធិ ភ្នំព្រះរាជទ្រព្យ និងមានរមណីយដ្ឋានផ្សេងៗទៀតផងដែរ។

❖ **ទាក់ទងនៃការបង្កើតឱ្យមានខណ្ឌ នៅព្រះរាជាណាចក្រកម្ពុជា**

ក្រោយពីមានការបញ្ចប់សង្គ្រាមស៊ីវិលជាងបីទសវត្សរ៍នៅប្រទេសកម្ពុជាមក ប្រទេសជាតិមានការបំផ្លិច បំផ្លាញយ៉ាងធ្ងន់នូវហេដ្ឋារចនាសម្ព័ន្ធរួមមាន គមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ រោងចក្រ ឧស្សាហកម្មនានា សង្គម សេដ្ឋកិច្ច ប្រព័ន្ធនយោបាយ រដ្ឋបាល ប្រពៃណីទំនៀមទម្លាប់។ល។ រដ្ឋាភិបាលនៃរដ្ឋកម្ពុជា បានធ្វើការ

បង្រួបបង្រួមជាតិ ដើម្បីធ្វើការបញ្ចប់នូវសង្គ្រាមស៊ីវិល ដោយបានសម្រេចចិត្តធ្វើការចរចាសម្របសម្រួលជាមួយភាគីជម្លោះចំនួន ០៤បានចុះហត្ថលេខាដោយមានវត្តមានសាក្សីមកពី ១៨ប្រទេស និងរួមទាំងអគ្គលេខាធិការអង្គការសហប្រជាជាតិ(UN) ផងដែរ ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជារហូតសម្រេចបាន "កិច្ចព្រមព្រៀងសន្តិសុខទីក្រុងប៉ារីស" ស្តីពីដំណោះស្រាយនៅកម្ពុជានៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។[១] តាមកិច្ចព្រមព្រៀងសន្តិសុខទីក្រុងប៉ារីសបានធ្វើឱ្យកម្ពុជា កសាងបាននូវសង្គមប្រជាធិបតេយ្យទៅតាមរយៈការបោះឆ្នោត ហើយបានបង្កើតជារដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣សព្វថ្ងៃ។ បន្ថែមទៀត រដ្ឋធម្មនុញ្ញនេះបានបែងចែកដែនដីរដ្ឋបាលក្នុងព្រះរាជាណាចក្រកម្ពុជា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។[២]

ប៉ុន្តែនៅក្នុងឆ្នាំ១៩៩៣ ភាគីហត្ថលេខីមួយនៃកិច្ចព្រមព្រៀងសន្តិសុខទីក្រុងប៉ារីស គឺភាគីខាងកម្ពុជាប្រជាធិបតេយ្យមិនបានអនុវត្តតាមកិច្ចព្រមព្រៀង និងមិនបានចូលរួមធ្វើការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ទៅថែមបន្តធ្វើសកម្មភាពប្រដាប់អាវុធប្រឆាំងរដ្ឋាភិបាលស្របច្បាប់។ ដើម្បីធ្វើការបញ្ចប់នូវភ្លើងសង្គ្រាម ឈានទៅរកប្រទេសមានសុខសន្តិភាព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ បានដាក់ចេញនូវនយោបាយឈ្នះ ឈ្នះ និងបាននាំនូវជ័យជម្នះនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ចាប់ពីថ្ងៃនោះមកប្រទេសកម្ពុជាបានទទួលសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី និងគ្រប់គ្រងតាមបែបធម្មនុញ្ញឆ្នាំ១៩៩៣។[៣] ក្រោយមកបន្ទាប់ពីមានការបោះឆ្នោតជាតិជាលើកទី០២ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការកែទម្រង់នូវប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ-សង្កាត់នៅក្នុងឆ្នាំ២០០២ តាមរយៈការដាក់ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតនៅឃុំ សង្កាត់ នៅឆ្នាំ២០០១។ ក្រោយពីអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំសង្កាត់បានជោគជ័យរួច នៅក្នុងឆ្នាំ២០០៨ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវកំណែទម្រង់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលអនុម័តនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ ហើយរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍រដ្ឋបាលឯកភាព ដើម្បីបង្កើតនឹងជម្រុញឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។[៤] ម្យ៉ាងទៀត បានបែង

[១] គេហទំព័រ ក្រសួងមុខងារសាធារណៈ https://www.mcs.gov.kh/?p=54785 ដកស្រង់នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤

[២] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ចុះនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា១៤៥-១៤៦ថ្មី

[៣] គេហទំព័រ ក្រសួងព័ត៌មាន https://www.information.gov.kh/articles/30034 ដកស្រង់នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤

[៤] ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា២

ចែក ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា រាជធានីភ្នំពេញ ចែកជា ខណ្ឌ។ ខណ្ឌ ចែកជា សង្កាត់។ ខេត្ត ចែកជាក្រុង និងស្រុក។ ក្រុង ចែកជាសង្កាត់។ ស្រុក ចែកជាឃុំ និងជាសង្កាត់។[៥]

បើយោងតាមគេហទំព័រនៃសាលារាជធានីភ្នំពេញនាពេលបច្ចុប្បន្ន រាជធានីភ្នំពេញមានផ្ទៃដីសរុបចំនួន ៦៩២,៤៦ គីឡូម៉ែត្រក្រឡា។ ចំពោះប្រជាជននៅក្នុងរាជធានីភ្នំពេញវិញ គឺមានចំនួនសរុប ១ ៤៧០ ៣០៣នាក់ (ឆ្នាំ២០១៨) ដែលក្នុងនោះស្ត្រីមានចំនួនប្រមាណ ៩៦០ ០៨១ នាក់ដែលស្មើនឹង ៣០៥ ៧៦៧ គ្រួសារ។ ជាមួយគ្នានេះដែលរាជធានីភ្នំពេញមានដង់ស៊ីតេប្រជាជនរស់នៅមានចំនួនប្រមាណស្មើនឹង ២ ២១៣ នាក់នៅក្នុងមួយគីឡូម៉ែត្រការ៉េ។ រីឯផែនដីនៅក្នុងរាជធានីភ្នំពេញវិញ ត្រូវបានបែងចែកចេញជា ១៤ខណ្ឌ។

សព្វថ្ងៃខណ្ឌទាំង ១៤ នៅក្នុងរាជធានីភ្នំពេញមានដូចជា៖

- ខណ្ឌពោធិ៍សែនជ័យ
- ខណ្ឌជ្រោយចង្វារ
- ខណ្ឌដូនពេញ
- ខណ្ឌទួលគោក
- ខណ្ឌមានជ័យ
- ខណ្ឌឫស្សីកែវ
- ខណ្ឌសែនសុខ
- ខណ្ឌចំការមន
- ខណ្ឌច្បារអំពៅ
- ខណ្ឌ៧មករា
- ខណ្ឌដង្កោ
- ខណ្ឌព្រែកព្នៅ (ថ្មី)
- ខណ្ឌកំបូល (ថ្មី)[៦]

[៥] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា៤-៥

[៦] អនុក្រឹត្យ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ, លេខ ០៤ អនក្រ.បក, ចុះនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨

- ខណ្ឌបឹងកេងកង (ថ្មី)។[៧]

តាមការរៀបរាប់អំពីខណ្ឌខាងលើ ក្នុងរាជធានីភ្នំពេញទាំងមូលមានភាពធំទូលាយពេក ដូច្នេះនៅក្នុងអត្ថបទសារណានេះនាងខ្ញុំ ធ្វើការកម្រិតត្រឹមតែសណ្ដាប់ធ្នាប់ និងបរិស្ថានខណ្ឌព្រែកព្នៅតែប៉ុណ្ណោះ។ ខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញបានបង្កើតឡើងនៅថ្ងៃ២៥ ខែធ្នូ ឆ្នាំ២០១៣ ដែលត្រូវបានកាត់យកសង្កាត់ចំនួន ០៣ពីក្នុងខណ្ឌសែនសុខ រួមមានសង្កាត់ព្រែកព្នៅ សង្កាត់ពញាពន់ និងសង្កាត់សំរោង និងកាត់យកសង្កាត់ចំនួន ០២ទៀតពីក្នុងខណ្ឌពោធិ៍សែនជ័យដែលរួមមាន សង្កាត់គោករកា និងសង្កាត់ពន្សាំង។[៨] នៅក្នុងខណ្ឌព្រែកព្នៅ មានសង្កាត់ចំនួន ០៥មានសង្កាត់ព្រែកព្នៅ សង្កាត់ពញាពន់ សង្កាត់សំរោង សង្កាត់គោករកា និងសង្កាត់ពន្សាំង ដែលមានទីតាំងរបស់សាលាខណ្ឌនៅសង្កាត់គោករកាតែម្ដង។[៩]

### ១.១.១. ទីតាំងភូមិសាស្ត្រ

បច្ចុប្បន្នខណ្ឌព្រែកព្នៅមានព្រំប្រទល់ផ្នែកខាងជើងជាប់នឹងឃុំព្រែកតាទែន ស្រុកពញាឮ និងខេត្តកណ្ដាល ខាងត្បូងជាប់ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌពោធិ៍សែនជ័យ ខាងលិចជាប់ឃុំ ទួលព្រិច ស្រុកអង្គស្នួល ខេត្តកណ្ដាលនឹងផ្នែកខាងកើតជាប់បឹងទន្លេសាប មានផ្ទៃដីប្រមាណ ១១ ៥៦០ ៩០ហិកតា ចែកជា ០៥សង្កាត់ និង៥៩ភូមិដូចតទៅៈ

- សង្កាត់គោករកា ស្ថិតតាមផ្លូវទំនប់កប់ស្រូវមានលេខកូដប្លង់គោល ១២១២០១ មានភូមិចំនួន១៨
- សង្កាត់ព្រែកព្នៅ ស្ថិតតាមដងផ្លូវជាតិលេខ៥ និងផ្លូវទំនប់កប់ស្រូវដែលមានលេខកូដប្លង់គោល ១២១២០២ មានភូមិចំនួន ០៥
- សង្កាត់ពញាពន់ ស្ថិតតាមដងផ្លូវលេខ១៥១ មានលេខកូដប្លង់គោល ១២១២០៣ និងមានភូមិចំនួន ០៨
- សង្កាត់ពន្សាំង ស្ថិតនៅផ្លូវលេខ៤២ ជាផ្លូវយុទ្ធសាស្ត្រមានលេខកូដប្លង់គោល ១២១២០៤ មានភូមិចំនួន ២៤

[៧] អនុក្រឹត្យ ស្ដីពីការបង្កើតខណ្ឌបឹងកេងកងនៃរាជធានីភ្នំពេញ, លេខ ០៣ អនក្រ.បក, ចុះនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨

[៨] អនុក្រឹត្យ ស្ដីពីការបង្កើតខណ្ឌព្រែកព្នៅនៃរាជធានីភ្នំពេញ និងការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ, លេខ ៥៧៨ អនក្រ.បក, ចុះនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣, មាត្រា១

[៩] អនុក្រឹត្យលេខ ៥៧៨ អនក្រ.បក, ចុះនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣, មាត្រា៥

- សង្កាត់សំរោងស្ថិតនៅផ្លូវជាតិលេខ៥ និងផ្លូវលេខ១៥១ ឆ្ពោះទៅភ្នំប្រសិទ្ធិមានលេខកូដប្លង់គោល ១២១២០៥ និងមានភូមិចំនួន ០៤។[១០]

### ១.១.២ ចំនួនប្រជាជន

នៅក្នុងខណ្ឌព្រែកព្នៅ បើតាមការសិក្សាវិភាគតាមបែបប្រជាសាស្ត្រដោយផ្អែកទៅលើលទ្ធផលនៃជំរឿនទូទៅនៃប្រជាសាស្ត្រកម្ពុជា ប្រជាជននៅឆ្នាំ២០០៨ មានចំនួន ៤៧ ៣១៣នាក់ និងនៅឆ្នាំ២០១៩ ចំនួន ១៩១ ៤៣៧នាក់ ហើយតាមការព្យាករណ៍នៅឆ្នាំ២០៣៥ ប្រជាជននឹងថយចុះមកត្រឹមចំនួនប្រមាណ ១៤៨ ១០៤ នាក់ បើផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។

ជាមួយគ្នានេះ ការបែងចែកនៃកម្លាំងផលធម្មតាទៅតាមវិស័យសេដ្ឋកិច្ចសម្រាប់ខណ្ឌព្រែកព្នៅ នៅឆ្នាំ ២០០៨ ប្រជាជនធ្វើការនៅក្នុងវិស័យកសិកម្មមានចំនួន ១១ ៨២៦នាក់ គឺស្មើនឹង៤៩,៤ភាគរយ វិស័យឧស្សាហកម្មមានចំនួន ៥ ៤៤០នាក់ស្មើនឹង២២,៧ភាគរយនឹងវិស័យសេវាកម្ម មានចំនួន ៦ ៦៨២ នាក់ស្មើនឹង ២៧,៩ភាគរយ ហើយរំពឹងថានៅឆ្នាំ២០៣៥ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងថយចុះមកត្រឹមចំនួន ១០ ៩៦០នាក់ស្មើនឹង២០ភាគរយ វិស័យឧស្សាហកម្មនឹងកើនឡើងដល់ចំនួន ២៥ ៧៥៥នាក់ដែលស្មើ៤៧ ភាគរយ និងវិស័យសេវាកម្មនឹងកើនឡើងរហូតដល់ចំនួន ១៨ ០៨៣នាក់ ស្មើនឹង៣៣ភាគរយ។[១១] បើគិតក្នុងឆ្នាំ២០២៣ នៅក្នុងខណ្ឌព្រែកព្នៅមានចំនួនគ្រួសារសរុប ១៤ ៣៨៦គ្រួសារ មនុស្សសរុប ៦២ ៦៩៤នាក់ ក្នុងនោះស្ត្រីមាន ៣៣ ១៧៥នាក់ អាយុ១៨ឆ្នាំឡើងមានចំនួន ៤០ ៥៧៨នាក់។[១២]

---

[១០] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី១

[១១] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី២

[១២] របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌព្រែកព្នៅ ប្រចាំឆ្នាំ២០២៣, លេខ ០០៩/២៤របក, ចុះនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤

## ១.១.៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខណ្ឌព្រែកព្នៅ




### ១.១.៣.១. ក្រុមប្រឹក្សាខណ្ឌ

ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រុមប្រឹក្សាជាបុគ្គលសាធារណៈ ដែលជាអ្នកការពារនឹងជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ ដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាមានអាណត្តិ ០៥ឆ្នាំ គិតចាប់ពីថ្ងៃបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងដល់ផុតពេលចប់អាណត្តិថ្ងៃបោះឆ្នោតបន្ទាប់។ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណាដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើការអង្កេតនោះរួចហើយត្រូវផ្តល់គោលការណ៍ណែនាំ និងអនុវត្តដល់គណៈអភិបាល។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ និងត្រូវមានគណនេយ្យភាពចំពោះដល់រាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា។[១៣]

[១៣] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា៣២-៣៥

❖ **តួនាទីក្រុមប្រឹក្សា**

- ក្រុមប្រឹក្សាត្រូវរៀបចំកម្មវិធីវិនិយោគ ០៣ (បី)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍រយៈពេល ០៥(ប្រាំ) ឆ្នាំរួមទាំងសមាសភាគនៃផែនការនេះដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទនៃក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។ ដោយមានការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រភេទក្រុមប្រឹក្សាផ្សេងទៀត នៅដែនសមត្ថកិច្ចរបស់ខ្លួន ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។
- ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ គឺដើម្បីជម្រុញការអភិវឌ្ឍបែបប្រជាធិបតេយ្យដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន ដូចជាការកាន់កាប់ ឬលើការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិធ្វើជារបស់ខ្លួនដោយខុសច្បាប់។
- ការដកយកថវិកា ឬទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ដូចជាការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដោយមិនមានភាពត្រឹមត្រូវ
- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះរាជរដ្ឋាភិបាល អំពីការប្រតិបត្តិស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា
- ក្រុមប្រឹក្សា ត្រូវតាមដាននឹងវាយតម្លៃជារៀងរាល់ឆ្នាំ លើការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍន៍ដែលស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀតក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា
- ជាពិសេសក្រុមប្រឹក្សា ត្រូវរៀបចំ អនុម័តនូវរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធទៅនឹងដីកា សេចក្តីសម្រេចនានាដែលបានដាក់ចេញ សកម្មភាពនានាដែលបានអនុវត្ត របាយការណ៍ហិរញ្ញវត្ថុ និងការវាយតម្លៃក្នុងការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា និងវិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវពិនិត្យ និងធ្វើការអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើ គឺមិនលើសពី (៤៥)ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំ និងមានចំណុច

ជាច្រើនទៀត ដែលមានចែងពីតួនាទីរបស់ក្រុមប្រឹក្សា ដែលស្ថិតក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[១៤]

**១.១.៣.២. គណៈអភិបាលខណ្ឌ**

គណៈអភិបាលខណ្ឌ គឺត្រូវបានគេតែងតាំងដោយអនុក្រឹត្យនៃសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[១៥] គណៈអភិបាលខណ្ឌ និងគណៈអភិបាលរងខណ្ឌមានអាណត្តិការងារ គឺមិនអាចលើសពី (០៤)ឆ្នាំ និងអាចត្រូវបានគេតែងតាំងបន្តបាន ០៤អាណត្តិទៀតសម្រាប់អាណត្តិទី០២ របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល។ គណៈអភិបាលខណ្ឌ ត្រូវបានជ្រើសចេញពីចំណោមនៃមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់នៅក្នុងក្រសួងមហាផ្ទៃដែលមានលក្ខណៈសម្បត្តិដូចជា៖

- មានឋានន្តរស័ក្តិចាប់ពីអនុមន្ត្រីឡើងទៅមានអាយុចាប់ពី ៣០ឆ្នាំឡើងទៅដល់ថ្ងៃដែលតែងតាំង
- មានបទពិសោធន៍ទៅលើការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួន ០៥ឆ្នាំ ឬមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតជាផ្លូវការនៃរយៈពេលតែងតាំង និងមិនធ្លាប់មានបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយឡើយ។[១៦]

ក្នុងរចនាសម្ព័ន្ធខណ្ឌព្រែកព្នៅ អភិបាលខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញដែលត្រូវគ្រប់គ្រងខណ្ឌមានចំនួន ០១រូប និងអភិបាលរងចំនួន ០៦រូបជាជំនួយការ។[១៧] តាមសកម្មភាពរបស់អភិបាល និងអភិបាលរងខណ្ឌ ត្រូវរួមគ្នាដឹកនាំគ្រប់គ្រងទៅលើកិច្ចការរដ្ឋបាលដែនដី ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម និងលើកកម្ពស់ការអភិវឌ្ឍដល់សេដ្ឋកិច្ច សង្គម វប្បធម៌ ដែលនៅក្នុងភូមិសាស្ត្រក្នុងខណ្ឌឱ្យស្របទៅតាមគោលនយោបាយ ច្បាប់លិខិតបទដ្ឋានជាធរមាន និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។[១៨]

[១៤] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា៣៥-៥០

[១៥] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា១៤២, កថាខណ្ឌទី២

[១៦] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា១៤៤

[១៧] សេចក្តីសម្រេច ស្តីពីការបែងចែកតួនាទីភារកិច្ច និងរបៀបរបបធ្វើការជូនគណៈអភិបាល នៃអភិបាលខណ្ឌព្រែកព្នៅ, លេខ ០៣៤ ស.សរ/រហ, ចុះនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ប្រការ១

[១៨] សេចក្តីសម្រេចលេខ ០៣៤ ស.សរ/រហ, ចុះនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២, ប្រការ៣

❖ **តួនាទី និងភារកិច្ចអភិបាលខណ្ឌ**

អភិបាល គឺមានតួនាទីជាតំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំសម្របសម្រួល តម្រង់ទិសមន្ទីរអង្គភាព ខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននានា និងទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។[១៩]

- គណៈអភិបាល ត្រូវរាយការណ៍ជូនទៅក្រុមប្រឹក្សា ពីការអនុវត្តសេចក្តីសម្រេច របស់ក្រុមប្រឹក្សា និង សកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា របស់ក្រុមប្រឹក្សា។
- គណៈអភិបាលត្រូវផ្តល់យោបល់ និងរាយការណ៍ជូនទៅក្រុមប្រឹក្សាពីការរៀបចំយុទ្ធសាស្ត្រ និង រៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយកមុខងារ ភារកិច្ច និង ធនធានដែលត្រូវផ្ទេរទៅក្រុមប្រឹក្សា។
- ក្នុងតួនាទីជាតំណាងឱ្យរាជរដ្ឋាភិបាល ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល គឺអភិបាល ចាំបាច់ត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានា។
- ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចស្នើរាជរដ្ឋាភិបាលចេញអនុក្រឹត្យ ដើម្បីកំណត់តួនាទី សិទ្ធិអំណាចរបស់អភិបាលក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួងស្ថាប័ននានាតាមការ ចាំបាច់។
- អភិបាល ត្រូវធ្វើជាអ្នកតំណាងឱ្យរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ នៅក្នុងការងារ សណ្តាប់ធ្នាប់សន្តិសុខ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សនៅក្នុងដែនសមត្ថកិច្ច របស់ខ្លួន។[២០]
- កម្មវិធីវិនិយោគ០៣ (បី)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍រយៈពេល០៥ (ប្រាំ)ឆ្នាំ របស់ ក្រុមប្រឹក្សា រួមទាំងសមាសភាគផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ ក្រុមប្រឹក្សា រួមគ្នាប្រភេទក្រុមប្រឹក្សាផ្សេងៗទៀតក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់ រាជរដ្ឋាភិបាល និងដៃគូរពាក់ព័ន្ធនានា។[២១]

---

[១៩] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា២៣

[២០] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា១៥២-១៥៥

[២១] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨, មាត្រា១៦៥

### ១.១.៤. មូលហេតុនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់

នៅក្នុងខណ្ឌព្រែកព្នៅ ជាតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចយ៉ាងខ្លាំងលើការប្រកបអាជីវកម្ម កន្លែងវិនិយោគ សម្បូរទៅដោយរោងចក្រ សហគ្រាស ជាច្រើនដែលអំណោយផលទៅដល់ការរស់នៅប្រជាពលរដ្ឋ។ ម្យ៉ាងទៀតនៅខណ្ឌព្រែកព្នៅបានប្រមូលផ្តុំទៅដោយសេវាសុខាភិបាល ការអប់រំសម្បូរបែប និងមានការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការរក្សាសន្តិសុខនៅក្នុងភូមិ-ឃុំ-សង្កាត់ ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថានផងដែរ។ ទន្ទឹមគ្នានឹងកំណើនប្រជាជន ចូលមករស់នៅខណ្ឌព្រែកព្នៅមានចំនួនច្រើនឡើងវាក៏នាំមកបញ្ហាជាច្រើនដែលបង្កឱ្យកើតមានផងដែលជាក់ស្តែងរួមមាន៖

#### ១.១.៤.១. កំណើនប្រជាជន

ពីមួយឆ្នាំទៅមួយឆ្នាំ កំណើនមនុស្សដែលឡើងចំណាកស្រុកពីទីជនបទ តំបន់ខេត្តដាច់ស្រយាលឡើងមកទីប្រជុំជនក្រុងភ្នំពេញកាន់តែច្រើនឡើងៗ។ ការចំណាកស្រុកប្រជាពលរដ្ឋឡើងមករស់នៅក្នុងទីក្រុង គឺមានបញ្ហាធំចម្បងមកពីស្ថានភាពនៃចំណូលទ្រទ្រង់ជីវភាពគ្រួសារ។ ប្រជាពលរដ្ឋ នៅតំបន់ទីជនបទ តំបន់ដែលដាច់ស្រយាល និងនៅតាមបណ្តាខេត្តនានា នាំគ្នាមករស់នៅទីប្រជុំជននៅក្នុងទីក្រុង ដើម្បីរកការងារចិញ្ចឹមជីវិតដែលរួមមានធ្វើការ ជាកម្មករនិយោជិត បុគ្គលិកតាមសហគ្រាស ភោជនីយដ្ឋាន រោងចក្រកាត់ដេរ រោងចក្រសិប្បកម្ម បើករបររកស៊ីអាជីវកម្ម សេវាកម្ម ឬរកជំនាញផ្សេងៗ ដើម្បីរកចំណូលជួយផ្គត់ផ្គង់ក្រុមគ្រួសារ។

ដូច្នេះការកើនឡើងនៃចំនួនប្រជាជននៅខណ្ឌព្រែកព្នៅ គឺបានធ្វើឱ្យរដ្ឋបាលខណ្ឌព្រែកព្នៅត្រូវតែមានការយកចិត្តទុកដាក់ក្នុងការរៀបចំនូវសណ្តាប់ធ្នាប់។ ពីព្រោះកាលណា មានកំណើនប្រជាជនកើននឹងនាំឱ្យមានកត្តាតម្រូវការរបស់ប្រជាជនកើតមានដូចជា អគ្គិសនី សួនសាធារណៈ កន្លែងកម្សាន្ត កំណើនសាលារៀន ផ្សារ និងមធ្យោបាយធ្វើដំណើរមានភាពងាយស្រួលជាពិសេស គឺការរៀបចំបរិស្ថានឱ្យបានស្អាតល្អ។

#### ១.១.៤.២. ភាពក្រីក្រ

ការកំណត់ពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់ តែជាទូទៅភាពក្រីក្រសំដៅលើតម្រូវការរបស់មនុស្សមិនបានបំពេញ។[២២] ជារួមនៅក្នុងប្រទេសភាគច្រើន គឺគេអាចកំណត់ពីភាពក្រីក្របានទៅតាមរយៈប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ដែលមិនអាចចំណាយគ្រប់គ្រាន់នៅក្នុងជីវភាពប្រចាំថ្ងៃខ្លួន។ ដូចជាការកង្វះខាតក្នុងការទិញសម្លៀកបំពាក់ លំនៅឋាន ចំណីអាហារ ការចាយវាយលើថាមពលអគ្គិសនីប្រើប្រាស់ប្រចាំថ្ងៃ អនាម័យ និងលើសុខុមាលភាពសង្គម។ នៅពេលភាពក្រីក្ររបស់ប្រជាជន មានការកើនឡើងនោះនឹង

[២២] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៩

បណ្តាលឱ្យមាននូវភាពអសន្តិសុខ និងអសុវត្ថិភាព ដែលអាចលេចចេញរូបភាពមានការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារមានការលួច ឆក់ ប្លន់ និងអាចមានការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មកើតឡើងនៅក្នុងដែនដីខណ្ឌផងដែរ។ ម្យ៉ាងទៀតមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយអាចមកពីប្រជាពលរដ្ឋក្រីក្រ គ្មានផ្ទះសម្បែងស្នាក់នៅ តាមទីវត្តអារាម សួនសាធារណៈចិញ្ចើមផ្លូវ ដែលបញ្ហាទាំងអស់នេះជាហេតុនាំឱ្យអាជ្ញាធរខណ្ឌ គឺត្រូវតែមានការយកចិត្តទុកដាក់ និងធ្វើដំណោះស្រាយឱ្យមានភាពល្អប្រសើរ។

**១.១.៤.៣. កម្រិតជីវភាពនៃការរស់នៅ**

ការរស់នៅទីជនបទ និងទីតំបន់ខេត្តដាច់ស្រយាលមួយចំនួននឹងតថភាពរស់នៅរបស់ប្រជាជនទីក្រុងមានលក្ខណៈខុសពីគ្នាជាច្រើន។ ដោយមូលហេតុនោះ គឺនៅទីក្រុងកម្រិតជីវភាព និងប្រាក់បៀវត្សនៅតំបន់ទីក្រុងខ្ពស់ដែលជាកត្តាទាក់ទាញមនុស្សឱ្យមករស់នៅទីក្រុង។[២៣] លើសពីនេះទីក្រុង បានប្រមូលផ្តុំទៅដោយកត្តាសង្គមស្របទៅតាមតម្រូវការកើនឡើងនៃចំនួនប្រជាជនដែលរួមមាន នយោបាយល្អ ការកសាងនៅសាលារៀនគ្រប់កម្រិតទាំងរដ្ឋ និងឯកជន សំណង់លំនៅឋាន មានជាច្រើនប្រភេទដូចជាខុនដូរ បុរី ផ្ទះវីឡា ផ្សារទំនើប សម្បូរអគារពាណិជ្ជកម្ម សហគ្រាស សិប្បកម្ម រោងចក្រ ក្លឹបកម្សាន្ត សួនសាធារណៈដែលអាចបម្រើដល់អារម្មណ៍ប្រជាពលរដ្ឋ។ រីឯ មធ្យោបាយគមនាគមន៍កាន់មានភាពងាយស្រួលធ្វើដំណើរ ទាំងផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ជាពិសេសនោះតែងតែមានការយកចិត្តទុកដាក់ទៅលើ ការរៀបចំសណ្តាប់ធ្នាប់ ដែលមានសន្តិសុខ ភាពស្ងប់ស្ងាត់ និងបរិស្ថានស្អាត។ ការលើកឡើងទាំងនេះបានជះឥទ្ធិពលដល់ទីក្រុង ឱ្យកាន់តែមាននូវ ស្តង់ដារនៃការរស់នៅកាន់មានប្រណីតភាពមានផាសុកភាព។ ដូច្នេះហើយកម្រិតជីវភាពនៅក្នុងការរស់នៅគឺវាពិតជាមានសារៈសំខាន់ណាស់ដែលអភិបាលខណ្ឌត្រូវធ្វើការរៀបចំ។

**១.១.៤.៤. គមនាគមន៍**

គមនាគមន៍ គឺជាផ្នែកមួយដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍទីក្រុងផងដែរ។ ពីព្រោះថា ផ្លូវថ្នល់ប្រៀបដូចជាសរសៃឈាមនៃសេដ្ឋកិច្ច។ ការពង្រីកផ្លូវថ្នល់នេះមានសារៈសំខាន់ណាស់ ដើម្បីបង្កើនគុណផលសេដ្ឋកិច្ច ព្រោះថាបើហេដ្ឋារចនាសម្ព័ន្ធល្អ វាមិនបង្កឧបសគ្គដល់ការវិនិយោគ ការធ្វើដំណើរ និងការដឹកជញ្ជូនជាដើម។[២៤] ម្យ៉ាងទៀត បើកាលណាមានការរីកចម្រើនខាងគមនាគមន៍មានការអភិវឌ្ឍមានផ្លូវថ្នល់ខ្វាត់ខ្វែងនោះប្រជាជនអាចធ្វើដំណើរលែងសូវមានការកកស្ទះចរាចរណ៍នៅក្នុងការធ្វើដំណើរអាចចេញទៅបំពេញការងារទៅសាលារៀនបានលឿន ការដឹកជញ្ជូនរិញឆាប់រហ័សផងដែរ។ ហើយអ្វីដែលសំខាន់ទៀត វាបានជួយលើកនូវ

[២៣] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៩

[២៤] គេហទំព័រ https://construction-property.com/km ដកស្រង់នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០

មុខមាត់ប្រទេសជាតិ ដែលអាចឱ្យមានការផ្លាស់ប្តូរពីប្រទេសកំពុងអភិវឌ្ឍន៍ ឈានទៅរកជាប្រទេសអភិវឌ្ឍន៍ជឿនលឿនថែមទៀតផង។

បើនិយាយពីការរៀបចំគមនាគមន៍ឱ្យមានសណ្តាប់ធ្នាប់ល្អ រដ្ឋបាលនៅក្នុងខណ្ឌព្រែកព្នៅតែងតែធ្វើការជូនដំណឹងផងដែលទៅដល់បងប្អូនប្រជាពលរដ្ឋ និងអាជីវករ លក់ដូរ ទុកដាក់របស់របរ សាងសង់សំយ៉ាបមកលើផ្លូវសាធារណៈ ដែលរំលោភទៅលើចំណីផ្លូវសាធារណៈដែលវាបានធ្វើឱ្យបាត់បង់នូវសោភ័ណភាព និងរបៀបរៀបរយសាធារណៈ រដ្ឋបាលខណ្ឌព្រែកព្នៅបានធ្វើការណែនាំដូចជា៖

- រុះរើសំយ៉ាបផ្ទះ ឬដំបូលផ្ទះដែលសាងសង់មកលើដងផ្លូវ និងចិញ្ចើមផ្លូវ
- ធ្វើការកាប់ឆ្ការព្រៃ ជំរះស្មៅតាមរបង និងចិញ្ចើមផ្លូវ
- បញ្ឈប់ការដាក់តាំង ឬជួលទីតាំងចិញ្ចើមផ្លូវលក់ទំនិញ ម្ហូបអាហារ បន្លែ សាច់ សម្ភារៈ ឬវត្ថុផ្សេងៗនៅលើដងផ្លូវ និងចិញ្ចើមផ្លូវ
- បញ្ឈប់ការចាក់ទឹកមកលើដងផ្លូវ និងចោលកាកសំណល់គ្រប់ប្រភេទ រួមទាំងសំរាមដាក់តាមដងផ្លូវ ចិញ្ចើមផ្លូវដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អនាម័យ បរិស្ថាន និងផ្លូវថ្មើរជើង សម្រាប់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ
- បញ្ឈប់ការចតយានយន្តគ្រប់ប្រភេទ (ទាំងយប់ទាំងថ្ងៃ) ដែលធ្វើឱ្យកកស្ទះចរាចរណ៍ និងបង្កឱ្យកើតមានគ្រោះថ្នាក់ចរាចរណ៍។[២៥]

### ១.៤.៤.៥. ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ

សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ជាមូលហេតុចម្បងដែលនាំឱ្យមានការរៀបចំទីក្រុងផងដែរ។ ពីព្រោះ បានអនុគ្រោះទៅដល់ដំណើរការអភិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀតមានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងឱកាសរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ នៃថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជានាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវអនុសាសន៍ជាច្រើនក្នុងនោះបានកំណត់យកគោលការណ៍ភូមិ ឃុំមានសុវត្ថិភាព ដើម្បីលើកកម្ពស់នឹងជម្រុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅគ្រប់ច្រកល្ហកទូទាំងប្រទេសកម្ពុជា។ តាមរយៈ

[២៥] សេចក្តីណែនាំ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ នឹងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់នៅភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០១៣/១៨, ចុះនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨

អនុសាសន៍ដ៏ថ្លៃថ្លានេះក្រសួងមហាផ្ទៃ បានធ្វើការកំណត់យកភូមិ-ឃុំមានសុវត្ថិភាព គឺជាគោលនយោបាយអាទិភាពមួយដែលសម្រាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងនៅក្នុងជួរនៃរដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាជួយពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈឱ្យបានស្អាតល្អនៅគ្រប់ភូមិឃុំទូទាំងប្រទេស។[២៦] ក្រោយមកដើម្បីឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងគៀងគរឱ្យមានការចូលរួមកាន់តែច្រើនឡើង គឺរាជរដ្ឋាភិបាលបានសម្រេចកែលម្អលក្ខណៈសម្បត្តិនៃគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់-មានសុវត្ថិភាព" ព្រមទាំងបានលើកនូវកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរដូចខាងក្រោម៖

❖ **គោលបំណង និងសំណូមពរ**

- បន្តកសាង និងពង្រឹងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែងនឹងគ្រប់ពេលវេលាទៅតាមរយៈការតស៊ូ លុបបំបាត់បទល្មើសគ្រប់ប្រភេទ នៅក្នុងមូលដ្ឋានភូមិ-ឃុំ-សង្កាត់នៅទូទាំងប្រទេស។
- លក្ខណៈសម្បត្តិភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពជាភូមិ-ឃុំ-សង្កាត់មានលក្ខណៈសម្បត្តិ ០៧យ៉ាងដូចខាងក្រោម៖
    - ផ្តល់សេវាសាធារណៈ គឺផ្តល់សេវារដ្ឋបាល ប្រកបដោយគុណភាពតម្លាភាព និងការទទួលបានទំនុកចិត្ត
    - គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
    - គ្មានអំពើអានាចារ្យ ការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហឹង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង
    - ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការដោយគុណភាព និងមានប្រសិទ្ធិភាព
    - មានអនាម័យសោភ័ណភាពល្អ និងមានបរិស្ថានល្អ
    - ឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតដែលកាចសាហាវប្រកបដោយប្រសិទ្ធិភាព

---

[២៦] ផែនការណែនាំ ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព, លេខ ០២០៨.ក, ចុះនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

- មានសណ្ដាប់ធ្នាប់ល្អ និងគ្មានគ្រោះថ្នាក់ចរាចរណ៍។ [២៧]

➢ ចំពោះរដ្ឋបាលខណ្ឌព្រែកព្នៅវិញ គឺបានធ្វើការផ្សព្វផ្សាយណែនាំឱ្យសង្កាត់ចំនួន ០៥ ធ្វើផែនការកម្មវិធីប្រចាំសប្ដាហ៍ឱ្យបានទៀងទាត់នៅក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពតាមមូលដ្ឋានរបស់ខ្លួនដោយៈ

- ធ្វើការផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ដែលនៅតាមសាលារៀន នៅគ្រឹះស្ថានសិក្សាមានចំនួន ០១លើកនៅក្នុងនោះមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចូលរួមសរុប ៤៩២នាក់ (៣២៦ នាក់ស្រី)។

- មានការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ដែលមានការធ្វើសកម្មភាពរៀបចំផែនការល្បាត ពួនស្ទាក់ បង្ការទប់ស្កាត់ បង្ក្រាបបទល្មើស នៅក្នុងមូលដ្ឋានសង្កាត់នីមួយៗ ដែលត្រូវសហការជាមួយផ្នែកជំនាញរបស់អធិការដ្ឋាន នគរបាលខណ្ឌព្រែកព្នៅ។[២៨]

សូមបញ្ជាក់ផងដែរ នៅក្នុងចំនួនប៉ុស្តិ៍នៃរដ្ឋបាលខណ្ឌព្រែកព្នៅមាន ០៥ប៉ុស្តិ៍ ហើយចំនួនប្រជាការពារសរុបចំនួន ៥០២នាក់ ដែលមានក្រុមប្រជាការពារ ៤៩ក្រុម មានស្នាក់ការបំពេញការងារ ០៥ប៉ុស្តិ៍។[២៩] ចំពោះនៅក្នុងន័យសន្តិសុខ ត្រូវបានកំណត់គោលកាណ៍ធំៗសំខាន់ ០៣យ៉ាងរួមមាន សុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ។

➢ **សុវត្ថិភាពបុគ្គល** សំដៅដល់ស្ថានភាពដែលបុគ្គលមានសុវត្ថិភាពលើរូបរាងកាយ និងសេរីភាពដោយគ្មានការគំរាមគំហែងពីការបំពានពីសំណាក់បុគ្គលណាម្នាក់ឡើយ ដោយមានការការពារ និងអន្តរាគមន៍ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។

➢ **សុវត្ថិភាពសម្ភារៈ** សំដៅលើការការពារទ្រព្យសម្បត្តិទាំងអចលនវត្ថុ ចលនវត្ថុ របស់ប្រជាពលរដ្ឋពីសំណាក់រដ្ឋ។ ក្នុងនោះមានការរួមបញ្ចូលពីផ្នែកឯកជន និងផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ ដែលរួម

---

[២៧] គោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល, លេខ ០១គនប, ចុះនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០២១

[២៨] របាយការណ៍ ស្ដីពីលទ្ធផលបូកសរុបនៃការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព, របស់រដ្ឋបាលខណ្ឌព្រែកព្នៅ, ប្រចាំខែមីនា ឆ្នាំ២០២៤

[២៩] របាយការណ៍ ស្ដីពីលទ្ធផលបូកសរុបនៃការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព, របស់រដ្ឋបាលខណ្ឌព្រែកព្នៅ, ប្រចាំខែមីនា ឆ្នាំ២០២៤

មានធនាគារគ្រឹះស្ថានសាធារណៈ មីក្រូហិរញ្ញវត្ថុ បច្ចេកទេសវិទ្យាសាស្ត្រ ជាប្រភេទកម្មវិធីស្កេន QR CODE GPSជាដើម។

- **សុវត្ថិភាពចំណីអាហារ** សំដៅដល់ចំណីអាហារ ដែលអាចទទួលទានបានដោយមានគុណភាពល្អ មិនប៉ះពាល់ដល់សុខភាព មានការផលិតតាមបច្ចេកទេសត្រឹមត្រូវ ទទួលស្គាល់ចេញពីក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងពាក់ព័ន្ធនានា និងមានការធ្វើអធិការកិច្ចម្ហូបអាហារដែលអនុវត្តន៍ដោយមន្ត្រីអធិការកិច្ចម្ហូបអាហាររបស់ក្រសួងពាណិជ្ជកម្ម ឬមន្ត្រីអធិការកិច្ចរបស់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ទៅតាមដំណាក់កាលខ្សែចង្វាក់ផលិតកម្មតាមសមត្ថកិច្ចរៀងៗខ្លួនស្របទៅតាមច្បាប់ និងបទបញ្ញត្តិជាធរមាន។[៣០]

## ១.២. បច្ចុប្បន្នភាពនិងទិសដៅអនាគតនៃការរៀបចំខណ្ឌព្រែកព្នៅ

### ១.២.១. បច្ចុប្បន្នភាពនៃការរៀបចំ

ខណ្ឌព្រែកព្នៅ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញដែលជាទីតាំងល្អក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍។ បច្ចុប្បន្ននេះ ខណ្ឌព្រែកព្នៅមានការរៀបចំដូចជា

#### ១.២.១.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

នាពេលបច្ចុប្បន្ននេះនៅក្នុងខណ្ឌព្រែកព្នៅ សង្កេតឃើញមានការអភិវឌ្ឍខាងហេដ្ឋារចនាសម្ព័ន្ធជាច្រើនគួរឱ្យកត់សម្គាល់។ ជាក់ស្តែងការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធនេះរួមមាន ការដាក់ប្រព័ន្ធលូរំដោះទឹកភ្លៀង ការយកចិត្តទុកដាក់ដោះស្រាយលើប្រជាពលរដ្ឋដែលរស់នៅ នៅលើដីចំណីផ្លូវ ការកសាងផ្លូវ ការដាក់បង្គោលភ្លើងបណ្តាញទឹកស្អាតនឹងមានបណ្តាញអគ្គិសនីប្រើប្រាស់ជាដើម។ ដែលទាំងនេះពិតជាមានសារៈសំខាន់ណាស់ដល់ប្រជាពលរដ្ឋងាយស្រួលក្នុងការធ្វើដំណើរ ការរស់នៅ ការរកស៊ីអាជីវកម្មផ្សេងៗ ជាពិសេស គឺការបញ្ចៀសការកកស្ទះផ្លូវផងដែរ។

#### ១.២.១.២. ការអភិវឌ្ឍគមនាគមន៍

នៅក្នុងការអភិវឌ្ឍផ្លូវថ្នល់នៅឯខណ្ឌព្រែកព្នៅមានគមនាគមន៍តូចធំជាច្រើនមាន ផ្លូវតភ្ជាប់នៃសេដ្ឋកិច្ចយ៉ាងសំខាន់ដែលមានផ្លូវជាតិលេខ៥ ដែលតភ្ជាប់ខេត្តមួយចំនួន រួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ។ ផ្លូវលេខ១៥១ ដែលតភ្ជាប់ពីខេត្តកណ្តាល ជួយរំដោះដល់ការកកស្ទះផ្លូវជាតិលេខ៤ ហើយក៏ជាផ្លូវចូលទៅរមណីយដ្ឋានវប្បធម៌ភ្នំរាប ភ្នំប្រសិត ភ្នំឧត្តុង្គ និងមានផ្លូវបេតុងដែលបានតភ្ជាប់ ពី

[៣០] ច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារ, លេខ នស/រកម/០៦២២/០០៦, ចុះនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២, មាត្រា២០

សង្កាត់មួយទៅសង្កាត់មួយ ពីភូមិមួយទៅភូមិមួយជាច្រើនខ្សែផងដែរ។[៣១] នៅក្នុងខណ្ឌព្រែកព្នៅ មានមហាវិថីចំនួន ០២ធំ គឺមានមហាវិថីសំរោង និងមហាវិថីឈ្នះ ឈ្នះ។ មហាវិថីសំរោងនេះ ស្ថិតនៅសង្កាត់សំរោង ក្នុងខណ្ឌព្រែកព្នៅ ដែលមានប្រវែងសរុប ៥,២០០ម៉ែត្រ ទទឹងផ្លូវ ៣០ម៉ែត្រនិងដាក់សម្ពោធផ្លូវការថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣កន្លងមក។ ដោយមានការតភ្ជាប់ពីផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ផ្លូវក្រវ៉ាត់ក្រុងទី៣ កាត់តាមបុរីភូមិសំរោង ឬផ្លូវ១៣០ ត្រង់ទំនប់កប់ស្រូវដែលជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋតំបន់ខណ្ឌព្រែកព្នៅទៅកាន់គ្រប់បណ្តាខេត្តទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសភ្ជាប់ទៅផ្លូវល្បឿនលឿនភ្នំពេញក្រុងព្រះសីហនុផងដែរ។ មហាវិថីសំរោង គឺជាប្រភេទផ្លូវបេតុងអាមេ ៣ស្រទាប់កម្រាស់សរុប ៨,២តឹក ដែលមានគន្លងឡានម៉ូតូ ៩ម៉ែត្រ សួនកណ្តាល ២ម៉ែត្រ ផ្លូវថ្មើរជើង ៥ម៉ែត្រ មានប្រព័ន្ធលូ២សម្រាប់រំដោះទឹកភ្លៀង និងទឹកកខ្វក់ប្រវែង ២០,៤១២ម៉ែត្រ មុខកាត់រំដោះទឹកភ្លៀងទំហំ ១ម៉ែត្រ មុខកាត់លូរំដោះទឹកកខ្វក់ទំហំ ១ម៉ែត្រ មានបង្គោលភ្លើងប្រភេទសូឡាអមជុំវិញផ្លូវចំនួន ៣៧៧ដើម និងបានដាំដើមឈើនៅអមសងខាងផ្លូវ និងមានសួនកណ្តាលផ្លូវ គឺមានចំនួន ១ ៣៦៤ដើម។[៣២]

ចំណែក មហាវិថីឈ្នះ ឈ្នះ ឬផ្លូវកប់ស្រូវ ជាផ្លូវក្រវ៉ាត់ក្រុងទី៣មានប្រវែងជាង ២៤គីឡូម៉ែត្រ និងទទឹង ២២ ម៉ែត្រ ឆ្លងកាត់ខណ្ឌចំនួន ០៤ចាប់ពីផ្លូវជាតិលេខ៤ដល់ផ្លូវជាតិលេខ៦។ មហាវិថីឈ្នះ ឈ្នះនេះ គឺបានបូកបញ្ចូលគ្នាដោយកំណាត់ផ្លូវ៣ខ្សែ គឺខ្សែទី១ ផ្លូវអូដឹមកប់ស្រូវតភ្ជាប់ពីផ្លូវជាតិលេខ៤ ទៅក្នុងភូមិអូដឹម នៅសង្កាត់ចោមចៅ ទៅកាន់សង្កាត់សំរោងក្រោម ខ្សែទី២(ផ្លូវទំនប់កប់ស្រូវ) នៅសង្កាត់គោករកា រហូតដល់ ផ្លូវជាតិលេខ៥ និងនៅខ្សែទី៣ គឺពីផ្លូវព្រែកព្នៅ ចាប់ពីគល់ស្ពានព្រៃព្នៅខាងកើត។ មុនប្រសិទ្ធិនាមជាមហាវិថីឈ្នះ ឈ្នះ នេះ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ បានឱ្យដឹងថាមហាវិថីឈ្នះ ឈ្នះ (ផ្លូវកប់ស្រូវ) គឺជាផ្លូវខ្សែក្រវ៉ាត់ក្រុងទី៣ សម្រាប់បម្រើការដឹកជញ្ជូនប្រភេទធុនធ្ងន់ និងធុនស្រាល ពង្វាងចរាចរណ៍មិនឱ្យចូលមកក្នុងរាជធានីភ្នំពេញ ដែលស្ថិតនៅក្នុងភូមិសាស្ត្រខាងជើង និងខាងលិចនៃរាជធានីភ្នំពេញ ហើយមានតួនាទីក្នុងការតភ្ជាប់ការដឹកជញ្ជូនមុខទំនិញគ្រប់ប្រភេទ ដែលបានឆ្លងកាត់តាមតំបន់ភាគខាងត្បូង ទៅតំបន់ភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា។ មហាវិថីនេះត្រូវបានបែងចែកជា ២កំណាត់ ក្នុងនោះកំណាត់ផ្លូវទី១ គឺចាប់ពីផ្លូវលេខ៤ ដល់គល់ស្ពានព្រែកព្នៅនៃត្រើយខាងលិចមានប្រវែង ១ ៦ ៦៥០ម៉ែត្រ ជាប្រភេទផ្លូវបេតុងអាមេ។ កំណាត់ផ្លូវទី២ ចាប់គិតពីគល់ស្ពានព្រែកព្នៅត្រើយខាងកើតដល់ផ្លូវលេខ៦ មានប្រវែង ៧ ៨៣៧ម៉ែត្រ មាន

[៣១] សៀវភៅ ផែនការអភិវឌ្ឍន៍ ៥ឆ្នាំរបស់រដ្ឋបាលខណ្ឌព្រែកព្នៅ, ឆ្នាំ២០២០-២០២៤, ទំព័រទី១២

[៣២] គេហទំព័រ សាលារាជធានីភ្នំពេញ https://phnompenh.gov.kh ដកស្រង់នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤

ទទឹង២៥។[៣៣] ទាក់ទងការអភិវឌ្ឍនៅក្នុងវិស័យគមនាគមន៍វិញ រដ្ឋបាលខណ្ឌព្រែកព្នៅមានការរៀបចំទៅលើសុវត្ថិភាពចរាចរណ៍ និងការតុបតែងសោភ័ណភាពផងដែលរួមមាន៖

❖ **ការដាក់ភ្លើងសញ្ញាចរាចរណ៍**

នៅក្នុងខណ្ឌព្រែកព្នៅ មានការរៀបចំបំពាក់ភ្លើងសញ្ញាចរាចរណ៍ទៅតាមដងផ្លូវមហាវិថីជាច្រើនដើម។ នៅក្នុងការដាក់ភ្លើងស្តុបតាមដងផ្លូវនេះ ដើម្បីធ្វើឱ្យមានសុវត្ថិភាពដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ពីព្រោះថាទិសដៅនៃការធ្វើដំណើរតែងមានទៅមានមក ម្យ៉ាងទៀតនៅក្នុងទីប្រជុំជនមានផ្លូវជាច្រើន ដែលចាក់ប្រសព្វមកលើមហាវិថី។ ប្រសិនបើគ្មានការបំពាក់ភ្លើងសញ្ញាចរាចរណ៍ទេនោះប្រជាពលរដ្ឋ និងអាចប្រឈមទៅនឹងគ្រោះថ្នាក់។ ម្យ៉ាងវិញទៀត ការដាក់ភ្លើងសញ្ញាចរាចរណ៍បានជួយសម្រួលដល់អ្នកធ្វើដំណើរថ្មើរជើងឆ្លងកាត់ដោយមិនចាំបាច់បារម្ភពីអសុវត្ថិភាព។ ជាទូទៅភ្លើងសញ្ញាចរាចរណ៍មានបីពណ៌ សម្រាប់អ្នកដំណើរថ្មើរជើងអាចយល់ពីអត្ថន័យតាមពណ៌ដូចជា៖

- រូបដែលមានមនុស្សឈរ មានពណ៌សដើរខាងក្នុង គឺអនុញ្ញាតឱ្យឆ្លងកាត់បាន។[៣៤]
- រូបដែលមានមនុស្សឈរ មានពណ៌សលើផ្ទៃពណ៌បៃតងដើរខាងក្នុងអនុញ្ញាតឱ្យធ្វើការដើរឆ្លងកាត់បាន។
- ពណ៌ក្រហម មានលេខ និងរូបមនុស្សឈរពណ៌ក្រហមលើផ្ទៃខ្មៅត្រូវឈប់ ឬហាមឆ្លងកាត់។ លេខពណ៌ក្រហមប្រាប់រយៈពេលគិតជាវិនាទីដែលនឹងត្រូវប្តូរជាពណ៌បៃតងវិញ។
- ពណ៌បៃតងមានលេខ និងរូបមនុស្សធ្វើចលនាដើរពណ៌បៃតង លើផ្ទៃពណ៌ខ្មៅ អនុញ្ញាតឱ្យដើរឆ្លងកាត់បាន។ ដែលពណ៌បៃតងប្រាប់រយៈពេលគិតជាវិនាទី ដែលនឹងត្រូវប្តូរជាពណ៌ក្រហមវិញ។[៣៥]

❖ **ការដាក់ភ្លើងតាមដងផ្លូវ**

ចំពោះការជួយសម្រួលសុវត្ថិភាពចរាចណ៍នឹងការធ្វើដំណើររបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍វិញ រដ្ឋបាលខណ្ឌមានការយកចិត្តទុកដាក់ជាខ្លាំងក្នុងការរៀបចំមធ្យោបាយបំពាក់អំពូលតាមផ្លូវសាធារណៈ។

---

[៣៣] គេហទំព័រ ក្រសួងសាធារណការ និងដឹកជញ្ជូន https://www.mpwt.gov.kh ដកស្រង់នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤

[៣៤] គេហទំព័រ ក្រសួងសាធារណការ និងដឹកជញ្ជូន https://www.mpwt.gov.kh/kh/press/24215 ដកស្រង់នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤

[៣៥] គេហទំព័រ ក្រសួងសាធារណការ និងដឹកជញ្ជូន Ministry of Public Works and Transport - ដកស្រង់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩

ម្យ៉ាងវិញទៀត ការបំពាក់ភ្លើងអំពូលតាមដងផ្លូវ និងសួរឡានៅទីប្រជុំជន មិនថែមទាំងជួយសម្រួលសុវត្ថិភាព អ្នកធ្វើដំណើរការរៀបចំភ្លើងនេះវាបានជួយដោះស្រាយបញ្ហាអសន្តិសុខជាច្រើន ដែលមានការឆក់ប្លន់ ការប្រព្រឹត្តអំពើកាប់សម្លាប់ រំលោភតាមទីតំបន់សាធារណៈ និងបទល្មើសផ្សេងៗ បន្ថែមលើពីនេះទៀតវាបានធ្វើឱ្យខណ្ឌព្រែកព្នៅ អនុវត្តតាមគោលនយោបាយរបស់រដ្ឋាភិបាល ដែលនិយាយពីភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពផងដែរ។

❖ **ការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ និងទីធ្លាសាធារណៈ**

បើក្រឡេកទៅមើល ការរៀបចំបំពាក់ភ្លើងចម្រុះពណ៌នៅតាមសួនច្បារ និងទីធ្លាសាធារណៈ គឺយើងអាចសង្កេតឃើញថារដ្ឋបាលសាលាខណ្ឌព្រែកព្នៅ មានការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការរៀបចំដាំបង្គោលភ្លើងជាច្រើនតាមកន្លែងសាធារណៈនៅអមសងខាងផ្លូវមហាវិថីឈ្មោះ ឈ្មោះ មហាវិថីសំរោង ជាពិសេសប្រជាពលរដ្ឋនៅក្នុងខណ្ឌព្រែកព្នៅ គឺមានការសហការជាមួយរដ្ឋបាលខណ្ឌជាខ្លាំង ប្រជាជនសឹងតែគ្រប់ផ្ទះបានដាក់អំពូលភ្លើងសួរឡានៅមុខផ្ទះរបស់ពួកគេ រីឯរោងចក្រកាត់ដេរ រោងចក្រឧស្សាហកម្ម សហគ្រាស មានការបំពាក់អំពូលភ្លើង តាមបងហូរហែរចំណែកភោជនីយដ្ឋាន អាហារដ្ឋាន ផ្ទះសំណាក់នៅទីនោះវិញ មានការបំពាក់ភ្លើងពណ៌ចម្រុះជាច្រើនដែលទាំងនោះមានភាពទាក់ទាញជាខ្លាំងមិនចាញ់ខណ្ឌដទៃឡើយ។

**១.២.១.៣ ការអភិវឌ្ឍនៃសំណង់អគារ**

នៅក្នុងខណ្ឌព្រែកព្នៅបច្ចុប្បន្ន មានការរីកចម្រើននូវប្រភេទសំណង់អគារជាច្រើនដែលគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។ ខណ្ឌព្រែកព្នៅ ជាតំបន់ដែលរីកដុះដាលនៃវិស័យសំណង់តូច ធំមិនចាញ់ខណ្ឌដទៃឡើយ គឺមានទាំងគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន មន្ទីរពេទ្យ សហគ្រាស ផ្សារទំនើប ស្ថាប័នរដ្ឋ ស្ថាប័នឯកជនជាដើម ដែលមានដូចជា៖

❖ **គ្រឹះស្ថានសិក្សាមាន**

- **គ្រឹះស្ថានសិក្សារដ្ឋ** មានសាលាបឋមសិក្សាហ៊ុនសែនសំរោងជើង សាលាបឋមសិក្សាព្រែកព្នៅ សាលាបឋមសិក្សាកប់ស្រូវ អនុវិទ្យាល័យព្រែកព្នៅ វិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែនសំរោង សាលាវិទ្យាល័យជាស៊ីម ឈូកវ៉ា វិទ្យាល័យបឹងប្រិយ៍ និងវិទ្យាល័យហ៊ុន សែន ពញាពន់។ល។

- **គ្រឹះស្ថានសិក្សាឯកជន** មានសាលាអន្តរជាតិឡាយហ្វ៍ប្រាយ នៅក្នុងសង្កាត់ពន់ឡាំង សាលាភាសាកូរ៉េ ចន់ជូ ក្នុងសង្កាត់គោករកា សាលាប៊ែលធីអន្តរជាតិខណ្ឌព្រែកព្នៅ សាលាអាមេរិកកាំងកាន់សាស នៅខណ្ឌព្រែកព្នៅ។

❖ **ចំណែកមន្ទីរពេទ្យនៅខណ្ឌព្រែកព្នៅមាន**

- **មន្ទីរពេទ្យរដ្ឋ** មន្ទីរពេទ្យបង្អែកខណ្ឌព្រែកព្នៅ មណ្ឌលសុខភាពពញាពន់ មណ្ឌលសុខភាពសំរោង មន្ទីរពេទ្យ តេជោសន្តិភាព នៅបណ្ដោយមហាវិថីឈ្នះ ឈ្នះ មានបំពាក់បរិក្ខារវេជ្ជសាស្រ្តទំនើបៗ តាមស្តង់ដារ ដែលអាចផ្តល់សេវាគ្រប់ផ្នែកទាំងអស់ មានគ្រែព្យាបាលដល់ជិត ១ ០០ ០០០មុឺនគ្រែ។
- **មន្ទីរពេទ្យឯកជនមាន** មន្ទីរសម្រាកព្យាបាល និងសម្ភព ចន្ទី ព្រែកព្នៅ មន្ទីរសម្រាកព្យាបាល សម្ភព ចំប៉ី មន្ទីរពហុព្យាបាល និងសម្ភពគុណម្ដាយ មន្ទីរសម្រាកព្យាបាល ឧត្តមភាពនៅភូមិផ្សារលិច សង្កាត់ព្រែកព្នៅជាដើម។ល។

❖ **បើងាកទៅមើលផ្សារនៅខណ្ឌព្រែកព្នៅមាន**

- ផ្សារដើមគរថ្មី គឺមានបោះដុំទំនិញគ្រប់មុខ និងបន្លែផ្លែឈើមកពីប្រទេសចិន ថៃ ឡាវ វៀតណាម កម្ពុជាដោយផ្ទាល់។ ផ្សារដើមគរថ្មីនេះ និងធ្វើឱ្យរាជធានីភ្នំពេញប្រែមុខមាត់ថ្មីមួយទៀតតាមរយៈការអភិវឌ្ឍព្រោះជាផ្សារបោះដុំធំជាងគេនៅភ្នំពេញ។ ផ្សាដើមគរថ្មីនេះមានផ្ទៃដីប្រមាណជាង ២០ ហិកតា ដែលមានរៀបចំសំណង់អាគារស្អាតមានរបៀបរៀបរយនឹងមានហេដ្ឋារចនាសម្ព័ន្ធនានា ដែលផ្ដល់ឱ្យអាជីវករអាចធ្វើអាជីវកម្មបានរីកចម្រើន។
- ផ្សាព្រែកព្នៅ ផ្សាសំរោង ដែលមានការលក់បន្លែ ត្រីសាច់ ផ្លែឈើ ម្ហូបអាហារ គ្រឿងឧបភោគ គ្រឿងទេសផ្សេងៗ សម្លៀកបំពាក់ជាដើម។[៣៦]

❖ **ចំពោះស្ថាប័នរដ្ឋ និងស្ថាប័នឯកជនរួមមាន**

- **ចំពោះស្ថាប័នរដ្ឋ** សាលាខណ្ឌព្រែកព្នៅ សាលាសង្កាត់នានានៅខណ្ឌព្រែកព្នៅ កងរាជអាវុធហត្ថខណ្ឌព្រែកព្នៅ អធិការដ្ឋាននគរបាលខណ្ឌព្រែកព្នៅ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាដើម។

[៣៦] គេហទំព័រ https://btv.com.kh/article/ ដកស្រង់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

- **ចំពោះស្ថាប័នឯកជន** ធនាគារអេស៊ីលីដា ភីអិលស៊ី ធនាគារអេអ៊ឹមខេ ធនាគារព្រីនស៍ រោងចក្រផ្គុំដំឡើងរថយន្ត រោងចក្រធ្វើម្សៅមី រោងចក្រផលិតកេសកាតុង និងក្រដាសកាតុង សិប្បកម្មផលិតទឹកត្រីទឹកស៊ីអ៊ីវ រោងចក្រកាត់ដេរសម្លៀកបំពាក់ រោងចក្រអាល់កុល រោងចក្រផលិតទ្រនាប់ស្បែកជើង រោងចក្រផលិតកម្មកែច្នៃអង្ករ។ល។

### ១.២.១.៤. ការរៀបចំលំនៅឋាន

លំនៅឋាន នៅក្នុងខណ្ឌព្រែកព្នៅបច្ចុប្បន្ននេះ គឺមានការអភិវឌ្ឍវិស័យសំណង់ នេះឡើងយ៉ាងខ្លាំងក្លា ដែលមានការវិនិយោគពីក្នុងស្រុក និងក្រៅស្រុកដែលមានការសាងសង់ប្រភេទបែបខុនដូរប្រណីត ផ្ទះវីឡាទោល វីឡាកូនកាត់ផ្ទះល្វែង សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះលំហែរ មជ្ឈមណ្ឌលទីតាំងពាណិជ្ជកម្ម ផ្សារទំនើបៗ នឹងមានសួនច្បារ មើលទៅមានសោភ័ណភាពយ៉ាងស្រស់ស្អាត ក្លឹបកម្សាន្ត ភោជនីយដ្ឋានជាច្រើនដែលសាងសង់ឡើងនៅក្នុងខណ្ឌព្រែកព្នៅ។ ប៉ុន្តែការកសាងឡើងប្រភេទសំណង់ទាំងនេះ គឺមានសំណង់ខ្លះ គឺគេពុំបានធ្វើការសាងសង់ឡើងទៅតាមបែបបទនៃស្តង់ដារឱ្យត្រឹមត្រូវដែលស្តីពីសំណង់ សំណង់ខ្លះសាងសង់ឡើងគ្មានរបៀបរៀបរយដោយរំលោភលើចំណីផ្លូវដែលត្រូវមានការយកចិត្តទុកដាក់ពីរដ្ឋបាលខណ្ឌដែលរួមមាន៖

- ការចុះវាយតម្លៃភាគរយនៃសំណង់តាមផ្ទះនីមួយៗក្នុងបុរីCS នៅភូមិស្រែដូនតូច សង្កាត់ពញាពន់ ក្នុងខណ្ឌព្រែកព្នៅ
- ចុះត្រួតពិនិត្យ វាយតម្លៃផលប៉ះពាល់សំណង់ឈ្មោះ ថោង សុភាព ស្ថិតនៅផ្លូវជាតិលេខ៥ នៅភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ
- ចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការកាន់កាប់ជាក់ស្តែងនូវប័ណ្ណកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ តំបន់ស្ពានឡុង ឈិន នៅភូមិផ្សារលិច សង្កាត់ព្រែកព្នៅ
- ចុះណែនាំ ធ្វើការផ្សព្វផ្សាយស្តីពីច្បាប់សំណង់ដល់ប្រជាពលរដ្ឋ និងម្ចាស់លំនៅឋាន ក្នុងខណ្ឌព្រែកព្នៅ
- ចុះត្រួតពិនិត្យសំណង់មិនមានរបៀបរៀបរយនៅតាមទន្លេស្ថិតក្នុងភូមិសាស្ត្រនៅក្នុងខណ្ឌព្រែកព្នៅ បានចុះរុះរើនូវសំណង់មិនរៀបរយនៅលើចំណីផ្លូវ
- បានចុះពិនិត្យការបាក់ស្រុតដី ក្នុងសហគមន៍សំរោងកណ្តាល
- បានចុះស្រង់សំណង់មិនរៀបរយតាមសហគមន៍ចំនួន ០៣ក្នុងខណ្ឌព្រែកព្នៅ

- ចុះស្រង់ស្ថិតិបុរី នៅក្នុងភូមិសាស្ត្រខណ្ឌព្រែកព្នៅ ជូនសាលារាជធានីភ្នំពេញ ស្ដីពីការផ្អាកសំណង់ផ្ទះ ០៥ល្វែងស្ថិតនៅភូមិគ្រួស សង្កាត់សំរោងខណ្ឌព្រែកព្នៅ។[៣៧]

### ១.២.១.៥. ការរៀបចំប្រព័ន្ធលូសាធារណៈ

បន្ទាប់ពីមានការអភិវឌ្ឍវិស័យគមនាគមន៍ វិស័យសំណង់ នៅក្នុងខណ្ឌព្រែកព្នៅ អ្វីដែលគួរឱ្យយកចិត្តទុកដាក់សំខាន់ទៀត គឺការរៀបចំនូវប្រព័ន្ធលូសាធារណៈ។ នៅក្នុងខណ្ឌព្រែកព្នៅ តែងតែមានការស្ទះបញ្ហាលូសាធារណៈដែលតែងលេចលង់ដោយសារជំនន់ទឹកភ្លៀង ចេញពីលំនៅឋានប្រជាពលរដ្ឋ និងផ្លូវថ្នល់។ នៅក្នុងពេលថ្មីៗនេះរដ្ឋបាលខណ្ឌព្រែកព្នៅ បានរៀបចំប្រព័ន្ធលូនឹងស្ថាបនាបណ្ដាញលូនៅទីតាំងសំខាន់ៗមានដូចជាៈ

- ការដាក់លូរំដោះទឹកនៅក្នុងមូលដ្ឋាន នារដូវវស្សាដែលស្ថិតនៅភូមិស្វាយចេក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ មានមុខកាត់ទំហំ ០,៦ ម៉ែត្រ ប្រវែង ២,០៩០ម៉ែត្រ
- ការស្ថាបនាបណ្ដាញលូ ក្នុងមូលដ្ឋានសង្កាត់គោករកា ក្នុងនោះបានដាក់បណ្ដាញលូទំហំ ០,៦០ ម៉ែត្រ ប្រវែង ៤១៥កង់ និងរៀបអណ្ដូងលូ ១១០សង់ទីម៉ែត្រគុណ ១១០សង់ទីម៉ែត្របានចំនួន ១៦អណ្ដូង
- បានចុះស្ដារប្រឡាយចំនួន ២ខ្សែរ បណ្ដោយ ២៤ម៉ែត្រ ទំហំមុខកាត់ ១ម៉ែត្រ មានទទឹង ៤ម៉ែត្រ ដើម្បីរំដោះទឹកភ្លៀងនៅរដូវវស្សាជន់លិច ដែលស្ថិតនៅភូមិកោះរងៀង សង្កាត់ពន្សាំង
- បានស្ថាបនាបណ្ដាញលូរំដោះទឹកចេញ មានប្រវែង ១,៩០០ម៉ែត្រ ទំហំមុខកាត់ ០.៦០ម៉ែត្រ ស្ថិតនៅភូមិសំរោងត្បូង និងភូមិសំរោងកណ្ដាល សង្កាត់សំរោង
- បានស្ថាបនាបណ្ដាញលូរំដោះទឹកចេញ មុខកាត់ ១ម៉ែត្រ បានចំនួន ១២៦កង់នៅក្នុងចំណុចផ្លូវ ៤៥ បឹងតាមោក
- បានដាក់បណ្ដាញលូមុខកាត់ ១,៥ ម៉ែត្រ ប្រវែង ១០ម៉ែត្រដាក់ ០៣ជួរ ត្រង់ចំណុចមុខសាលាវិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា (សាលាកូរ៉េ) ស្ថិតនៅភូមិប្លូវផ្អែម សង្កាត់គោករកា ខណ្ឌព្រែកព្នៅ
- បានស្ថាបនាបណ្ដាញលូរំដោះទឹកចេញស្ថិតនៅក្នុងសហគមន៍សំរោងត្បូង សង្កាត់សំរោង ទំហំ ០.៦០ម៉ែត្រ សរុបទាំងអស់ដាក់បានចំនួន ១,២១៧កង់

[៣៧] របាយការណ៍ ស្ដីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌព្រែកព្នៅ, លេខ ០០៩/២៤ របក, ឆ្នាំ២០២៣, ទំព័រទី៨២

- បានដាក់បណ្តាញលូទំហំ ០,៦០ម៉ែត្រ ប្រវែង ៧១៤កង់ និងរៀបអណ្តូងលូទំហំ ១ម៉ែត្រគុណ ១ម៉ែត្របានចំនួន ៣២អណ្តូង នៅទីតាំងដីពុះឡូតិ៍ ជូនប្រជាពលរដ្ឋ សហគមន៍១៥១ ស្ថិតនៅភូមិសំរោងត្បូង
- ចុះពិនិត្យមើលការស្តារអណ្តូងលូដែលមានដី កកស្ទះត្រង់ចំណុចក្រោមស្ពានព្រែកព្នៅរហូតទៅដល់កែងស្តុបផ្លូវមហាវិថីឈ្នះ ឈ្នះ ស្ថិតក្នុងខណ្ឌព្រែកព្នៅ
- ដាក់គ្រឿងចក្រកាយប្រឡាយ ដើម្បីរំដោះទឹកចេញពីភូមិកប់ស្រូវតូច ភូមិអង្គតាកូវ ភូមិជំរៅ ភូមិត្រពាំងសំព័រ សង្កាត់គោករការ។[៣៨]

## ១.២.២. ទិសដៅរៀបចំពេលអនាគតនៅខណ្ឌព្រែកព្នៅ

### ១.២.២.១. ការរៀបចំប្រព័ន្ធទឹកស្អាត

នៅក្នុងខណ្ឌព្រែកព្នៅ គឺតែងមានការកង្វះខាតទាក់ទង និងការផ្គត់ផ្គង់ទឹកមិនទាន់តម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាននៅឡើយ ដែលជាបញ្ហាមួយដែលពិបាកក្នុងការដោះស្រាយ។ ប្រជាពលរដ្ឋនៅខណ្ឌព្រែកព្នៅ នៅសង្កាត់ខ្លះនៅតែគ្មានបណ្តាញទឹកស្អាតប្រើប្រាស់ ហើយនៅពេលដែលមានការខ្សត់ទឹកប្រើប្រាស់នៅរដូវក្តៅម្តងៗមានក្រុមការងារ រដ្ឋបាលខណ្ឌចុះដឹកអណ្តូង និងស្តារស្រះសម្រាប់ពលរដ្ឋប្រើប្រាស់។ ពេលខ្លះប្រជាពលរដ្ឋ នៅក្នុងសង្កាត់ និងផ្ទះបុរីមួយចំនួន នៅពេលដែលទឹកដាច់ម្តងៗតែងតែទិញទឹកយកទៅប្រើប្រាស់ប្រចាំថ្ងៃ បើទោះបីជាមានអាជ្ញាធរខណ្ឌ និងម្ចាស់បុរីមួយចំនួន បានចុះចែកទឹកទៅឱ្យប្រជាពលរដ្ឋបានប្រើប្រាស់រយៈពេលប៉ុណ្ណោះអាសន្នក៏ដោយ។ ចំពោះមូលហេតុនាំឱ្យមានកង្វះទឹកប្រើប្រាស់នេះ គឺបណ្តាលពីការចូលមករស់នៅក្នុងខណ្ឌព្រែកព្នៅ គឺមានចំនួនប្រជាពលរដ្ឋច្រើន ចំណែកអង្គភាពរដ្ឋាករស្វយ័តដែលកំពុងធ្វើការ តនូវបណ្តាញថ្មីសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត នៅខណ្ឌព្រែកព្នៅ មិនបានគ្រប់គ្រាន់ក្នុងការប្រើប្រាស់។ ម៉្យាងទៀត ប្រជាពលរដ្ឋបានលើកឡើងថាកម្លាំងទឹកដែលធ្វើការផ្គត់ផ្គង់មានភាពខ្សោយ ចេញតិច ប្រើប្រាស់មិនគ្រប់គ្រាន់ និងមានបញ្ហាក្លិនស្អុយផងដែរ។ ដើម្បីឱ្យមានការគ្រប់គ្រងទឹកស្អាតបាន រដ្ឋបាលខណ្ឌព្រែកព្នៅកំពុងខិតខំជម្រុញថ្នាក់លើដើម្បីរកដំណោះស្រាយមកជូនប្រជាពលរដ្ឋ និងលើកសំណើពីគុណភាពទឹកឆ្លងទៅអភិបាលខណ្ឌ ដើម្បីអញ្ជើញក្រុមអ្នកជំនាញមកពីក្រសួងឧស្សាហកម្ម សិប្បកម្ម និងរដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ ចុះមកត្រួតពិនិត្យមើលគុណភាពឱ្យបានច្បាស់លាស់ ដើម្បីឱ្យ

[៣៨] របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌព្រែកព្នៅ, លេខ ០០៩/២៤ របក, ឆ្នាំ២០២៣, ទំព័រទី៣៨

ក្រុមហ៊ុនកែតម្រូវតាមគុណភាពស្តង់ដារដែលរក្សាបាននូវសុវត្ថិភាព និងសុខភាពអ្នកប្រើប្រាស់ផងដែរ។[៣៩] បើយោងទៅតាមប្លង់គោលប្រើប្រាស់ដីនៅខណ្ឌព្រែកព្នៅចក្នុវិស័យ ឆ្នាំ២០៣៥ បញ្ហារៀបចំផ្គត់ផ្គង់ទឹកស្អាតនឹងត្រូវបានរៀបចំនៅក្នុងខណ្ឌព្រែកព្នៅដែលមាន៖

- ការត្រួតពិនិត្យបណ្តាញផ្គត់ផ្គង់ទឹកស្អាត
- មានបំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗដែលខូច
- សិក្សាពីបណ្តាញផ្គត់ផ្គង់ទឹកថ្មីរហូតឆ្នាំ២០៣៥
- អភិវឌ្ឍន៍ស្ថានីយចម្រោះទឹកស្អាត និងបណ្តាញចែកចាយទឹកស្អាតរហូតដល់ឆ្នាំ២០៣៥។[៤០]

### ១.២.២.២. ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍

ដើម្បីធ្វើការលើកកម្ពស់ដល់គុណភាពរស់នៅ ប្រកបទៅដោយភាពងាយស្រួលក្នុងការទំនាក់ទំនងនឹងសន្សំសំចៃដើម្បីឆ្លើយតបតម្រូវការបច្ចុប្បន្នភាព និងអនាគត ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្នុវិស័យ ឆ្នាំ ២០៣៥ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ខណ្ឌឆ្លាតវៃ តាមរយៈការគិតគូរបំពាក់នូវបរិក្ខារ និងសេវាកម្មសម្រាប់ខណ្ឌឆ្លាតវៃមានក្នុងវិស័យសំខាន់ៗដូចជា ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងវិស័យទូរគមនាគមន៍៖

❖ **ការផ្គត់ផ្គង់ថាមពលអគ្គិសនី**

- រៀបចំផ្គត់ផ្គង់ថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យតាមផ្លូវសាធារណៈ
- លើកកម្ពស់ការប្រើប្រាស់ថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ
- ដំឡើង និងជួសជុលបណ្តាញអគ្គិសនីបំភ្លឺតាមមហាវិថី អនុមហាវិថី និងទីសាធារណៈ
- ធ្វើផែនការអគ្គិសនីប្រកបដោយប្រសិទ្ធិភាពខ្ពស់
- ជម្រុញបង្កើតបទបញ្ញត្តិការផ្គត់ផ្គង់ការប្រើប្រាស់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយបន្ទុក បរិស្ថាន
- អភិវឌ្ឍន៍បណ្តាញផ្គត់ផ្គង់អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានទំលំទូលាយនឹងមានសណ្តាប់ធ្នាប់ និងសោភ័ណភាព

[៣៩] គេហទំព័រ https://www.kampucheathmey.com/local-news/280728 ដកស្រង់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤

[៤០] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្នុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី២០

- កែលម្អបណ្តាញអគ្គិសនី និងទូរគមនាគមន៍ឱ្យសមស្របតាមបទដ្ឋានបច្ចេកទេស ជៀសវាងបង្ក គ្រោះថ្នាក់ និងបាត់បង់នូវសោភ័ណភាពខណ្ឌ
- រៀបចំឱ្យមានប្រព័ន្ធសុវត្ថិភាពស្វ័យប្រវត្តិតាមទីសាធារណៈ ដើម្បីងាយស្រួលអន្តរាគមន៍ ឱ្យបាន ទាន់ពេលវេលាដើម្បីធានាឱ្យបាននូវសុវត្ថិភាពនៃការរស់នៅ
- ជម្រុញលទ្ធភាពនៃការរៀបចំបណ្តាញអគ្គិសនី ឬបណ្តាញបញ្ជូនអគ្គិសនី បណ្តាញទូរគមនាគមន៍ ខ្សែកាប្លិ៍គ្រប់ប្រភេទដែលកប់ក្នុងដី ដើម្បីអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរក្សាដល់សោភ័ណភាព ទីក្រុង
- ជម្រុញការវិនិយោគ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដើម្បីគាំទ្រដល់ការអភិវឌ្ឍ សេដ្ឋកិច្ច ទេសចរណ៍ និងពាណិជ្ជកម្ម។

## ❖ វិស័យទូរគមនាគមន៍

- បន្ត តាមរយៈការដាក់យុទ្ធសាស្ត្រអភិវឌ្ឍន៍ខណ្ឌឆ្លាតវៃនៅក្នុងវិស័យទូរគមនាគមន៍នេះ គឺមានការ ចែកចេញជា០២ គឺការផ្តល់សេវាអ៊ីនធឺណេតសាធារណៈ និងការកសាងមជ្ឈមណ្ឌលទិន្នន័យ មានដូចជា៖
- **សេវាអ៊ីនធឺណេតសាធារណៈ**
  - ផ្តល់ការប្រើប្រាស់សេវាអ៊ីនធឺណេតសាធារណៈជូនដល់សាធារណជនទូទៅ នៅក្នុងកន្លែង សាធារណៈ ដូចជាស្ថាប័នរដ្ឋ សួនកម្សាន្ត តំបន់ទេសចរណ៍ តំបន់វប្បធម៌ និងមហាវិថីធំៗ ដែលផ្តល់ដោយស្ថាប័ន លើផ្តត់ផ្គង់សេវាទូរគមនាគមន៍ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល
  - រៀបចំ និងផ្សព្វផ្សាយផែនទីបង្ហាញទីតាំងដែលមានសេវាអ៊ីនធឺណេតសាធារណៈ។
- **មជ្ឈមណ្ឌលទិន្នន័យសាធារណៈ**
  - សិក្សានូវលទ្ធភាព ក្នុងការកសាងមជ្ឈមណ្ឌលទិន្នន័យ សម្រាប់ជំនួយគម្រោងខណ្ឌឆ្លាតវៃ ដែលអាចធ្វើការគ្រប់គ្រង និងប្រមូលទិន្នន័យបច្ចុប្បន្នភាពក្នុងខណ្ឌ
  - ជាមជ្ឈមណ្ឌលសម្រាប់ធ្វើដំណើរការប្រព័ន្ធទិន្នន័យ របស់រាជរដ្ឋាភិបាល នៅក្នុងតំបន់ដែល អាចជួយ សម្រួលនឹងដំណើរការនូវគេហទំព័រ សេវាកម្មដល់ប្រជាពលរដ្ឋ ការងាររដ្ឋបាល និង ជាប្រភពទិន្នន័យសម្រាប់ប្រព័ន្ធការងាររដ្ឋបាលអន្តរជាតិផង

- ជាមជ្ឈមណ្ឌល ដែលអាចវិភាគ និងដោះស្រាយបញ្ហារបស់ខណ្ឌបានទាន់ហេតុការណ៍
- សេវាផ្តល់សេចក្តីជូនដំណឹងពីព័ត៌មាន ស្តីពីសេវាសាធារណៈនៅក្នុងខណ្ឌដល់ប្រជាពលរដ្ឋ
- រៀបចំប្រព័ន្ធសេវាផ្តល់ព័ត៌មាន ដល់ប្រជាពលរដ្ឋបានទៀងទាត់ និងទាន់ហេតុការណ៍ ដូចជា សន្តិសុខ ចរាចរណ៍ សុខាភិបាល រដ្ឋបាល បរិស្ថាន សេដ្ឋកិច្ច និងវប្បធម៌ជាដើម។

### ១.២.២.៣. ការអភិវឌ្ឍលើវិស័យពាណិជ្ជកម្ម

ខណ្ឌព្រែកព្នៅ គឺជាខណ្ឌមួយមានសក្តានុពលសំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ព្រោះប្រជាពលរដ្ឋប្រកបរបរកសិកម្មមាន (៣៥,ភាគរយ) មុខរបរក្រៅពីវិស័យកសិកម្មមាន (៦៤,៥ភាគរយ) ទាំងនេះ គឺបានបង្ហាញឱ្យឃើញថាជីវភាពប្រជាពលរដ្ឋដែលធ្លាប់តែធ្វើកសិកម្មឥឡូវប្តូរមកជា សិប្បកម្ម សេវាកម្មផ្សេងៗជាច្រើនទៅតាមជំនាញ និងតម្រូវការរៀងៗខ្លួន ដោយសារស្ថានភាព និងកត្តាភូមិសាស្ត្ររបស់ខណ្ឌព្រែកព្នៅមានផ្ទៃដីធំទូលាយដែលអំណោយផលដល់ការអភិវឌ្ឍផ្នែកអាជីវកម្មផ្សេងៗមានរោងចក្រ សហគ្រាស និងសំណង់បែបលំនៅឋាន។[៤១] ដូច្នេះហើយការអភិវឌ្ឍទៅលើវិស័យឯកជនជាក្បាលម៉ាស៊ីនដ៏សំខាន់ សម្រាប់កំណើនសេដ្ឋកិច្ច ដែលខណ្ឌព្រែកព្នៅ តែងតែធ្វើការទាមទារឱ្យមានការវិនិយោគផ្ទាល់ពីវិស័យឯកជន ក៏ដូចជាបានកាត់បន្ថយដល់ភាពក្រីក្រដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានផងដែរ។ កន្លងទៅ នៅក្នុងឆ្នាំ២០២២ ក្នុងខណ្ឌព្រែកព្នៅមានការបើកផ្លូវពាណិជ្ជកម្មបុរីភូមិសំរោង ពីក្រុមហ៊ុនព្រីន ហ័ន យូ រៀល អ៊ីស្តេតគ្រុប និងអ្នកតំណាងក្រុមហ៊ុនផលិតផលពាណិជ្ជកម្មប្រហែល ៥០ក្រុមហ៊ុន នៅលើផ្ទៃដី ២៧០ហិកតា នៅបណ្តោយផ្លូវជាតិលេខ៥ ក្នុងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ ដែលបានវិនិយោគលើវិស័យពាណិជ្ជកម្មដែលរួមមាន ប្រភេទបណ្តុំហាងផ្គត់ផ្គង់សង្ហារឹមខ្នាតធំ ផ្សារទំនើប ភោជនីយដ្ឋានល្បីៗ ក្លឹបកម្សាន្ត ធនាគារ ហាងកាហ្វេ ផ្ទះ Shop house សបហោស៍ប្រភេទ Link villa លីង វីឡាសេវាកម្មតុបតែងផ្ទះ និងហាងលក់ផ្នែកបរិក្ខារអគ្គិសនី ជាពិសេសគម្រោងបុរីភូមិសំរោងនេះ ក៏មានការរៀបចំបង្កើតជាមជ្ឈមណ្ឌលវប្បធម៌ សារៈមន្ទីរ និងមន្ទីរពេទ្យអន្តរជាតិ និងមានទីតាំងកម្សាន្តខ្នាតធំដែលនឹងក្លាយទៅជាទីកន្លែងពេញនិយមស៊ីវិល័យនៅក្នុងរាជធានីភ្នំពេញពេលអនាគតផងដែរ។[៤២]

ដោយមើលឃើញពីការរីកចម្រើនទៅដល់វិស័យពាណិជ្ជកម្មយ៉ាងច្រើន ខណ្ឌព្រែកព្នៅ គឺមានការដាក់ចេញនូវគោលការណ៍មួយចំនួនដើម្បីឱ្យវិស័យឯកជនចូលមកវិនិយោគក្នុងមូលដ្ឋានមួយចំនួនដូចជា៖

---

[៤១] សៀវភៅ ផែនការអភិវឌ្ឍន៍ ៥ឆ្នាំ របស់រដ្ឋបាលខណ្ឌព្រែកព្នៅ, ឆ្នាំ២០២០-២០២៤, ទំព័រទី១២

[៤២] គេហទំព័រ https://m.freshnewsasia.coml ដកស្រង់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

- លើកទឹកចិត្ត និងជម្រុញការចូលរួមរបស់វិស័យឯកជនមៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ពិនិត្យឡើងវិញពីច្បាប់ស្តីពីសម្បទានព្រមទាំងលិខិបទដ្ឋានគតិយុត្តនានា
- បន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ទាំងឡាយដើម្បីគាំទ្រដល់ការបង្កើតធុរកិច្ច និងលើកកម្ពស់ ការវិនិយោគសាធារណៈ
- បង្កើតបរិយាកាសអំណោយផលសម្រាប់ការទទួលការវិនិយោគ ក្នុងមូលដ្ឋានរួមមានការសម្រួលការចុះបញ្ជី ការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗជាពិសេសនៅតាមយន្តការច្រកចេញចូលតែមួយ គឺដើម្បីពន្លឿនរាល់ប្រតិបត្តិការនានាពាក់ព័ន្ធនឹងធុរកិច្ច ការវិនិយោគ ព្រមទាំងការកាត់បន្ថយ ការចំណាយក្រៅផ្លូវការ
- បន្តអនុវត្តន៍យន្តការ វេទិការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងវិស័យឯកជននានា ដើម្បីធ្វើការដោះស្រាយរាល់បញ្ហា ឬកង្វល់ផ្សេងៗរបស់ប្រជាពលរដ្ឋ និងវិស័យឯកជន គឺដើម្បីពង្រឹងឱ្យកាន់តែមានជីវភាពល្អប្រសើរ
- ផ្តោតការយកចិត្តទុកដាក់ទៅលើការផ្សព្វផ្សាយ និងការទាក់ទាញលើការវិនិយោគផ្ទាល់ថែមទាំងលើកកម្ពស់សេវា ថែរក្សាវិនិយោគដែលមានស្រាប់។[៤៣]
- សម្រាប់ទិសទៅការរៀបចំការអភិវឌ្ឍវិស័យពាណិជ្ជកម្មនៅពេលអនាគតក្នុងខណ្ឌព្រែកព្នៅ និងធ្វើការរៀបចំដូចជាៈ
  - ធ្វើការបែងចែក តំបន់ប្រើប្រាស់ដីពាណិជ្ជកម្មសម្រាប់អនាគតបានច្បាស់លាស់ និងត្រឹមត្រូវ
  - កែលម្អ និងពង្រីកទីផ្សាររលក់ដូរដើម្បីប្រជាពលរដ្ឋ និងអាជីវករក្នុងផ្សារមានកន្លែងលក់ដូរធំទូលាយមាននូវសណ្តាប់ធ្នាប់ល្អ
  - រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ និងមណ្ឌលព័ត៌មាន អំពីស្តង់ដារនៃបច្ចេកទេសផលិតផលក្នុងស្រុកទៅដល់ប្រជាពលរដ្ឋ
  - កែលម្អផ្សារ និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានស្រាប់ទាំងឯកជន និងរដ្ឋមានលក្ខណៈស្តង់ដារដែលរួមមានចំណតយានយន្ត ច្រកចេញចូលផ្លូវដើរនៅក្នុងផ្សារ បណ្តាញទឹកស្អាត

[៤៣] សៀវភៅ ផែនការអភិវឌ្ឍន៍ ៥ឆ្នាំ របស់រដ្ឋបាលខណ្ឌព្រែកព្នៅ, ឆ្នាំ២០២០-២០២៤, ទំព័រទី១២

- បណ្តាញអគ្គិសនី តំបន់បៃតង ហេដ្ឋារចនាសម្ព័ន្ធ កន្លែងកម្សាន្តនានា ឱ្យមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់។
- រៀបចំបង្កើតផ្សារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាជន
- គាំទ្រមានការវិនិយោគផ្សារទំនើប ហាងទំនិញ ផ្សាររាត្រី មជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ សហគ្រាសឃ្លាំងផ្សេងៗ ដើម្បីងាយស្រួលក្នុងការដោះដូរទំនិញបង្កើតការងារ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចបានខ្លាំងក្លា
- រៀបចំដេប៉ូស្តុកទំនិញសម្រាប់ចែកចាយនៅក្នុងខណ្ឌ និងនៅតំបន់ជុំវិញការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធបានល្អដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន
- រៀបចំទីកន្លែងសម្រាប់តាំងពិព័រណ៍ និងផ្សព្វផ្សាយនូវផលិតផលគ្រប់ប្រភេទដើម្បីបង្កើននូវការផលិតជម្រុញសេដ្ឋកិច្ចបានខ្លាំងក្លា។[៤៤]

**១.២.២.៤. ការអភិវឌ្ឍលើវិស័យឧស្សាហកម្ម**

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ទិសដៅក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេស មានប្រាក់ចំណូលមធ្យមក្នុងឆ្នាំ២០៣០ និងមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ។ ទិសដៅនេះបញ្ជាក់ពីតួនាទីនៃវិស័យឧស្សាហកម្ម និងសហគ្រាសធុន តូច និងមធ្យម ដែលជាកត្តាជម្រុញដ៏សំខាន់ចំពោះកំណើននាពេលអនាគត។[៤៥] ងាកមកមើលនៅខណ្ឌព្រែកព្នៅ វិស័យឧស្សាហកម្ម រួមមានក្រុមហ៊ុន រោងចក្រ សរុបចំនួន ១១រោងចក្រ និងកម្មករសរុប ១.៦២៤នាក់ មានស្រី ៦១នាក់។ សិប្បកម្មមានចំនួន ៤៣កន្លែងមានកម្មករសរុប ៤៧១នាក់ ស្រី ២០៥នាក់។ រោងចក្រ សិប្បកម្មទាំងនោះរួមមាន រោងចក្រទឹកស៊ីអ៊ីវ រោងចក្រកាត់ដេរ រោងចក្រផលិតម្សៅមី កែច្នៃអង្ករ រោងចក្រអាល់កុល ទ្រនាប់ស្បែកជើង បោកគក់ ផលិតតម្លើងគ្រឿងដែក និងការងារសំណង់ជាដើម។ នៅមានឧស្សាហកម្ម មួយចំនួនទៀតដែលមិនទាន់មានច្បាប់អនុញ្ញាត។[៤៦]

យោងទៅតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានផ្សាយតាំងពីខែមករា ដល់ដំណាច់ខែមីនា ឆ្នាំ២០២៣ កន្លងទៅឃើញថាគម្រោងវិនិយោគ អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

[៤៤] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី១៤

[៤៥] គេហទំព័រ https://opendevelopmentcambodia. / ដកស្រង់នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤

[៤៦] សៀវភៅ ផែនការអភិវឌ្ឍន៍ ៥ឆ្នាំរបស់រដ្ឋបាលខណ្ឌព្រែកព្នៅ, ឆ្នាំ២០២០-២០២៤, ទំព័រទី១២

នៅរាជធានីភ្នំពេញ គឺសុទ្ធសឹងតែគម្រោងរោងចក្រ និងមានទីតាំងនៅតំបន់ជាយក្រុងនៃរាជធានីភ្នំពេញមានទុនវិនិយោគចន្លោះពី ១ ០០០ ០០០ ទៅ ៥ ០០០ ០០០លានដុល្លារអាមេរិក ដែលមានគម្រោងវិនិយោគ ០៨ ឧស្សាហកម្ម ដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅក្នុងរាជធានីភ្នំពេញមានទឹកប្រាក់សរុប ៣៧.៨ លានដុល្លាអាមេរិក។ ដែលនៅក្នុងនោះមានទីតាំងមួយចំនួននៅក្នុងខណ្ឌព្រែកព្នៅផងដែលរួមមាន៖

- គម្រោងវិនិយោគរោងចក្រផលិតគ្រឿងបន្សំស្បែកជើង គឺមានទីតាំងនៅសង្កាត់គោករកា នៅក្នុងខណ្ឌព្រែកព្នៅនៃរាជធានីភ្នំពេញមានទុនវិនិយោគចំនួន ៥.១លានដុល្លារអាមេរិក
- គម្រោងរោងចក្រផលិតកេសកាតុង និងសម្ភារៈវេចខ្ចប់មានទីតាំងនៅក្នុង ភូមិកប់ស្រូវ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ មានទុនវិនិយោគចំនួន ៥.៣លានដុល្លារអាមេរិក។[៤៧]
- ចំពោះផែនការពេលអនាគតនៃការរៀបចំវិស័យឧស្សាហកម្ម នៅក្នុងខណ្ឌព្រែកព្នៅ មានការរៀបចំទៅលើ៖
  - រៀបចំបែងចែកតំបន់ឧស្សាហកម្ម សមស្របទៅតាមបទដ្ឋានបច្ចេកទេស និងត្រូវមានទីតាំងដាច់ចេញពីតំបន់លំនៅឋាន
  - បង្កើនឧស្សាហកម្មបៃតងសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលសំដៅការតភ្ជាប់រវាងសហគ្រាសខ្នាតធំ ក្រៅប្រទេស និងសហគ្រាសនៅក្នុងស្រុក ជាពិសេសមានការចូលរួមនៅក្នុងខ្សែចង្វាក់តម្លៃនឹងខ្សែចង្វាក់ ផលិតកម្ម
  - ជម្រុញអភិវឌ្ឍន៍ឧស្សាហកម្មបែបធុនស្រាល ឬសិប្បកម្មដែលប្រើប្រាស់មានជា គ្រឿងម៉ាស៊ីនស្វ័យប្រវត្តិទំនើប សម្រាប់កែច្នៃផលិតផលក្នុងស្រុក និងសម្ភារៈប្រើប្រាស់ផ្សេងៗ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខណ្ឌ ក៏ដូចជាក្នុងរាជធានីសម្រាប់ការចែកចាយទាំងក្នុងប្រទេស និងក្រៅប្រទេស
  - លើកទឹកចិត្ត ការវិនិយោគរោងចក្រ ផលិតគ្រឿងបរិភោគ និងភេសជ្ជៈ រោងចក្រដំឡើងយានយន្តមានគ្រឿងអេឡិចត្រូនិច និងសិប្បកម្មដែលអាចជួយបង្កើតការងារជូនប្រជាពលរដ្ឋដើម្បីលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃ

[៤៧] គេហទំព័រ https://propertyarea.asia/archives/ ដកស្រង់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤

- លើកទឹកចិត្តទៅដល់អ្នកវិនិយោគទាំងជាតិ និងអន្តរជាតិដែលមកធ្វើឧស្សាហកម្មបៃតងនៅក្នុងខណ្ឌ។[៤៨]
- ផ្លាស់ប្តូរទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មបច្ចុប្បន្នដែលរងការប៉ះពាល់ដល់បរិស្ថាន សុខភាព រៀបចំសាងសង់ និងកែសម្រួលឡើងវិញស្របតាមស្តង់ដារបរិស្ថាននឹងតាមប្លង់គោលប្រើប្រាស់ដីខណ្ឌ។[៤៩]

### ១.២.២.៥. ការអភិវឌ្ឍវិស័យដឹកជញ្ជូន

ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន គឺវាជាយុទ្ធសាស្ត្រចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ។ បច្ចុប្បន្ននេះ នៅកម្ពុជាកំពុងស្ថិតនៅក្នុងដំណើរការនៃការបញ្ចប់ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនអន្តរមធ្យោបាយកម្ពុជា២០២២-២០៣០ (CIT- MP) ដែលជាការរួមបញ្ចូលគ្នាផែនការមេ និងការអភិវឌ្ឍរចនាសម្ព័ន្ធទាំងផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស កំពង់ផែ ភស្តុភាកម្ម និងការដឹកជញ្ជូនបែបអន្តរកម្ម។[៥០] ការអភិវឌ្ឍវិស័យដឹកជញ្ជូននេះពិតជាសំខាន់ខ្លាំងណាស់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ដែលបច្ចុប្បន្នការកើនឡើងនៃកំណើនប្រជាជន គឺកាន់តែមានសន្ទុះខ្ពស់ដែលធ្វើឱ្យមានកំណើនតម្រូវការនៃការប្រើប្រាស់គមនាគមន៍ច្រើនសម្រាប់ជាមធ្យោបាយធ្វើដំណើរ ដឹកជញ្ជូនអ្នកដំណើរ និងប្រភេទទំនិញ។ ម្យ៉ាងវិញទៀតនៅពេលបច្ចុប្បន្ន ប្រជាពលរដ្ឋ គឺចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសឹងគ្រប់ៗគ្នាធ្វើឱ្យពួកគេទទួលសេវា ក្នុងការដឹកជញ្ជូនទំនិញនៅតាមបណ្តាលប្រទេសលើពិភពលោកបានយ៉ាងងាយស្រួល ជាពិសេសនោះ គឺអាចធ្វើដំណើរទៅកាន់មន្ទីរពេទ្យជិតខាង ធ្វើដំណើរកម្សាន្ត ទៅកាន់ប្រទេសតំបន់អាស៊ី ក្នុងសមាជិកអាស៊ាន ដោយមានមធ្យោបាយគមនាគមន៍ ធ្វើដំណើរទាំងផ្លូវគោក ផ្លូវអាកាស ងាយស្រួលផងដែរ។

ដោយមើលឃើញពីផលវិជ្ជមាន នៃវិស័យដឹកជញ្ជូននេះក្នុងពេលទិសដៅអនាគត ក្នុងខណ្ឌព្រែកព្នៅនឹងមានការរៀបចំឡើងនូវវិស័យដឹកជញ្ជូន ដែលផ្សាភ្ជាប់ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាផងដែល ដើម្បីឱ្យកាន់តែមានភាពល្អប្រសើរឡើងដូចជា៖

- ➢ សាងសង់ ស្ពានរំលង ថ្មើរជើងសម្រាប់ឆ្លងកាត់ផ្លូវ នៅទីតាំងដែលមានចរាចរណ៍ឆ្លងកាត់មមាញឹក

---

[៤៨] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី១៤

[៤៩] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី២០

[៥០] គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/ ដកស្រង់នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤

- កែលម្អបណ្ដាញផ្លូវមេសំខាន់ៗ និងសាងសង់ចំណតរថយន្តរៀបចំចិញ្ចើមផ្លូវ ថ្មើរជើង និងគន្លងផ្លូវទោចក្រយានយន្តសម្រាប់ សាធារណជន និងជនពិការភាព
- កែលម្អ សាងសង់ផ្លូវក្រវ៉ាត់រាជធានីនឹងបណ្ដាញផ្លូវនៅក្នុងខណ្ឌដើម្បីលើកកម្ពស់សណ្ដាប់ធ្នាប់ និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- រៀបចំមធ្យោយបាយដឹកជញ្ជូនសាធារណៈ ដែលមិនបំពុលបរិស្ថាន[៥១]
- ពង្រឹងសមត្ថភាពស្ថាប័ន សម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធិភាព
- កសាងប្រព័ន្ធដឹកជញ្ជូនសាធារណៈឆ្លាតវៃ
- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍ តាមបែបសមាហរណកម្ម
- ប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូន សន្សំសំចៃ និងមិនប៉ះពាល់ដល់បរិស្ថាន
- បង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ
- ប្រើប្រាស់គំនួសផ្លូវឆ្លាតវៃ ដោយលាយសារធាតុបារ៉ែត ២០ភាគរយជាមួយនឹងទឹកថ្នាំគំនូសផ្លូវ ដើម្បីមានចំណាំងផ្លាតភ្លឺ នៅក្នុងពេលធ្វើចរាចរណ៍នៅពេលយប់ បំពាក់អំពូលឆ្លាតនៅតាមដងផ្លូវ ដែលជាប្រភេទអំពូល ដែលមានការសន្សំសំចៃខ្ពស់នឹងគ្រប់គ្រងដោយស្វ័យប្រវត្តិ
- បំពាក់កាមេរ៉ាសុវត្ថិភាពនៅតាមដងផ្លូវក្នុងខណ្ឌដើម្បីត្រួតពិនិត្យចរាចរណ៍ ជាទូទៅនៅតាមដងផ្លូវ ក៏ដូចជានៅទីធ្លាសាធារណៈនានា ដើម្បីធានានូវសុវត្ថិភាព ជូនដល់ប្រជាជននឹងការបង្ក្រាបរាល់សកម្មភាពអវិជ្ជមានដែលកើតមានបានទាន់ពេលវេលា មានប្រសិទ្ធភាព និងពន្លឿនការស្រាវជ្រាវរកមុខសញ្ញានៃជនល្មើស ទៅលើករណីណាមួយដែលកើតមានឡើង។
- កសាងផ្លូវដឹកជញ្ជូនសាធារណៈ និងការផ្ដល់ព័ត៌មាននៃពេលវេលាមកដល់ ដោយបង្កើតប្រព័ន្ធព័ត៌មាន ទាន់ពេលវេលា នៃការដឹកជញ្ជូនសាធារណៈ ដល់អ្នកដំណើរដើម្បីផ្ដល់ការពិនិត្យព័ត៌មាននៃការធ្វើដំណើរមកដល់របស់រថយន្តសាធារណៈតាមទូរស័ព្ទដៃទំនើប។ [៥២]

---

[៥១] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី៦

[៥២] សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យ ឆ្នាំ២០៣៥, បោះពុម្ពឆ្នាំ២០២១, ទំព័រទី១៩

# ជំពូកទី២
# ការរៀបចំបរិស្ថាន
# នៅក្នុងខណ្ឌព្រែកព្នៅ

# ជំពូកទី២
# ការរៀបចំបរិស្ថាននៅខណ្ឌព្រែកព្នៅ

បរិស្ថាន គឺជាអ្វីៗដែលនៅជុំវិញខ្លួនយើង រាប់ទាំងភាវៈមានជីវិត (មនុស្ស សត្វ រុក្ខជាតិ) និងភាវៈគ្មានជីវិត (ទឹក ដី ខ្យល់ ផ្ទះ សាលារៀន សួនច្បារ)។ យើងដឹងហើយថា រាល់ការបំពុល បរិស្ថាន គឺជាបញ្ហាមួយដ៏សំខាន់ជាពិសេសទន្ទឹង និងការអភិវឌ្ឍ ច្បាស់ណាស់បញ្ហាផ្សេងៗទៀតនឹងកើតមាន ឡើងជាមួយគ្នាដែរ។ ហេតុដូចនេះហើយយើងទាំងអស់គ្នា ត្រូវតែចូលរួមដោះស្រាយដើម្បីកាត់បន្ថយការ បំពុលបរិស្ថាន និងថែរក្សាបរិស្ថាន ព្រោះការយល់ដឹងពីការបំពុលបរិស្ថានរបស់ប្រជាពលរដ្ឋមិនទាន់បានទូលំទូលាយនៅឡើយដែលវានឹងនាំឱ្យកើតជាបញ្ហាដល់យើងទាំងអស់គ្នា។ ហើយក្នុងចំណោមបញ្ហាទាំងអស់នោះ បរិស្ថាន គឺទទួលការគំរាមកំហែង និងផលប៉ះពាល់ខ្លាំងជាងគេ។ ជាក់ស្តែងនៅក្នុងការអភិវឌ្ឍ ជៀសមិនផុតនោះទេពីការបំពុល។ ដូចនេះឱ្យតែមានការអភិវឌ្ឍ គឺត្រូវតែមានការបំពុលនេះហើយទើបយើងត្រូវរកនូវវិធីធ្វើយ៉ាងណាដើម្បីដោះស្រាយរាល់បញ្ហាបំពុលទាំងនេះ។ ការបំពុលបរិស្ថានដែលយើងតែងតែជួបប្រទះរួមមាន ការបំពុលទឹក ដី ខ្យល់ សំណល់រឹងរាវ និងសំឡេង។ ដោយសារតែមានការបំពុលនេះហើយទើប រាជរដ្ឋាភិបាល កម្ពុជាបានខិតខំរិះរកគ្រប់មធ្យោបាយ ធ្វើយ៉ាងណាស្វែងរកនូវដំណោះស្រាយដើម្បីទប់ស្កាត់ បង្ការ ការពារ និងដាក់ចេញនូវវិធានការដោះស្រាយចំពោះបញ្ហាដែលកើតមានឡើងទៅលើបរិស្ថាននៃការរស់នៅប្រចាំថ្ងៃនេះ។

ជាក់ស្តែង ខណ្ឌព្រែកព្នៅក៏បានយកចិត្តទុកដាក់ទៅលើការរៀបចំបរិស្ថានជុំវិញខណ្ឌទាំងមូលផងដែរដើម្បីរក្សាសុខុមាលភាពសម្រាប់ប្រជាពលរដ្ឋនៅក្នុងដែនដីរបស់ខ្លួន ជាពិសេសចូលរួមសកម្មភាពជាច្រើនជាមួយវិស័យឯកជន ក្នុងនោះរួមមានៈ

❖ **សកម្មភាពពីការចូលរួមរបស់រដ្ឋបាលខណ្ឌព្រែកព្នៅ**

- បានចុះជម្រុញភ្នាក់ងារបរិស្ថានទាំង ០៥សង្កាត់បានចំនួន ១៨០លើក
- បានផ្ទុករកទីតាំងដែលប្រជាពលរដ្ឋ បញ្ចេញសំរាមក្នុងសង្កាត់ទាំង០៥បានចំនួន ៥០លើក
- បានចុះធ្វើការផ្សព្វផ្សាយដល់អាជីវកម្ម អាហារដ្ឋាន និងសិប្បកម្មបានចំនួន ៥៧លើក
- ចុះរុករកប្រភពបំពុលបរិស្ថាន ដែលកំពុងកើត និងពុំទាន់កើតបានចំនួន ៦០លើក
- បានចូលរួមជាមួយអាជ្ញាធរសង្កាត់ទាំង០៥ បានចំនួន ២៦លើក
- អប់រំផ្សព្វផ្សាយជូនប្រជាពលរដ្ឋទាំង ០៥សង្កាត់ពីការទុកដាក់សំរាម និងបញ្ចេញសំរាមបានចំនួន ៦៨៤គ្រួសារ

- ចុះណែនាំប្រជាពលរដ្ឋ ពីការទុកដាក់សំរាម បញ្ចេញសំរាមនៅតាមផ្ទះរៀងៗខ្លួនតាមដងផ្លូវជាតិលេខ៥មហាវិថីឈ្នះៈឈ្នះ ផ្លូវ១៥១ និងផ្លូវ២០១១ បានចំនួន ២០០គ្រួសារ
- ចុះពិនិត្យដេប៉ូសំរាម និងបានលុបបំបាត់ដេប៉ូសំរាមចំនួន ០៨ទីតាំង នៅក្នុងសង្កាត់គោករកាចំនួន ០៥ នៅក្នុងទីតាំង និងសង្កាត់ព្រែកព្នៅបានចំនួន ០៣ទីតាំង
- ចុះជម្រុញរោងចក្រ និងសិប្បកម្ម អំពីការទុកដាក់សំរាម បញ្ចេញសំរាមបានចំនួន ១០ទីតាំង
- បានចុះសហការជាមួយមន្ទីរបរិស្ថានដោះស្រាយពាក្យបណ្តឹងនឹងមេត្រីភាពបរិស្ថានបានចំនួន ០៧នៅក្នុងទីតាំង
- បានចូលរួមផ្សព្វផ្សាយស្តីពី ការកាត់បន្ថយការប្រើសំណល់ប្លាស្ទិកនៅតាមសាលារៀនបានចំនួន ០៨លើក។[៥៣]

❖ **ការចូលរួមរបស់ផ្នែកឯកជនជាមួយខណ្ឌព្រែកព្នៅ**

- ក្រុមហ៊ុនប្រមូលសំរាម៨០០ស៊ុបភើរ (Super) បានឧបត្ថម្ភធុងសំរាមបន្ថែមចំនួន ០៦ធុងសម្រាប់ដាក់នៅសាលាបឋមសិក្សាបឹងប្រិយ៍ សង្កាត់ពន្សាំង រាជធានីភ្នំពេញ
- ក្រុមហ៊ុនប្រមូលសំរាម៨០០ស៊ុបភើរ (Super) មានកម្មករបោសសំរាមតាមដងផ្លូវជាតិលេខ៥ និងមហាវិថីឈ្នះៈឈ្នះ ក្នុងខណ្ឌព្រែកព្នៅមានចំនួន ០៧នាក់
- ក្រុមហ៊ុនប្រមូលសំរាម៨០០ស៊ុបភើរ (Super) ដែលបានធ្វើការសហការជាមួយនឹងរដ្ឋបាលខណ្ឌបានដាក់ធុងសំរាមពង្រាយតាមទីតាំងសំខាន់ៗទាំង ០៥សង្កាត់ ក្នុងមូលដ្ឋានខណ្ឌព្រែកព្នៅបានចំនួន ៤០៥ធុងចំណុះ ២៤០លីត្រ។
- ការប្រមូលសំរាមរបស់ក្រុមហ៊ុន៨០០ស៊ុបភើរ (Super) ក្នុងសង្កាត់ទាំង០៥ ប្រមូលបាន១, ១៩៥ជើងប្រហែល ៦, ៨២៦តោន ដោយប្រើប្រាស់រថយន្តដែលផ្ទុកសំរាមបាន ០៨តោន មានចំនួន ០៣គ្រឿង និងដោយប្រើប្រាស់រថយន្តដែលផ្ទុកសំរាមបាន ០៥តោន ចំនួន ០២គ្រឿង
- ការប្រមូលសំរាមតាមរយៈក្រុមហ៊ុនដឹកសំរាមស៊ិនទ្រី កន្លងមកបានចំនួន ១, ៧២០ជើង និងដឹកតាមម៉ូតូកង់បី គឺបានចំនួន ៣៧៩ជើង។

[៥៣] របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌព្រែកព្នៅ ប្រចាំមាសទី១ ឆ្នាំ២០២៣, ទំព័រទី៨៤

## ២.១. ការបំពុលបរិស្ថាននៅខណ្ឌព្រែកព្នៅ

ការបំពុលជាការកែប្រែមជ្ឈដ្ឋានមានជីវិតដែលបង្កឱ្យមានគ្រោះថ្នាក់ដល់លំនឹងធម្មជាតិ សុខភាព ទៅលើភាវរស់ទាំងនោះ។ ជាទូទៅការបំពុលបណ្តាលមកពីសារធាតុគីមីបំពុលសំណល់ជាច្រើនលើសលប់ក្នុងខ្យល់ ទឹក ដី ការបំពុលសំណល់រឹង រាវ និងសំឡេងជាដើម។ បញ្ហាការបំពុលបរិស្ថាន គឺជាស្ថានភាពដែលគួរឱ្យបារម្ភនៅក្នុងខណ្ឌព្រែកព្នៅ ដោយអាជ្ញាធររដ្ឋបាលធ្វើការផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋគ្រប់រូប ឱ្យមានការយល់ដឹងពីប្រភពដែលនាំឱ្យកើតមានឡើងចំពោះការបំពុលទាំង ០៥ និងបានខិតខំប្រឹងប្រែងរកដំណោះស្រាយផ្សេងៗដើម្បីការពារបរិស្ថាន និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ជាពិសេសពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពរូបវ័ន្ត។ ការបំពុលបរិស្ថានទាំង០៥ មានដូចជា ការបំពុលទឹក ការបំពុលដី ការបំពុលសំណល់រឹង រាវ ការបំពុលខ្យល់ និងការបំពុលដោយសំឡេង។

### ២.១.១. ការបំពុលទឹក

ទឹកមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការទ្រទ្រង់ជីវិតប្រចាំថ្ងៃរបស់មនុស្ស សត្វ និងរុក្ខជាតិនៅលើផែនដី។ ហើយទឹកក៏បានដើរតួនាទី ជាផ្នែកមួយដែលសំខាន់ក្នុងការជួយជម្រុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសឱ្យមានភាពរីកចម្រើនលូតលាស់ដូចជា ក្នុងវិស័យឧស្សាហកម្ម កសិកម្ម គមនាគមន៍ ទេសចរណ៍ និងតំបន់ទីក្រុង។ តែបើប្រភពទឹកដ៏សំខាន់នោះទទួលរងនូវការបំពុល ឬបង្កនូវភាពល្អក់កករ ក៏វាជាបញ្ហាគំរាម ដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិដែលអាស្រ័យផលនឹងទឹកនោះផងដែរ។ ជាទូទៅ ក្នុងការបំពុលទឹក គឺជាការធ្វើឱ្យកង្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹក ដោយមិនត្រូវបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម (ដកយកសារធាតុបំពុលចេញ)។ នៅក្នុងប្រទេសកម្ពុជាយើងលទ្ធភាពទទួលបានទឹកស្អាត និងមានសុវត្ថិភាពនៅតែជាបញ្ហាដែលប្រឈមនៅឡើយ សម្រាប់គ្រួសារតាមទីជនបទ ពីព្រោះការផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធទឹកនានានៅមានកម្រិតនៅឡើយសម្រាប់តំបន់នៅក្រៅពីទីក្រុងធំៗ។[៥៤]

#### ២.១.១.១. មូលហេតុនៃការបំពុលទឹក

ការបំពុលទឹក គឺជាការធ្វើឱ្យកខ្វក់ដល់ទឹក នៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹក។ ការបំពុលទឹក គឺជាបញ្ហាប្រឈមដ៏ធំមួយដែលធ្វើឱ្យប៉ះពាល់ស្ទើរតែគ្រប់ប្រទេសទាំងអស់ ទូទាំងពិភពលោក។ ដូច្នេះ នៅពេលមានការបំពុលទឹកកើតឡើងវានឹងនាំមកនូវគ្រោះមហន្តរាយជាច្រើនយ៉ាង ហើយមូលហេតុនៃការបំពុលទឹកបណ្តាលមកពីៈ

[៥៤] គេហទំព័រ https://opendevelopmentcambodia ដកស្រង់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

- **ការគ្រប់គ្រងសំណល់មិនបានល្អ** គ្មានការវេចខ្ចប់សំរាមឱ្យបានល្អត្រឹមត្រូវធ្វើឱ្យសំណល់ខ្លះហើរចូលទៅប្រភពទឹក។
- **ការគ្រប់គ្រងប្រព័ន្ធទឹកកង្វក់មិនបានល្អ** ភាគច្រើនចេញពីប្រភពរោងចក្រ សហគ្រាស សិប្បកម្មកែច្នៃជាដើម ដែលមិនប្រើប្រាស់ម៉ាស៊ីនចម្រុះទឹកឱ្យបានត្រឹមត្រូវ មុនបង្ហូរចូលក្នុងលូសាធារណៈ។
- **ការបំពុលដោយសកម្មភាពកសិកម្ម** ដែលប្រជាពលរដ្ឋប្រើប្រាស់ថ្នាំគីមី សម្រាប់សម្លាប់សត្វល្អិត ថ្នាំសម្រាប់ដំណាំឆាប់ចេញផលជាដើម ដែលបានបង្ហូរចូលប្រភពទឹក។
- **ការលេចធ្លាយប្រេងឆៅ** ពីនាវា កប៉ាល់ ដែលធ្វើឱ្យមានការហូរប្រេងចូលទៅក្នុងសមុទ្រ ឬទន្លេបង្កឱ្យមានផលប៉ះពាល់ដល់ជីវិតនៅក្នុងទឹក។
- **កាកសំណល់ពីលំនៅឋាន និងទីផ្សារ** ដែលយកសំរាមទៅចាក់ចោលក្នុងលូទឹកសម្អុយដែលគ្មានការចូលរួមសម្អាតបរិស្ថានត្រឹមត្រូវ ទៅតាមវិធានការក្រសួងបរិស្ថាន។
- **សកម្មភាពពីភ្ញៀវទេសចរ** ដែលមកកម្សាន្តលេងនៅកន្លែងទេសចរណ៍មានការចោលសំរាមពាសវាលពាសកាល រាយប៉ាយ។
- **គ្មានវិធានការចំពោះប្រជាពលរដ្ឋ** ដែលមិនបានចូលរួមក្នុងការប្រើប្រាស់បង្គន់អនាម័យឱ្យបានត្រឹមត្រូវបន្ទោរបង់នៅតាមទីវាល ឬបន្ទោរបង់ចូលទៅក្នុងទឹក ដែលនាំឱ្យបំពុលទឹក។[៥៥]
- **កត្តាធម្មជាតិ** ការបំពុលទឹក គឺមានការចូលនូវបាតុភូតធម្មជាតិផងដែររួមមានគ្រោះទឹកជំនន់ដែលនៅពេលមានទឹកជំនន់ម្តងៗ ទឹកបានគួចយកទៅសំរាម កាកសំណល់ដែលមានថង់ប្លាស្ទិក កំប៉ុង ដប សំណល់ពីសំណង់ ផ្សេងៗដែលមានសភាពរាយប៉ាយទៅតាមដងផ្លូវ ទន្លេ សមុទ្រ បឹង ព្រែកជាដើម។ ម្យ៉ាងទៀតពាក់ព័ន្ធនឹងភ្លៀងអាស៊ីត នៅពេលមានភ្លៀងធ្លាក់វានឹងនាំមកនូវឧស្ម័នការបូនឌីអុកស៊ីតដែលវាមានកម្រិតជាតិអាស៊ីត ហើយនៅពេលដែលវាធ្លាក់ចូលក្នុងបរិយាកាសប៉ះទង្គិចជាមួយ និងថាមពលឥន្ធនៈផូស៊ីលវានឹងធ្វើឱ្យប៉ះពាល់ដល់ការបំពុលទឹកដែលបានហូរចូលទៅក្នុង បឹងបួរ ទន្លេ សមុទ្រ ព្រែកជាដើម។[៥៦]

---

[៥៥] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៥០

[៥៦] គេហទំព័រ ក្រសួងបរិស្ថាន https://www.moe.gov.kh/index/1894 ដកស្រង់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

#### ២.១.១.២. ផលវិបាកនៃការបំពុលទឹក

ការបំពុលទឹក គឺមានផលអវិជ្ជមានយ៉ាងខ្លាំងទៅលើបរិស្ថាន និងសុខភាពរបស់មនុស្ស សត្វ រុក្ខជាតិ ដែលប្រទេសមួយចំនួននៅលើពិភពលោកតែងតែបារម្ភ និងយកចិត្តទុកដាក់ខ្លាំងជានិច្ច។ ជាក់ស្តែងទូទាំងពិភពលោកមានមនុស្សប្រមាណជាង ៣ពាន់លាននាក់ កំពុងប្រឈមមុខនឹងជំងឺដោយសារតែគុណភាពទឹកដែលមានប្រភពមកពីទន្លេ បឹង ព្រែក និងទឹកក្រោមដី។ ទន្ទឹមនឹងនេះអាងទន្លេមួយភាគប្រាំរបស់ពិភពលោកកំពុងមានការប្រែប្រួលយ៉ាងខ្លាំងដែលជួបប្រទះនឹងការកង្វះទឹកស្អាត សម្រាប់មនុស្សប្រមាណ ២.៣ពាន់លាននាក់ដែលរស់នៅក្នុងប្រទេស ហើយត្រូវបានគេចាត់ចូលនៅក្នុងថ្នាក់ដែលមានភាពតានតឹងនៅលើតម្រូវការទឹកប្រើប្រាស់រួមទាំង ៧២១លាននាក់នៅក្នុងតំបន់ដែលជួបនឹងស្ថានភាពទឹកធ្ងន់ធ្ងរផងដែរ។[៥៧]

ងាកមកមើល ប្រទេសកម្ពុជាយើងវិញកំណើននៃប្រជាជនមានការកើនឡើងជាលំដាប់ដែលធ្វើឱ្យមានកំណើនក្នុងការប្រើប្រាស់ទឹកកាន់តែច្រើនឡើងទៅតាមតម្រូវការបរិភោគ ការងូតទឹក ប្រើប្រាស់ក្នុងផ្ទះបាយ និងតម្រូវការជាប្រចាំថ្ងៃ ការធ្វើកសិកម្ម ស្រោចស្រពដំណាំ ស្រែចំការ ចិញ្ចឹមសត្វ ជាដើម។ ពេលមានបញ្ហានៃការបំពុលទឹកកើតមានឡើងធ្វើឱ្យមនុស្សទទួលរងការឆ្លងជំងឺដូចជា ជំងឺរលាកថ្លើម រាគរូស ខូចតម្រងនោម ជំងឺបែបសើស្បែក គ្រុនពោះវៀន អាសន្នរោគ ដោយសារការទទួលទានទឹកគ្មានអនាម័យ មានសារធាតុគីមី ហើយវាអាចធ្វើឱ្យឈានដល់ការបាត់បង់ជីវិតទៀតផង។ ម្យ៉ាងទៀតការបំពុលទឹក វាពិតជាមានហានិភ័យខ្ពស់ ទៅលើការប៉ះពាល់ដល់វិស័យសំខាន់ៗនៅក្នុងប្រទេសកម្ពុជា មានវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងសិប្បកម្ម និងវិស័យទេសចរណ៍ថែមទៀតផងដែរ។

### ២.១.២. ការបំពុលដី

ការបំពុលដី គឺជាការធ្វើដីខូចបាត់បង់នូវជីវជាតិ និងបណ្តាលឱ្យមនុស្ស សត្វ និងរុក្ខជាតិពិបាករស់រានមានជីវិត ឬក៏ឈានដល់ការបាត់បង់ជីវិតក៏មាន។ ការបំពុលដី ក៏អាចបណ្តាលមកពីការកើនឡើងនៃកំណើនរបស់ប្រជាជនជាខ្លាំងដែលបានជះឥទ្ធិពលអាក្រក់ដល់ការបំពុលដី។

#### ២.១.២.១. មូលហេតុនៃការបំពុលដី

ដីជាប្រភពអាហារសំខាន់ដែលផ្តល់ធនធានស្បៀងដល់ពី ៩៥ទៅ ៩៧ភាគរយ សម្រាប់ប្រជាជនដែលរស់នៅលើពិភពលោក។ ផ្ទៃដីនៃធនធានដីរបស់ពិភពលោក គឺមាន ១២៩ លានគីឡូម៉ែត្រការ៉េ ឬ៨៦,៥ភាគរយនៃផ្ទៃដី។ ដីបង្កបង្កើនផល និងចម្ការដែលមានអាយុច្រើនឆ្នាំជាផ្នែកនៃដីកសិកម្មកាន់កាប់ប្រហែល ១០ភាគរយ

[៥៧] គេហទំព័រ អង្គការបរិស្ថានពិភពលោក https://www.unep.org/ ដកស្រង់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

នៃដីវាលស្មៅ និងវាលស្មៅ ២៥ភាគរយនៃផ្ទៃដី។ ជាអកុសល ដោយសារតែការធ្វើអាជីវកម្មមិនបានត្រឹមត្រូវ ដីមានជីជាតិមួយចំនួនត្រូវបាត់បង់ជារៀងរាល់ឆ្នាំ។ ដូច្នេះសម្រាប់សតវត្សទីចុងក្រោយ ជាលទ្ធផលនៃការកើនឡើងនៃសំណឹកដី ដី គឺមានជីជាតិចំនួន ២ពាន់លានហិកតាត្រូវបានបាត់បង់ដែលស្មើនឹង ២៧ភាគរយនៃផ្ទៃដីសរុប និងផ្ទៃដីប្រើប្រាស់សម្រាប់ធ្វើកសិកម្ម។[៥៨] ដូច្នេះហើយ នៅពេលមានការបំពុលដីកាន់តែខ្លាំងឡើង គឺត្រូវតែចូលរួមរកដំណោះស្រាយ អំពីមូលហេតុដែលនាំឱ្យមានការបំពុល។

- **មូលហេតុនៃការបំពុលដីរួមមានៈ**
  - **កំណើនកើនឡើងនៃសំណង់** មានលំនៅឋាន សហគ្រាស សិប្បកម្ម ដែលនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃមានកំណើនរីកដុះដាល ទាំងសំណង់ខ្ពស់ ទាប តូច ធំលើផ្ទៃដី ជាពិសេសឧស្សាហកម្មធន់ធ្ងន់ដែលមានលោហៈធាតុ ក្រដាស ថង់ប្លាស្ទិកជាដើម ដែលនាំឱ្យប៉ះពាល់ដល់បរិស្ថាន។
  - **ការបំពុលដោយការធ្វើកសិកម្ម** ប្រជាពលរដ្ឋមួយចំនួនធ្វើស្រែចំការ ដាំដំណាំផ្លែឈើនានា ដើម្បីឱ្យមានផលល្អលូតលាស់ឆាប់រហ័សបានប្រើប្រាស់នូវថ្នាំសម្លាប់សត្វល្អិតហួសកម្រិត បាញ់ថ្នាំគីមី និងបានដាក់ជីគីមីធ្វើឱ្យខូចដល់ស្រទាប់ដី ដីរងសំណឹក បាត់បង់ជីវជាតិខ្សោះជាតិទឹក។
  - **ការបំពុលដោយសំណល់** សំណល់មានដូចជា ថង់ប្លាស្ទិក កំប៉ុងជ័រ ក្រដាសការតុង សំណល់ចេញពីមន្ទីរពេទ្យ សំណល់សរីរាង្គពីសំបកកង់ឡាន កង់ម៉ូតូ ចោលទៅលើដីដែលធ្វើឱ្យបរិស្ថានបាត់បង់នូវសោភ័ណភាព។
  - **ការជីកយករ៉ែ** ការជីកយករ៉ែពីក្រោមដីដល់ស្រទាប់ជ្រៅធ្វើឱ្យដីរងសំណឹក មិនអាចដាំដុះកសិកម្មបាន។
  - **ការចិញ្ចឹមសត្វ** ដូចជាសត្វជ្រូក គោ សេះ ដែលធ្វើឱ្យបំពុលដីដោយសារ លាមក ទឹកនោមដែលធ្វើឱ្យមានក្លិនសម្អុយ បំផ្លាញបរិស្ថាន។ល។
  - **កត្តាប្រជាពលរដ្ឋ** ប្រជាពលរដ្ឋមួយចំនួន គឺមិនទាន់យល់ច្បាស់ពីការបែងចែកប្រភេទសំរាមទៅតាមពណ៌ធុងសំរាមដូចជា ធុងសំរាមពណ៌បៃតងម្រាប់ប្រភេទសំណល់សរីរាង្គ ផ្ទះបាយ ធុងសំរាមពណ៌ទឹកក្រូច គឺសម្រាប់ដាក់នូវសំណល់ប្លាស្ទិក និងធុងសំរាមពណ៌ក្រហមសម្រាប់ផ្ទុកសំណល់គ្រោះថ្នាក់។[៥៩]

[៥៨] គេហទំព័រ https://studyboom.ru/km/zagryaznenie-i-istoshchenie ដកស្រង់នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤

[៥៩] គេហទំព័រ ក្រសួងបរិស្ថាន https://www.moe.gov.kh/index/22766 ដកស្រង់នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤

#### ២.១.២.២. ផលវិបាកនៃការបំពុលដី

ការបំពុលដី គឺមានផលវិបាកយ៉ាងខ្លាំងកើតចេញពីការសកម្មភាពដូចជាការធ្វើកសិកម្ម ការបំពុលដោយសំណល់ អាជីវកម្ម ឬសំណល់ចេញពីកសិដ្ឋានចិញ្ចឹមសត្វ ការគ្រប់គ្រងសំណល់មិនបានល្អនាំឱ្យបន្សល់នូវគុណវិបត្តិនៃការបំពុលដីមានដូចជា៖

- ធ្វើឱ្យដីទទួលរងនូវសំណឹក មានការបាត់បង់នូវសារធាតុចិញ្ចឹមនៅក្នុងដី
- មានការបាត់បង់នូវជីវចម្រុះនៅលើដី ធនធានធម្មជាតិ
- មានវិបត្តិស្បៀងអាហារដោយសារតែពិបាកក្នុងការធ្វើកសិកម្ម
- មានការកើនឡើង នៃវិបត្តិគ្រោះមហន្តរាយនៃធម្មជាតិ។

### ២.១.៣. ការបំពុលខ្យល់

ខ្យល់ ត្រូវបានបំពុលពេលវាប៉ះពាល់ទៅនឹងភាពកខ្វក់នៃឧស្ម័នពុល និងភាគល្អិតតូចៗដែលត្រូវបានបញ្ចេញដោយរោងចក្រឧស្សាហកម្ម មធ្យោបាយដឹកជញ្ជូនទៅក្នុងបរិយាកាសខាងក្រៅ។ ការបំពុលខ្យល់ គឺជាបញ្ហាគ្រោះថ្នាក់មួយដែលខ្យល់មិនបរិសុទ្ធ និងមាននូវសារធាតុពុលគំរាមកំហែងទៅដល់ជីវិតមនុស្ស។ ជាទូទៅការបំពុលខ្យល់មានសភាពធ្ងន់ធ្ងរនៅក្នុងទីក្រុង តំបន់ឧស្សាហកម្ម តំបន់ទំនាប និងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សនៅទីក្រុងដូចជា ផ្សែងដែលចេញពីយានយន្ត ទោចក្រយានយន្ត ឬរោងចក្រ សហគ្រាស សិប្បកម្ម អាហាដ្ឋាន ដុតសំរាម និងការដុតថាមពលឥន្ធនៈជាដើម។ល។ តាមរយៈការបំពុលខ្យល់មានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងចំពោះសុខភាពសាធារណៈ បរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច។

#### ២.១.៣.១. មូលហេតុនៃការបំពុលខ្យល់

ការបំពុលខ្យល់ កើតឡើងនៅពេលសារធាតុប្រកបដោយគ្រោះថ្នាក់ (សារធាតុពុល) គឺត្រូវបានបញ្ចេញទៅក្នុងខ្យល់នៅក្នុង ឬនៅក្រៅផ្ទះរបស់យើង។ ការបំពុលខ្យល់មិនត្រឹមតែបំផ្លាញអាកាសធាតុ បរិស្ថានទេ ជាពិសេសអាចប៉ះពាល់ទៅដល់រាងកាយ និងសុខភាពរបស់មនុស្ស ទៀតផងដែរ ហើយកត្តាដែលនាំឱ្យមានការបំពុលខ្យល់រួមមាន៖

- **ការប្រើប្រាស់រថយន្ត និងយានយន្តចាស់ៗ** ដែលពុំបានថែទាំបានល្អ ធ្វើឱ្យមានការសាយភាយនូវឧស្ម័នចេញពីបំពង់ស៊ីមាំង ទៅបរិយាកាស ដែលបណ្តាលឱ្យមានផ្សែងពុលទៅក្នុងបរិយាកាស

- **ការប្រើប្រាស់ជីគីមី** ការបាញ់ថ្នាំប្រភេទគីមីនៅលើដំណាំអាចនឹងប៉ះពាល់យ៉ាងខ្លាំងទៅលើខ្យល់ព្រមទាំងបរិយាកាស ព្រោះការបំភាយសារធាតុគីមី មានប្រតិកម្មជាមួយអុកស៊ីសែន ដែលជាតម្រូវការចាំបាច់សម្រាប់ជីវិតមនុស្ស និងសត្វ។ ករណីមាននូវការប្រតិកម្មរវាងអង្គធាតុគីមី ទៅនឹងអុកស៊ីសែនធ្វើឱ្យសារធាតុអុកស៊ីសែនក្នុងបរិយាកាសថយចុះ និងប្រែប្រួល។ រីឯខ្យល់ត្រូវទទួលរងការបំពុលហើយថែមទាំងប៉ះពាល់ដល់ស្រទាប់អូសូនថែមទៀតផង។ [៦០]
- **កាកសំណល់** កាកសំណល់ដែលស្អុយរលួយដែលចេញពីផ្ទះបាយ ភោជនីយដ្ឋាន អាហារដ្ឋាន និងសិប្បកម្មកែច្នៃ ដែលចោលគ្មានរបៀបរៀបរយ បានសាយភាយក្លិនចូលទៅក្នុងបរិយាកាស។
- **ការបំភាយឧស្ម័ន** សំដៅទៅលើរោងចក្រ សហគ្រាស ដែលដំណើរការដោយថាមពលឧស្ម័ន ដែលបង្ហុយតាមបំពង់ផ្សែងខ្មៅពាសពេញបរិយាកាស។
- **ការដុតបំផ្លាញព្រៃឈើ** ការដុតបំផ្លាញព្រៃឈើ ឬវាលស្មៅធ្វើឱ្យមានការបំផ្លាញដល់ស្រទាប់អូសូនស្តើង ដោយសារចំហាយនៃឧស្ម័នហើរពាសពេញផ្ទៃមេឃ។
- **ប្រែប្រួលអាកាសធាតុ** ចំហេះឥន្ធនៈដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឱ្យមានការប្រែប្រួលនូវអាកាសធាតុ ដែលបង្កផលប៉ះពាល់ទៅដល់ការផ្គត់ផ្គង់អាហារ ខ្យល់ ទឹក និងបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់សុខភាពមនុស្ស។

### ២.១.៣.២. ផលវិបាកនៃការបំពុលខ្យល់

ការបំពុលខ្យល់កើតឡើង នៅពេលដែលសារធាតុប្រកបដោយគ្រោះថ្នាក់ត្រូវបានបញ្ចេញទៅក្នុងខ្យល់នៅមជ្ឈដ្ឋានជុំវិញខ្លួនយើង។ ការបំពុលខ្យល់ បានផ្តល់ផលប៉ះពាល់ជាច្រើនដល់សុខភាពមនុស្ស និងធម្មជាតិ ដែលមានដូចជា៖

- **ប៉ះពាល់ដល់សុខភាព** សារធាតុពុលនៅក្នុងខ្យល់ គឺអាចប៉ះពាល់ដល់សុខភាពមនុស្ស ដូចជាសួត និងប្រព័ន្ធឈាមរបស់យើងដែលបង្កើនហានិភ័យ ចំពោះជំងឺបេះដូង ជំងឺផ្លូវដង្ហើម និងជំងឺមហារីកសួត ក្រហាយភ្នែក ឈឺក្បាល អស់កម្លាំង អាលាក់ហ្ស៊ី ឬដង្ហើមខ្លី។[៦១] នៅក្នុងករណី

[៦០] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៤៨

[៦១] គេហទំព័រ អង្គការមូលនិធិកុមារនៅកម្ពុជា របស់អង្គការសហប្រជាជាតិ https://www.unicef.org/cambodia/ ដកស្រង់នៅថ្ងៃ២៧ ខែមេសា ឆ្នាំ២០២៤

ដែលយើង បានស្រូបយកខ្យល់ពុលក្នុងរយៈពេលវែង ជាហេតុបង្កឱ្យយើង ប៉ះពាល់ខួរក្បាល និង បន្ថយសមត្ថភាពក្នុងការចងចាំផងដែរ។[៦២]

- **ការប្រែប្រួលអាកាសធាតុ** សព្វថ្ងៃនេះកំណើនរោងចក្រ សហគ្រាស និងកំណើនប្រជាជនកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ គឺបានបំផ្លាញ ដើមឈើដែលយកទៅធ្វើលំនៅឋាន ការដុតសំរាម ដុតឥន្ទនៈផូស៊ីល និងយកដីដុតធ្វើកសិកម្មបានបង្កជាមូលហេតុនាំឱ្យមានការសាយភាយឧស្ម័នពុលពាសពេញផ្ទៃបរិយាកាសនឹងធ្វើឱ្យស្រទាប់អូសូនកាន់តែស្តើងឡើងៗនាំឱ្យមានបម្រែបម្រួលអាកាសធាតុទូទាំងសកលលោក ជាពិសេស បង្កើននូវលកកម្តៅព្រះអាទិត្យ ខ្សត់ទឹកភ្លៀង នាំឱ្យមានការឆេះព្រៃ និងបណ្តាលឱ្យរុក្ខជាតិងាប់។[៦៣]

## ២.១.៤. ការបំពុលសំណល់រឹង រាវ

ការបំពុលដោយសំណល់រឹង រាវ គឺជាការបំពុលបរិស្ថានមួយដែលជះឥទ្ធិពលមកលើផែនដីយើងសព្វថ្ងៃនេះដែលបណ្តាលមកពីកត្តាមនុស្ស គឺមិនបានរៀបចំ ឬបែងចែកសំណល់រឹង ឬសំណល់រាវ ឱ្យបានត្រឹមត្រូវជាហេតុនាំឱ្យមានការបំពុលទៅដល់បរិស្ថាន។ ជារៀងរាល់ថ្ងៃសំណល់ដែលកើតចេញមកពីលំនៅឋាន អគារសាធារណៈ រោងចក្រ ផ្សារ សណ្ឋាគារ អគារពាណិជ្ជកម្ម ភោជនីយដ្ឋាន កន្លែងកម្សាន្ត មិនថាសំណល់រឹង ឬសំណល់រាវទេវាបង្កគ្រោះថ្នាក់ដល់ភាវៈរស់ទាំងអស់មិនថា មនុស្ស សត្វ ឬរុក្ខជាតិ តែងតែទទួលរងឥទ្ធិពលពីប្រភពបំពុល សំណល់ទាំងអស់នេះ។

### ២.១.៤.១. មូលហេតុនៃការបំពុលសំណល់រឹង រាវ

**សំណល់រឹង** គឺសំដៅទៅលើសម្រាមជាវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កម្ទេចកម្ទីរឹង ដែលគេលែងត្រូវការប្រើប្រាស់ ហើយត្រូវបានគេបោះបង់ចោលមានបំណងនឹងបោះចោល ឬតម្រូវឱ្យបោះបង់ចោល។ នៅក្នុងចំណុចសំណល់រឹង ជាចំណុចសំខាន់ក្នុងការថែរក្សាបរិស្ថាន។[៦៤] សំណល់រឹងចែកចេញជា ០២រួមមាន

- **សំរាម** ជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ដែលបញ្ចេញដោយរោងចក្រ សណ្ឋាគារ ទីផ្សារ អគាពាណិជ្ជកម្ម ភោជនីយដ្ឋាន លំនៅឋាន និងកន្លែងកម្សាន្ត។

[៦២] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៥០

[៦៣] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៥០

[៦៤] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អនក្រ.បក, ចុះនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨, មាត្រា៣

- **សំណល់ប្រកបដោយគ្រោះថ្នាក់** សំដៅដល់ធាតុវិទ្យុសកម្មដែលអាចចម្លងជំងឺ ឆេះ រលាក និង រងការធ្វើអុកស៊ីតកម្ម ឬសាធាតុគីមីផ្សេងៗដែលបង្កគ្រោះថ្នាក់។[៦៥]

**សំណល់រាវ** គឺសំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថាន ដែលបញ្ចេញពីសកម្មភាព ឬ ដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។[៦៦] ឬម្យ៉ាងទៀតសំណល់រាវ គឺជាវត្ថុរាវ ដែលជា ផលិតផល និងជាសារធាតុរួមផ្សំ ជាមួយនឹងសារធាតុរឹងខ្លះដែលត្រូវបានគេបញ្ចេញចោលជាប្រចាំទៅ តាមបណ្តាញប្រព័ន្ធ លូទឹកស្អុយផ្សេងៗ។[៦៧] សំណល់រាវនេះត្រូវបានបែងចែកចេញជាពីរប្រភពគឺ ប្រភព បំពុលរាយប៉ាយ និងប្រភព បំពុលចំណុច។

- **ប្រភពបំពុលរាយប៉ាយ** គឺជាប្រភពដែលបង្កឱ្យមានការបំពុលដោយសារ សារធាតុបំពុលពីដី ច្រើនកន្លែងដូចជា លំហូរកសិកម្ម សំណល់ចេញពីលំនៅដ្ឋាន សំណល់អាជីវកម្មរ៉ែ និង កំទេចកម្ទីពីការដ្ឋានសំណង់ជាដើមហើយសំណល់ទាំងនេះហូរធ្លាក់ចូលទៅក្នុងទឹកលើផ្ទៃដីនៃ តំបន់ដ៏ធំមួយ ហើយមិនងាយស្រួលក្នុងការត្រួតពិនិត្យ វាអាស្រ័យទៅលើការយល់ដឹងរបស់ បុគ្គល គ្រួសារ និងសហគមន៍។
- **ប្រភពបំពុលចំណុច** គឺជាប្រពភដែលកើតចេញពីកន្លែងច្បាស់លាស់តាមរយៈបំពង់បង្ហូរ ឬប្រឡាយ ទីតាំងឧស្សាហកម្ម រោងចក្រ និងបំពង់បង្ហូរទឹកលូសម្អុយ ហើយងាយស្រួលក្នុង ការត្រួតពិនិត្យ និងធ្វើប្រត្តិកម្មសំអាតទឹកឡើងវិញ។[៦៨]

❖ **ការបំពុលសំណល់រឹង**

ចំនួនប្រជាជននៅលើពិភពលោកសព្វថ្ងៃមានកំណើនកើនឡើងគួរឱ្យកត់សម្គាល់ ដែលប្រទេសនីមួយៗ តែងតែយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍដើម្បីបំពេញតម្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ទាក់ទងនិង ការអភិវឌ្ឍវិស័យសំណង់ វិស័យឧស្សាហកម្ម និងវិស័យកសិកម្ម ដែលនេះជាហេតុនាំឱ្យមានកាកសំណល់ច្រើន សន្ធឹក។ កាកសំណល់រឹងភាគច្រើនមានប្រភពចេញពី៖

---

[៦៥] អនុក្រឹត្យលេខ ៣៦ អនក្រ.បក, ចុះនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨, មាត្រា៣

[៦៦] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងលូ និងប្រព័ន្ធទឹកកខ្វក់, លេខ ២៣៥ អនក្រ.បក, ចុះនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

[៦៧] គេហទំព័រ https://seylanote.wordpress.com/?s ដកស្រង់នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២៤

[៦៨] គេហទំព័រ https://www.khsearch.com/qna/8874 ដកស្រង់នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២៤

- **រោងចក្រសិប្បកម្ម** ជាសំណល់ផលិតកម្មដែលភាគច្រើនជាសំណល់គ្រោះថ្នាក់ដែលមានដូចជា សសៃអំបោះ កម្ទេចកំណាត់ ដែលចេញពីការឆេះក្នុងឡឧស្សាហកម្ម
- **មន្ទីរពេទ្យ** សំណល់ស្ងួតដែលមាន ស៊ីរ៉ាំង បង់រុំរបួស អាលុយមីញ៉ូម ប្លាស្ទិក ដែលមានមេរោគជាច្រើន
- **សំណល់ពីអគារពាណិជ្ជកម្ម** មានដូចជា ក្រដាស សម្ភារៈក្នុងការិយាល័យ និងប្រភេទឧបករណ៍អេឡិចត្រូនិច។
- **សំណល់ពីសំណង់** ជាគុណវិបត្តិរបស់ប្រទេសកំពុងអភិវឌ្ឍន៍ជាងគេ ពីព្រោះវាតែងតែរីកដុះដាលជារៀងរាល់ថ្ងៃពីព្រោះវាបានបង្កឱ្យមានសំឡេងរំខាន កកស្ទះចរាចរណ៍ ដែលមានស៊ីម៉ងត៍ ដែកថង់ប្លាស្ទិក និងថ្នាំពណ៌។
- **សំណល់ចេញពីផ្ទះបាយ** សំណល់ផ្ទះបាយភាគច្រើនជាសំណល់សើមមានដូចជាបាយ ត្រី សាច់ ផ្លែឈើ បន្លែ និងសំណល់ផ្សេងៗដែលទ្រទ្រង់គ្រឿងឧបភោគបរិភោគ។ សំណល់ទាំងនេះ គឺមានប្រភពចេញពីអាហារដ្ឋាន ភោជនីយដ្ឋាន តំបន់ ទេសចរណ៍ បៀហ្គាឌិនជាដើម។ល។[៦៩]

❖ **ការបំពុលសំណល់រាវ**

ក្នុងជីវភាពប្រចាំថ្ងៃ មនុស្សយើងពិតជាត្រូវការទឹកជាចាំបាច់ខ្លាំងណាស់ សម្រាប់យកមកប្រើប្រាស់ និងបរិភោគ។ ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃយើងបានធ្វើឱ្យទឹកកាន់តឹកខ្វក់ឡើងៗ ដែលបានធ្វើសកម្មភាពបំពុលទឹក ដូចជា៖

- **រោងចក្រ សិប្បកម្ម សហគ្រាស** បង្ហូរសំណល់រាវចូលទៅប្រព័ន្ធលូសាធារណៈ ប្រឡាយ បឹងដែលធ្វើឱ្យមានក្លិនសម្អុយ ដោយគ្មានការធ្វើប្រព្រឹត្តកម្ម។
- **ទីផ្សារ និងគេហដ្ឋាន** ប្រជាពលរដ្ឋមួយចំនួន ធ្វើការសាងសង់បង្គន់អនាម័យ ដោយបង្ហូរចូលទៅក្នុងលូសាធារណៈ។

[៦៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៥៣

#### ២.១.៤.២. ផលវិបាកនៃសំណល់រឹង រាវ

ផលវិបាកនៃសំណល់រឹង រាវ គឺបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរស់នៅប្រចាំថ្ងៃដែលបង្កជាគុណវិបត្តិទៅដល់បរិស្ថានសង្គម និងប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋជាច្រើនរួមមាន៖

❖ **ប៉ះពាល់លើសុខភាពសាធារណៈ**

➢ **ប៉ះពាល់ដល់ផ្លូវដង្ហើម** ការទុកដាក់ និងការរិចខ្ចប់សំរាមមិនបានល្អធ្វើឱ្យមានក្លិនស្អុយសាយភាយ និង សំរាមហើរទៅជាធូលី ហើយបង្កជាបំពុលខ្យល់ទៀតនាំឱ្យមានបញ្ហាផ្លូវដង្ហើមកើតជំងឺស្បែក មេរោគដែលបង្កមកពីសំរាម បាននៅពេញបរិយាកាស ហើយហើរទៅប៉ះនឹងស្បែក ជាទូទៅ វានឹងបង្កជាជំងឺរមាស់ ពងបែក អាលែកហ្ស៊ីស្បែក ជាដើម។

➢ **ជំងឺភ្នែក** ធូលីដី និងមេរោគក្នុងបរិយាកាស ជាច្រើនដែលមាននៅក្នុងគ្រប់ទីកន្លែង រួចហើរចូលទៅក្នុងកែវភ្នែករបស់យើងគ្រប់គ្នាដែលអាចបង្កជាជំងឺភ្នែកក្រហម ឬផ្សាភ្នែក។

➢ **ជំងឺរលាកផ្លូវរំលាយអាហារ និងជំងឺរលាកសួត** មេរោគនឹងសារធាតុគីមីនៅក្នុងសំណល់រាវមួយចំនួន ក៏អាចបង្កឱ្យកើតជំងឺមហារីកបានដែរ។

❖ **ប៉ះពាល់លើគុណភាពបរិស្ថាន**

➢ **គ្រប់គ្រងសំណល់មិនបានល្អ** បង្កឱ្យមានសំរាមតាមដងផ្លូវសាធារណៈ ស្ទះលូសាធារណៈជាដើម

➢ **ប៉ះពាល់ដល់ទៅដល់សោភ័ណភាពជីវចម្រុះ** ដូចជាប្រព័ន្ធអេកូឡូស៊ីបៃតង និងការលូតលាស់របស់រុក្ខជាតិខ្សោយជាងមុន។

### ២.១.៥. ការបំពុលសំឡេង

សំឡេង គឺតែងតែស្ថិតនៅជុំវិញមជ្ឈដ្ឋានខ្លួនរបស់យើងគ្រប់ៗគ្នា។ នៅពេលដែលមានការបំពុលសំឡេងកើតឡើង វាពិតជាប៉ះពាល់ដល់សកម្មភាពរបស់យើងជាច្រើនទាំងការរស់នៅ ការសិក្សារៀនសូត្រ និងការប្រកបអាជីវកម្មផងដែរ។ បើយោងតាមមូលហេតុនៃការបំពុលសំឡេងនេះ គឺមកពីប្រភពធំៗចំនួនពីរយ៉ាងគឺ ប្រភពចល័ត នឹងប្រភពអចល័ត។

### ២.១.៥.១. មូលហេតុនៃការបំពុលសំឡេង

សំឡេងត្រូវបានក្លាយជាផ្នែកធម្មជាតិមួយ នៃជីវិតប្រចាំថ្ងៃរបស់យើងម្នាក់ៗ។ ដូច្នេះនៅពេលមានការបំពុលសំឡេង មាននៅជិតយើងម្នាក់ៗវា និងបង្កឱ្យមានផលវិបាកចំពោះផ្នែកមួយចំនួននៃរាង្គកាយ។ ដូច្នេះ យើងគួរតែដឹងពីមូលហេតុនាំឱ្យកើតមាននៃកាបំពុលសំឡេង។ នៅក្នុងមូលហេតុនៃការបំពុលសំឡេង៖

- **ការបំពុលពីប្រភពចល័ត** គឺសំដៅដល់ប្រភពនៃការបំពុលដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍ជាអាទិ៍ មាន យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងបំពងសំឡេង ឧបករណ៍ឃោសនាសព្ទ ដែលមាននៅតាមវិធីបុណ្យ ពិធីការ ពិធីខួបកំណើត ជប់លៀង និងស៊ីផ្លេចេញពីរថយន្ត ម៉ូតូ ស៊ីផ្លេរថភ្លើង ឡានក្រុងជាដើមដែលបង្កឱ្យមានការរំខានសំឡេង។
- **ការបំពុលពីប្រភពអចល័ត** គឺសំដៅដល់ប្រភពនៃការបំពុលដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍ជាអាទិ៍ មានដូចជា រោងចក្រ សហគ្រាស ការដ្ឋានសំណង់ ឧស្សាហកម្ម កន្លែងក្លឹបកម្សាន្ត ភោជនីយដ្ឋាន សិប្បកម្ម កន្លែងសិប្បកម្ម លំនៅឋានជាដើមផងដែរ រួមមានម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនកាត់ស្មៅ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបូមសំរាម ម៉ាស៊ីនភ្លើងជាដើម។[៧០]

### ២.១.៥.២. ផលវិបាកនៃការបំពុលសំឡេង

មនុស្សយើងគ្រប់រូបតែងតែទទួលសំឡេងជារៀងរាល់ថ្ងៃ ពីមជ្ឈដ្ឋានជុំវិញខ្លួននៅក្នុងសហគមន៍ដែលរស់នៅ។ ប៉ុន្តែការបំពុលសំឡេងអាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាព និងសកម្មភាពប្រចាំថ្ងៃផងដែរ។ ដែលជាទូទៅ កម្រិតនៃការបំពុលដោយសំឡេង ដែលអាចទ្រាំទ្របាន គឺនៅក្នុងកម្រិតដល់៤០ ដេស៊ីប៊ែលប្រសិនបើលើសពីកម្រិតនេះ នោះនឹងអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការរស់នៅរបស់ពលរដ្ឋដូចជា៖

- **រំខានដល់ការសិក្សារៀនសូត្រ** ពេលដែលនរណាម្នាក់ទទួលរងនូវការរំខានដោយសំឡេងនៅពេលដែលខ្លួនកំពុងសិក្សាពីមុខវិជ្ជាអ្វីមួយនោះមិនសូវអាចផ្តោតអារម្មណ៍ទៅលើសមត្ថភាពនៅពេលសិក្សា។
- **ការរំខានដំណេក** ចំពោះអ្នកដែលរស់នៅជិតតំបន់ដែលទទួលរងនៃការរំខានដោយសំឡេងការបំពុលដោយសំឡេងក៏អាចប៉ះពាល់ដូចជាសុខភាព រូបរាងកាយ និងប្រព័ន្ធការចងចាំរបស់គេនឹងទទួលរងនូវផលអវិជ្ជមានជាខ្លាំងនៅពេលទទួលដំណេកមិនគ្រប់គ្រាន់។

[៧០] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៥៣

- **លើសសម្ពាធឈាម** នៅពេលដែលមនុស្ស ទទួលរងនូវការរំខានដោយសំឡេងរយៈពេលយូរនោះ អាចធ្វើឱ្យសុខភាពមនុស្សមានជំងឺលើសសម្ពាធឈាម និងបញ្ហាបេះដូងដោយសារតែ សុខភាព របស់ពួកគេមិនអាចទ្រាំបាននូវការរំខានដោយសំឡេងខ្លាំងៗ និងមានរយៈពេលយូរ។[៧១]

## ២.២. ដំណោះស្រាយនៃការបំពុលបរិស្ថាន

ជាទូទៅរាល់ប្រទេសនីមួយៗ គឺតែងជួបវិបត្តិទៅលើការបំពុលពីសំណល់ដែលតែងតែជួបផលប៉ះពាល់ជាខ្លាំងទៅលើការរៀបចំអភិវឌ្ឍន៍ប្រទេសជាតិដូចជា ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជាពិសេស ការបំពុលសំណល់បានជះឥទ្ធិពលយ៉ាងចម្បងដល់សុខភាពមនុស្ស និងចំពោះសត្វ រុក្ខជាតិផងដែរ។ បើក្រឡេកមើលនៅក្នុងរាជធានីភ្នំពេញ ខណ្ឌទាំង១៤ តែងតែមានការរៀបចំការប្រកួតប្រជែងបរិស្ថានស្អាតទូទាំងទីក្រុង ដើម្បីទទួលបាននូវស្នាដៃពីការខិតខំធ្វើការ ពិសេសវាបានបង្កើនឱ្យមាននូវការទាក់ទាញវិនិយោគក្នុងដែនដីរបស់ខ្លួនដែលអាចជួយដោះស្រាយបញ្ហាផ្សេងៗ ដែលមានភាពក្រីក្រ របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន បង្កើតឱកាសឱ្យមានការចូលរួមរបស់រដ្ឋាភិបាលជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលក្នុងការស្វែងរកនូវជំនួយ ដែលមានកញ្ចប់ថវិកាក្នុងការអភិវឌ្ឍដូចជាកសាងគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធនានា ពិសេសពីក្រុមហ៊ុនរបស់ឯកជននៅក្នុងស្រុក និងក្រៅប្រទេស ចូលបណ្តាក់ទុនក្នុងការកសាងរោងចក្រ សហគ្រាស ផ្សារទំនើប អចលនទ្រព្យផ្សេងៗផងដែរ។ ទាក់ទងទៅនិងការអភិវឌ្ឍនេះខណ្ឌនីមួយៗ ត្រូវតែផ្តោតការយកចិត្តទុកដាក់ពីបរិស្ថាន និងរកដំណោះស្រាយនៅក្នុងការគ្រប់គ្រងសំណល់ដែលមានដូចជា៖

### ២.២.១. ដំណោះស្រាយការបំពុលទឹក

នៅក្នុងដំណោះស្រាយក្នុងការបំពុលទឹក គឺយើងមានវិធានការចូលរួមដោះស្រាយទៅលើកត្តាសំខាន់ ០២យ៉ាងធំៗ គឺការចូលរួមរបស់ក្រសួងបរិស្ថាន និងការចូលរួមរបស់ប្រជាពលរដ្ឋដូចជា៖

- **ការចូលរួមរបស់ក្រសួងបរិស្ថាន**

  - ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយ ការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

[៧១] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្តដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៤៤

- ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកដែលនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។
- ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈណាត្រូវទទួលរងការបំពុលដែលបានបង្កឱ្យមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចម្រុះ ក្រសួងបរិស្ថាន គឺត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈបន្ទាន់អំពីបញ្ហានៃគ្រោះថ្នាក់នេះ និងត្រូវចាត់វិធានការទប់ស្កាត់ផងដែលពីការបំពុលទឹកដោយចុះស្តារនូវគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈនោះ។[៧២]

❖ **ការចូលរួមរបស់ប្រជាពលរដ្ឋ**

ប្រជាពលរដ្ឋគ្រប់រូបត្រូវមានការចូលរួមជួយប្រកាន់ភ្ជាប់នូវវិធានការរបស់ក្រសួងបរិស្ថានក្នុងការចូលរួមសម្អាតបរិស្ថានដូចជា៖

- បោះចោលសំរាមទៅក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ វេចខ្ចប់ត្រឹមត្រូវ
- ត្រូវមានវិធានការធ្វើប្រព័ន្ធប្រព្រឹត្តកម្មសំរាម កាកសំណល់មានស្តង់ដារមុននឹងបង្ហូរសំណល់ទៅក្នុងលូសារធារណៈ
- ចូលរួមក្នុងការប្រើប្រាស់បង្គន់អនាម័យឱ្យបានគ្រប់ៗគ្នា ដើម្បីសោភ័ណភាពបរិស្ថាន ជាពិសេសប្រជាពលរដ្ឋតាមជនបទដាច់ស្រយាល
- កាត់បន្ថយការប្រើប្រាស់ប្រភេទថង់ប្លាស្ទិក ដប កំប៉ុងជ័រ គួរចូលរួមប្រើប្រាស់របស់ដែលអាចកែច្នៃឡើងវិញបាន ជាពិសេស ចូលរួមប្រើប្រាស់របស់ដែលមានគុណភាពមិនប៉ះពាល់សោភ័ណភាព និងបរិស្ថាន
- ចូលរួមទុកដាក់សំណល់ឱ្យបានល្អរួមទាំងសំណល់សរីរាង្គ និងប្រភេទសំណល់ដែលគ្រោះថ្នាក់ផ្សេងៗ។

---

[៧២] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨

### ២.២.២. ដំណោះស្រាយនៃការបំពុលដី

ទាក់ទងនៃការបំពុលទាំងឡាយដែលបានកើតឡើងនៅក្នុងសង្គមមួយ ប្រទេសមួយជាការពិតណាស់ អ្នកដឹកនាំ ឬរាជរដ្ឋាភិបាល មិនត្រូវទុកឱ្យមានសកម្មភាពនៃការបំពុល និងមិនដោះស្រាយនោះឡើយ។ ពីព្រោះដី បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតស្បៀងអាហារប្រចាំថ្ងៃ សម្រាប់ផ្គត់ផ្គង់មនុស្សរាប់ពាន់លាននាក់នៅលើពិភពលោកនាពេលបច្ចុប្បន្ន។ កសិផលស្ទើរតែទាំងអស់បានមកពីការធ្វើកសិកម្មនៅលើដី ពីព្រោះថាដីជាមជ្ឈដ្ឋានផ្តល់សារធាតុចិញ្ចឹមដល់រុក្ខជាតិដ៏មានប្រសិទ្ធភាពមួយ។ ការដាំដុះដំណាំដោយមិនស្វែងយល់ពីដី និងអាចធ្វើឱ្យដីអន្តរាយនាពេលអនាគតជាក់ជាមិនខាន។ គឺមិនអាចទទួលបានទិន្នផលខ្ពស់នោះទេដូចនេះ ការយល់ដឹងពីវិទ្យាសាស្ត្រដី គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយក្នុងការងារបម្រើឱ្យ វិស័យកសិកម្ម ប្រកបដោយជោគជ័យ និងមាននិរន្តរភាព។[៧៣] ដោយសារដី មានសារៈសំខាន់ ដូច្នេះហើយយើងត្រូវជួយរួមគ្នារកវិធានការដោះស្រាយទៅលើការបំពុលដី ជាមួយនឹងក្រសួងបរិស្ថានផងដែរ។

❖ **ការចូលរួមរបស់ប្រជាពលរដ្ឋ**

➢ យើងត្រូវចូលរួមជួយសម្អាតបរិស្ថានទាំងអស់គ្នា ដូចជាការចូលរួមចែកប្រភេទសំណល់នានាតាមការណែនាំរបស់ក្រសួងបរិស្ថានជាពិសេស គឺត្រូវទុកដាក់នូវកាកសំណល់ដែលអាចយកប្រើប្រាស់ឡើងវិញបានឱ្យមានភាពត្រឹមត្រូវ

➢ ចូលរួមធ្វើការផ្សព្វផ្សាយអំពីវិធានការរើសសំរាមដើម្បីទីក្រុងមានសោភ័ណភាព យើងដឹងហើយថាការរៀបចំសោភ័ណភាពឱ្យស្រស់ស្អាតមិនអាចផ្តើមពីខ្លួនយើងម្នាក់ទេ គឺត្រូវចូលរួមជាផ្លូងមួយ។

➢ ដាក់ធុងសំរាមនៅទីធ្លាសាធារណៈ កន្លែងកម្សាន្ត តំបន់ទេសចរណ៍ ឧទ្យានជាតិនានា ឱ្យបានច្រើនជៀសវាងការបោះសំរាមរាយប៉ាយ ផ្តេសផ្តាសគ្មានសណ្តាប់ធ្នាប់

➢ ចូលរួមកាត់បន្ថយការប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វល្អិត កសិករគួរតែប្រើប្រាស់ជីធម្មជាតិដើម្បីឱ្យដីកាន់តែមានជីវជាតិល្អ

➢ ចូលរួមជាមួយរដ្ឋាភិបាល និងក្រសួងបរិស្ថានក្នុងយុទ្ធនាការសោភ័ណភាពសហគមន៍ទីក្រុង។

---

[៧៣] គេហទំព័រ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទhttps://server២.maff.gov.kh/ ដកស្រង់នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤

### ២.២.៣ ដំណោះស្រាយនៃការបំពុលខ្យល់

ខ្យល់ជាឧស្ម័នចម្រុះគ្នា ភាគច្រើន គឺអុកស៊ីសែន និងនីត្រូសែនដែលរុក្ខជាតិ សត្វ និងមនុស្ស ត្រូវការដើម្បីរស់រានមានជីវិត។[៧៤] នៅពេលការបំពុលខ្យល់កើតមានឡើងវា និងនាំវត្តមាននៃសារធាតុកខ្វក់ មេរោគ នៅក្នុងនឹងក្រៅបរិយាកាស វានិងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត មនុស្ស សត្វ និងរុក្ខជាតិ។ ហេតុនេះ យើងត្រូវចូលរួមដោះស្រាយជាមួយគ្នានៅក្នុងការបំពុលខ្យល់។ ចំពោះវិធានការ ចូលរួមដោះស្រាយទៅលើកត្តាបំពុលខ្យល់សំខាន់ៗមាន ០២យ៉ាងមាន៖

❖ **ការចូលរួមរបស់ក្រសួងបរិស្ថាន**

➢ ត្រូវត្រួតពិនិត្យតាមដានជាប្រចាំអំពីស្ថានភាព និងគុណភាពខ្យល់ទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់នឹងធ្វើការកាត់បន្ថយការបំពុលខ្យល់ឱ្យបានទាន់ពេលវេលា។

➢ ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់វាយតម្លៃអំពីស្ថានភាពគុណ្ណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានច្រើនពីស្ថានភាពគុណភាពនឹងការបំពុលខ្យល់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

➢ ក្នុងករណីរកឃើញថាតំបន់ណាមួយត្រូវបានរងការបំពុលខ្យល់ ដែលបង្កឱ្យមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬទៅលើគុណភាព បរិស្ថានក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវបើកការស៊ើបអង្កេតរកប្រភពដែលបង្កឱ្យមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារឱ្យគុណភាពខ្យល់បានប្រសើរឡើងវិញ។[៧៥]

❖ **ការចូលរួមពីប្រជាពលរដ្ឋ**

➢ ចូលរួមយុទ្ធនាការដាំដើមឈើឱ្យបានច្រើនដើម្បីបន្សុតបរិយាកាស។

➢ ចូលរួមកាត់បន្ថយការប្រើប្រាស់យានយន្ត ទោចក្រក្រយានយន្តចាស់ៗ ជាពិសេសគួរតែចូលរួមក្នុងការកាត់បន្ថយការបំពុលខ្យល់ពីបំពង់ស៊ីមាំងងាកមកចូលរួមក្នុងការជិះឡានក្រុង។

---

[៧៤] គេហទំព័រ មូលនិធិសង្គ្រោះកុមារនៅកម្ពុជារបស់អង្គការសហប្រជាជាតិ https://www.unicef.org/cambodia/km/ ដកស្រង់នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤

[៧៥] អនុក្រឹត្យ ពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ ៤៧ អនក្រ.បក, ចុះនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០០, មាត្រា២៧, ទំព័រទី១៣៨

- ធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីមូលហេតុនៃការបំពុលខ្យល់ និងដំណោះស្រាយដែលស្តីពីការបំពុលខ្យល់។
- ម្ចាស់ រោងចក្រ សហគ្រាសដែលដំណើរការដោយប្រេងឥន្ធនៈ គួរតែមានម៉ាស៊ីនបន្សុតខ្យល់ដែលមានស្តង់ដារមុននឹងបំភាយទៅបរិយាកាស។

### ២.២.៤. ការដោះស្រាយនៃសំណល់រឹង រាវ

យើងបានជ្រាបរួចហើយថាការបំពុលសំណល់រឹង រាវ មានគ្រោះថ្នាក់យ៉ាងខ្លាំងទៅដល់ សុខភាព អាយុជីវិតនឹងបរិស្ថាន។ ដូច្នេះយើងត្រូវតែមាន វិធានការក្នុងការដោះស្រាយទៅលើបញ្ហាទាំងអស់នោះដោយៈ

**❖ ការដោះស្រាយនៃសំណល់រឹង**

- ប្រជាពលរដ្ឋត្រូវចូលរួមប្រមូលសំរាម ដែលមានការចងចង់ឱ្យបានជិត និងដាក់សំរាមទៅតាមប្រភេទនៃសំរាមឱ្យបានត្រឹមត្រូវ ក្នុងកន្ត្រកសំរាមជៀសវាងការគរជាគំនរចោលនៅលើដីមានភាពរាយប៉ាយនិងនាំមកនូវគ្រោះថ្នាក់ពីសំណល់រឹងទាំងនោះ។
- យកចិត្តទុកដាក់ពីបញ្ហាសំរាមរបស់អាជ្ញាធររាជធានី ខេត្ត និងការធ្វើប្រតិភូកម្មទៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដែលត្រូវធ្វើការសហការណ៍ជាមួយ និងក្រុមហ៊ុនប្រមូលសំរាមដើម្បីដឹកជញ្ជូនសំរាមរៀងរាល់សប្តាហ៍  ឬជារៀងរាល់ថ្ងៃដើម្បីអនុវត្តន៍តាមតម្រូវការ និងឆ្លើយតបទៅនិងប្រជាពលរដ្ឋ។
- បណ្តុះយុវជន ឱ្យចូលរួមសម្អាតបរិស្ថានទាក់ទងនឹងការបំពុលសំណល់ និងរកវិធីដោះស្រាយដើម្បីទប់ស្កាត់ដូចជានៅតាមសាលារៀន ទីផ្សារ និងធ្វើការផ្សព្វផ្សាយលើបណ្តាញសង្គម។
- ជាពិសេស ប្រជាពលរដ្ឋគួរប្រើប្រាស់សំណល់រឹងឱ្យទៅជាវត្ថុដែលអាចកែច្នៃឡើងវិញបានដែលធ្វើវិធីសាស្ត្រដូចជាៈ
  - ការកែច្នៃឡើងវិញ មានសំណល់សើមដូចជាដែក សំបកយានយន្ត ជ័រ អាលុយមីញ៉ូមជាដើម ដែលមកបំលែងប្រើប្រាស់ឡើងវិញ។
  - ប្រែក្លាយសំណល់ជាថាមពល ឧទាហរណ៍នៅក្នុងប្រទេសកម្ពុជាមានការផ្តល់នូវមូលនិធិពីសហភាពអឺរ៉ុប SWITH-ASIA, អង្គការ SNVកម្ពុជា បានអនុវត្តគម្រោងប្រែក្លាយសំណល់ជា

ថាមពលក្នុងការប្រើប្រាស់ក្នុងរោងកិនស្រូវ គឺការបច្ចេកវិទ្យាដើម្បីបម្លែងថាមពលអគ្គិសនីពីអង្កាម (ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៥)។[៧៦]

❖ **ដំណោះស្រាយសំណល់រាវ**

➢ **រោងចក្រ សហគ្រាស សិប្បកម្ម** ត្រូវរៀបចំឱ្យមានអាងធ្វើប្រព្រឹត្តកម្មសម្អាតសំណល់ឱ្យបានត្រឹមត្រូវទៅតាមបទដ្ឋានបច្ចេកទេសមុនបង្ហូរចូលទឹកដាក់ដំណើរការជាប្រចាំ។

➢ **ក្រសួងបរិស្ថាន** ត្រូវចុះទៅប្រមានដល់ម្ចាស់ ឬអ្នកទទួលខុសត្រូវចំពោះការមិនធ្វើតាមបទដ្ឋានត្រឹមត្រូវ ត្រូវដាក់ទោសចំណោះមុខច្បាប់ និងដាក់ទៅតាមទំហំបទល្មើស ឬទទួលការបង់ពិន័យជាសាច់ប្រាក់។

### ២.២.៥. ដំណោះស្រាយការបំពុលសំឡេង

ដើម្បីឱ្យការបំពុលសំឡេង មានភាពប្រសើរបានយើងត្រូវចូលរួមអនុវត្តនូវវិធានការ និងសហការជាមួយស្ថាប័នពាក់ព័ន្ធនឹងការបំពុលសំឡេងដែលរួមមាន៖

➢ អប់រំប្រជាពលរដ្ឋ ពីការបំពុលសំឡេងពីព្រោះអាចឱ្យប្រជាពលរដ្ឋយល់ដឹង និងគិតពីអ្នកដទៃ

➢ បង្កើតគណៈកម្មការត្រួតពិនិត្យការបំពុលសំឡេងកម្រិតខ្លាំង

➢ ការដ្ឋានសំណង់ និងការធ្វើពិធីនានាគួរតែប្រើប្រាស់ឧបករណ៍ដែលអាចបន្ថយសំឡេងក្នុងកម្រិតទទួលយកបាន។

➢ ស៊ីផ្លេយានយន្តគ្រប់ប្រភេទគួរតែមានហ្វ្រេកង់កម្រិតស៊ីផ្លេ។

សរុបមកវិញ ការរៀបចំបរិស្ថាននឹងការដោះស្រាយការបំពុលទាំង០៥ មានការបំពុលខ្យល់ ការបំពុលទឹក ការបំពុលដី ការបំពុលសំណល់រឹង រាវ និងការបំពុលសំឡេង នៅក្នុងទីក្រុង គឺពិតជាមានការចាំបាច់ពិតប្រាកដមែនបើតាមការរៀបរាប់ពីការបំពុលខាងលើមក។ បើងាកទៅមើលក្នុងខណ្ឌព្រែកព្នៅ ការរៀបចំបរិស្ថាននេះដែល គឺមានការយកចិត្តទុកដាក់រៀបចំបរិស្ថានបានយ៉ាងល្អទាំងនៅតាមដងផ្លូវមហាវិថី ទីផ្សារ សាលារៀន កន្លែងសារធារណៈជាដើម គឺមានសោភ័ណភាពល្អជាច្រើន។ ម្យ៉ាងទៀតប្រជាពលរដ្ឋនៅខណ្ឌព្រែកព្នៅ មានភាពយល់ដឹងអំពីការរៀបចំសណ្ដាប់ធ្នាប់ដែលមានការរៀបចំវិច្ចខ្ចប់សំរាមបានត្រឹមត្រូវមិនចោលរាយប៉ាយ។ នៅមុខផ្ទះប្រជាពលរដ្ឋភាគច្រើនតែងមានកន្ត្រកមុខផ្ទះប្រជាពលរដ្ឋ ឬធ្វើជាទ្រុងដែកសម្រាប់ដាក់សំរាម

[៧៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ព ឆ្នាំ២០២៣, ទំព័រទី៣៩

ចោលដើម្បីងាយស្រួលសម្រាប់ដាក់សំរាមសំណល់ និងមិនមានការហើរាយប៉ាយទៅតាមផ្លូវសាធារណៈនោះទេ។ ជាពិសេសអាជ្ញាធរខណ្ឌព្រែកព្នៅ បានចូលរួមសហការណ៍ជាមួយក្រុមហ៊ុនប្រមូលសំរាមនៅតាមផ្ទះប្រជាពលរដ្ឋ នៅតាមផ្លូវថ្នល់ មន្ទីរពេទ្យ សាលារៀន ទីផ្សារផងដែរ។ យ៉ាងណាមិញ  ការចូលរួមថែរក្សានូវបរិស្ថានរបស់ប្រជាពលរដ្ឋ ជាមួយរដ្ឋបាលខណ្ឌនៅតែមានប្រជាពលរដ្ឋភាគតិច ដែលនៅតែប្រព្រឹត្ត ការបោះចោលសំរាមមិនបានត្រឹមត្រូវនៅឡើយ ទោះបីជាយ៉ាងណារដ្ឋបាលខណ្ឌព្រែកព្នៅ នៅតែខំយកចិត្តទុកដាក់ក្នុងការសម្រួលស្ថានការណ៍និងតែងតែចេញនូវវិធានការជាញឹកញាប់បន្តទៀត ដើម្បីទីក្រុងស្អាតមានអនាម័យល្អ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាន គឺនាំមកនូវរបៀបរៀបរយ មានភាពស្រស់ស្អាតនៅក្នុងខណ្ឌទាំងមូល។ មិនតែប៉ុណ្ណោះ ការរៀបសោភ័ណភាពនេះមានការជះឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងដល់ការអភិវឌ្ឍប្រទេសទៅលើវិស័យដូចជា ផ្នែកសេដ្ឋកិច្ចដែលបាននាំមកនូវលំហូរនៃការវិនិយោគពីក្នុងប្រទេស និងក្រៅប្រទេស រីឯវិស័យទេសចរណ៍វិញបាននាំមកនូវកំណើនទេសចរណ៍ចូលក្នុងប្រទេស ដែលវាបាននាំយករូបិយប័ណ្ណបរទេសចូលមក។ មួយវិញទៀតបើនិយាយអំពីវិស័យសំណង់ នៅក្នុងប្រទេសកម្ពុជាយើងមានការកសាងនៅប្រភេទសំណង់អគារជាច្រើនដែលមានប្រភេទ ផ្ទះលំហែលកាយ លំនៅឋានបុរី វីឡាទំនើប អគារពាណិជ្ជកម្មខ្ពស់ៗផងដែរ។ជាបន្ទាប់ គឺវិស័យឧស្សាហកម្ម នៅពេលមានការរៀបចំសណ្តាប់ធ្នាប់បានល្អនឹងមានកំណើន រោងចក្រ ឧស្សហកម្មកើនឡើង ម្យ៉ាងទៀតវាបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមមូលដ្ឋានផងដែរ។

នៅក្នុងខណ្ឌព្រែកព្នៅ អភិបាលនៃគណៈអភិបាលខណ្ឌតែងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាការរៀបចំខាងលើនេះ។ បើងាកទៅមើលតាមបណ្តោយផ្លូវសាធារណៈមានការរៀបចំបង្គោលភ្លើង និងមានដាក់កាម៉េរាសុវត្ថិភាព គូសគំនូសឆ្នូតតាមដងផ្លូវ និងបំពាក់ភ្លើងស្តុបនៅតាមមហាវិថីដើម្បីសុវត្ថិភាពប្រជាពលរដ្ឋផងដែរ។

យ៉ាងណាមិញ ទន្ទឹមនឹងការរៀបចំសណ្តាប់ធ្នាប់នៅខណ្ឌព្រែកព្នៅឱ្យមានភាពល្អប្រសើរ ក្រុមនាងខ្ញុំក៏បានឃើញមានបញ្ហាប្រឈមនឹងបរិស្ថានផងដែរ នៅតែមិនទាន់មានការគ្រប់គ្រងបានល្អនៅឡើយនោះទេ គឺនៅមានក្នុងកម្រិតតិចតួចដែលមិនទាន់សម្រួលបាន ដែលទាក់ទងទៅនឹងសំរាមដែលចោលនៅដីទំនេរតាមដងផ្លូវសាធារណៈ និងកន្លែងលក់ដូរតាមផ្ទះប្រជាពលរដ្ឋមួយចំនួនតូចមានថង់ប្លាស្ទិក ដំរ កំប៉ុងផ្សេងៗដែលរាយប៉ាយបង្កជាផលប៉ះពាល់ដល់សោភ័ណភាពនៅក្នុងខណ្ឌ។ ដូច្នេះអាជ្ញាធរខណ្ឌគួរតែមានការដាក់ធុងសំរាមឱ្យបានច្រើនទៅតាមប្រភេទសំណល់មានគ្រប់ភូមិ ឃុំ សង្កាត់នៅតាមដងផ្លូវ កន្លែងទីប្រជុំជនមានទីផ្សារ សាលារៀន កន្លែងទេសចរណ៍ វប្បធម៌ជាដើម។

សរុបមក ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាននៅក្នុងខណ្ឌទាំងមូល គឺពិតជាសំខាន់ណាស់ពីព្រោះវាបានធ្វើឱ្យមានរបៀបរៀបរយល្អ នាំមកនូវសោភ័ណភាព សុវត្ថិភាព ដែលស្របទៅតាមគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ជាពិសេសថែមទាំងបានលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋដែលបានមកពីការការីកចម្រើននៃវិស័យផ្សេងៗដែលមាននៅក្នុងខណ្ឌព្រែកព្នៅផងដែរ។

# អនុសាសន៍

# អនុសាសន៍

ដោយមើលឃើញពីស្ថានភាពជាក់ស្តែងនៃការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌព្រែកព្នៅ គឺមានលក្ខណៈល្អប្រសើរច្រើន ដោយសារការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីអភិបាលនៃគណៈអភិបាលខណ្ឌ និងអាជ្ញាធរក្នុងខណ្ឌព្រែកព្នៅ ដែលបានបានខិតខំបម្រើប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ដែលរួមមានការស្តាបនាប្រព័ន្ធហេដ្ឋារចនារចនាសម្ព័ន្ធនានា ការរៀបចំនូវសណ្តាប់ធ្នាប់ល្អ និងការដោះស្រាយលើបញ្ហាសំរាមជាមួយប្រជាពលរដ្ឋ។ ប៉ុន្តែជាមួយគ្នានេះដែរ នាងខ្ញុំទាំងពីរនាក់បានមើលឃើញពីបញ្ហាផ្សេងៗមួយចំនួនដែលកើតឡើងនៅក្នុងខណ្ឌព្រែកព្នៅដែលទាក់ទង និងការចោលសំរាមរាយប៉ាយដែលមិនសូវមានសណ្តាប់ធ្នាប់ល្អ និងបញ្ហាមួយចំនួនទៀត ដូច្នេះនាងខ្ញុំទាំងពីរនាក់សូមអនុញ្ញាតិ ស្នើសុំការបញ្ចេញមតិយោលបល់ទៅលើបញ្ហាទាំងនេះដែលមានដូចជា៖

- គួរមានវិធានការផ្សព្វផ្សាយ និងអប់រំទៅលើប្រជាពលរដ្ឋមួយចំនួនតូចដែលតែងបន្តចោលសំរាមគ្មានសណ្តាប់ធ្នាប់ រាយប៉ាយដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាពក្នុងខណ្ឌ។
- គួរមានការដាក់ធុងសំរាមឱ្យបានច្រើនទៅតាមប្រភេទសំណល់ ដែលមានគ្រប់ភូមិ ឃុំ សង្កាត់ នៅតាមដងផ្លូវ ទីផ្សារ និងសាលារៀន និងកន្លែងកម្សាន្តនានា
- យកចិត្តទុកដាក់ទៅលើ តម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់មួយចំនួនលើការកង្វះទឹកស្អាតប្រើប្រាស់ ដូច្នេះគួរតែដោះស្រាយបញ្ហានេះជាចម្បង
- មានវិធានការជាកំហិតចំពោះយានយន្តគ្រប់ប្រភេទ ដែលបើកបរក្នុងល្បឿនលឿនដែល ពីព្រោះអាចបង្កទៅជាគ្រោះថ្នាក់ចរាចរណ៍លើប្រជាពលរដ្ឋដែលជិះឆ្លងកាត់
- គួរតែណែនាំដល់ប្រជាពលរដ្ឋប្រើប្រាស់កន្ត្រកយួរពីផ្ទះ និងថង់ក្រណាត់ដើម្បីដាក់បន្លែ ផ្លែឈើ ត្រីសាច់ ពីព្រោះវាកាន់តែធ្វើឱ្យខណ្ឌព្រែកព្នៅមានភាពលេចធ្លោនឹងមានបរិស្ថានស្អាតជាងគេនៅទីក្រុង
- ផ្លូវប្រជុំជនខ្លះនៅពេលយប់ មានភាពស្ងប់ស្ងាត់ជាខ្លាំង ដូច្នេះត្រូវមានប្រជាការពារភូមិយាមតាមតំបន់មួយចំនួនដើម្បីថែរក្សាសន្តិសុខ ការពារសុវត្ថិភាពប្រជាពលរដ្ឋដែលធ្វើដំណើរនៅពេលយប់
- កង្វះការរៀបចំ នៅកន្លែងចតយានយន្តច្រើន និងមានការរឹតបន្តឹងចំពោះប្រជាជនមួយចំនួនតូចដែលធ្វើសកម្មភាពបោះចោលថង់សំរាមនៅតាមដងផ្លូវ និងសាងសង់សំយ៉ាបផ្ទះហួសដល់ផ្លូវសាធារណៈ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ ស្ដីពីសុវត្ថិភាពម្ហូបអាហារ, នស/រកម/០៦២២/០០៦, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២
- អនុក្រឹត្យ ស្ដីពីការបង្កើតខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញ និងការកែសម្រួលព្រំប្រទល់រដ្ឋបាល រវាងខណ្ឌពោធិ៍សែនជ័យ និងខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ, លេខ ៥៧៨ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣
- អនុក្រឹត្យ ស្ដីពីការគ្រប់គ្រងលូ និងប្រព័ន្ធទឹកកខ្វក់, លេខ ២៣៥ អនក្រ.បក, ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧
- អនុក្រឹត្យ ស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងរំខានដោយសំឡេង, លេខ ៤៧ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- អនុក្រឹត្យ ស្ដីពីការគ្រប់គ្រងសំណល់រឹង, លេខ ៣៦ អនក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យ ស្ដីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩
- សេចក្ដីសម្រេច ស្ដីពីការបែងចែកតួនាទីភារកិច្ច និងរបៀបរបប ធ្វើការជូនគណៈអភិបាល នៃអភិបាលខណ្ឌព្រែកព្នៅ, លេខ០៣៤ ស.សរ/រហ
- ផែនការណែនាំ ស្ដីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព, លេខ ០២០ផ.ក
- សេចក្ដីណែនាំ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្ដីពីការរៀបចំសណ្ដាប់ធ្នាប់តាមដងផ្លូវ និងប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់នៅភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០១៣/១៨ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨

- របាយការណ៍ ប្រចាំខែមីនា ឆ្នាំ២០២៤ ស្តីពីលទ្ធផលបូកសរុបនៃការចាត់តាំងអនុវត្តគោលនយោបាយ (ភូមិ ឃុំមានសុវត្ថិភាព) របស់រដ្ឋបាលខណ្ឌព្រែកព្នៅ
- របាយការណ៍ ប្រចាំខែមីនា ឆ្នាំ២០២៤ ស្តីពីលទ្ធផលបូកសរុបនៃការចាត់តាំងអនុវត្តគោលនយោបាយ (ភូមិ ឃុំមានសុវត្ថិភាព) របស់រដ្ឋបាលខណ្ឌព្រែកព្នៅ
- របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌព្រែកព្នៅប្រចាំឆមាសទី១ ឆ្នាំ២០២៣
- របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌព្រែកព្នៅ ប្រចាំឆ្នាំ២០២៣

## ២. ឯកសារយោងជាសៀវភៅនៃនិពន្ធ

- វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត
- សៀវភៅ នីតិនគរូបនីយវិទ្យា សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣
- សៀវភៅ ផែនការអភិវឌ្ឍន៍៥ឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលខណ្ឌព្រែកព្នៅ
- សៀវភៅ របាយការណ៍ ស្តីពីការអនុវត្តកាងាររដ្ឋបាលរបស់ខណ្ឌព្រែកព្នៅ (ឆ្នាំ២០២៣)
- សៀវភៅ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ២០៣៥

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័ររបស់ក្រសួងបរិស្ថាន https://www.moe.gov.kh/index/22766
- គេហទំព័ររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន https://www.mpwt.gov.kh/index.php/en/press/5524
- គេហទំព័រ របស់សាលារាជធានីភ្នំពេញ https://phnompenh.gov.kh/news-press-releases/post/news21823/
- គេហទំព័រ ក្រសួងកសិកម្មរុក្ខប្រមាញ់ និងនេសាទ https://www.mpwt.gov.kh/kh/press/
- គេហទំព័រ https://www.information.gov.kh/articles/30034
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/industries/

- គេហទំព័រ https://www.kampucheathmey.com/local-news/280728
- គេហទំព័រ https://construction-property.com/km/lets-find-out-ep27-how-does-road-infrastructure-contributes-to-economic-growth/
- គេហទំព័រ https://www.unep.org/news-and-stories/story/globally-3-billion-people-health-risk-due-scarce-data-water-quality
- គេហទំព័រ https://data.opendevelopmentcambodia.net/km/library_record/land-use-master-plan-for-khan-prek-pnov-vision-2035/resource/593133da-3436-42e6-bd45-fdf3425fef86
- គេហទំព័រ https://propertyarea.asia/archives/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១ ៖** សៀវភៅ ប្លង់គោល ប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យឆ្នាំ២០៣៥

**ឧបសម្ព័ន្ធទី២ ៖** ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី៣ ៖** អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧ អនក្រ.បក, ចុះនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៦

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង, លេខ៣៦ អនក្រ.បក, ចុះនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦

**ឧបសម្ព័ន្ធទី៥ ៖** អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤៧ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១ ៖** ប្លង់គោលប្រើប្រាស់ដី ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥

**ឧបសម្ព័ន្ធទី២ ៖** បណ្តុំរូបរូបភាពទូទៅ នៃខណ្ឌព្រែកព្នៅ

**ឧបសម្ព័ន្ធទី៣ ៖** បណ្តុំរូបភាព ពីការបំពុលទឹក

**ឧបសម្ព័ន្ធទី៤ ៖** បណ្តុំរូបភាព ពីការបំពុលខ្យល់

**ឧបសម្ព័ន្ធទី៥ ៖** បណ្តុំរូបភាព ពីការបំពុលសំឡេង

**ឧបសម្ព័ន្ធទី៦ ៖** បណ្តុំរូបភាព ពីការបំពុលដី

**ឧបសម្ព័ន្ធទី៧ ៖** បណ្តុំរូបភាព ពីការបំពុលសំណល់រឹង រាវ

**ឧបសម្ព័ន្ធទី៨ ៖** បណ្តុំរូបភាព ពីសកម្មភាពត្រួតពិនិត្យសណ្តាប់ធ្នាប់សាធារណៈ

# ឧបសម្ព័ន្ធគតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ

## ចក្ខុវិស័យឆ្នាំ ២០៣៥

រៀបចំដោយ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
បោះពុម្ពផ្សាយលើកទី១
ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥, ខែធ្នូ ឆ្នាំ២០២១

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ចក្ខុវិស័យឆ្នាំ ២០៣៥

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

: ០៧៧ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា២ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ

-បានឃើញសេចក្ដីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្ដីសម្រេចនេះ។

**ប្រការ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅត្រូវរៀបចំផែនការសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ និងអភិបាលនៃគណៈអភិបាលខណ្ឌព្រែកព្នៅនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២រោច ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**១-សេចក្តីផ្តើម**

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែកនិងគ្រប់វិស័យក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថាដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដីនិងការធ្វើឱ្យប្រសើរឡើងនូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ខណ្ឌព្រែកព្នៅជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញ និងត្រូវបានកំណត់ជាតំបន់កំពុងអភិវឌ្ឍក្នុងរាជធានីភ្នំពេញក្នុងចំណោមតំបន់ជាយក្រុងផ្សេងទៀតគឺខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌសែនសុខ។ល។ និងជាមជ្ឈមណ្ឌលវប្បធម៌ នយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គមដែលមានការអភិវឌ្ឍប្រកបដោយសក្តានុពលប្រកួតប្រជែងនិងនិរន្តរភាពលើគ្រប់វិស័យ។

បច្ចុប្បន្នខណ្ឌព្រែកព្នៅមានព្រំប្រទល់ផ្នែកខាងជើងជាប់នឹងឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ផ្នែកខាងត្បូងជាប់នឹងខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ និងខណ្ឌពោធិ៍សែនជ័យ ផ្នែកខាងលិចជាប់នឹងឃុំទួលព្រិច ស្រុកអង្គស្នួល ខេត្តកណ្តាល និងផ្នែកខាងកើតជាប់នឹងទន្លេសាប។ ខណ្ឌព្រែកព្នៅមានផ្ទៃដីប្រមាណ១១ ៥៦០,៩០ ហិកតា និងចែកជា៥សង្កាត់និង៥៩ភូមិ ដូចតទៅ៖

- សង្កាត់គោករការស្ថិតនៅតាមផ្លូវទំនប់កប់ស្រូវមានលេខកូដ 121201 និងមានភូមិចំនួន១៨
- សង្កាត់ព្រែកព្នៅស្ថិតនៅតាមដងផ្លូវជាតិលេខ៥ និងផ្លូវទំនប់កប់ស្រូវមានលេខកូដ 121202 និងមានភូមិចំនួន៥
- សង្កាត់ពញាពន់ស្ថិតនៅតាមដងផ្លូវលេខ១៥១មានលេខកូដ 121203 និងមានភូមិចំនួន៨
- សង្កាត់ពន្សាំងដែលមានផ្លូវលេខ៤២ជាផ្លូវយុទ្ធសាស្ត្រមានលេខកូដ 121204 និងមានភូមិចំនួន២៤
- សង្កាត់សំរោងស្ថិតនៅតាមផ្លូវជាតិលេខ៥ និងផ្លូវលេខ១៥១ ឆ្ពោះទៅភ្នំប្រសិទ្ធិមានលេខកូដ 121205 និងមានភូមិចំនួន៤។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងការអភិវឌ្ឍខណ្ឌព្រែកព្នៅប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញនិងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំនូវប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យឆ្នាំ២០៣៥ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសការអភិវឌ្ឍដែនដីខណ្ឌព្រែកព្នៅទាំងមូលឱ្យស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅត្រូវបានកសាងដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្ដីពីសំណង់ ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្ដីពីទេសចរណ៍ ច្បាប់ស្ដីពីជលផល ច្បាប់ស្ដីពីផ្លូវថ្នល់ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្ដីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្ដីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានលក្ខណៈទូលំទូលាយ គ្របដណ្ដប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការ**តម្រង់ទិសការអភិវឌ្ឍនគរូបនីយកម្ម**ប្រកបដោយចីរភាពនិងបរិយាបន្ន ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់វិស័យក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹក ទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិដែលអាចធ្វើការអភិវឌ្ឍឱ្យមានសណ្ដាប់ធ្នាប់ របៀបរៀបរយ សោភណភាព ចីរភាព និងចូលរួមបង្ការទប់ស្កាត់ការប្រែប្រួលអាកាសធាតុដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្ដៅ ទឹកជំនន់ និងខ្យល់ព្យុះក្នុងរាជធានីជាដើម។

## ២-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច និងចក្ខុវិស័យ

### ២.១-ក្របខណ្ឌសង្គម-សេដ្ឋកិច្ច

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅត្រូវបានរៀបចំឡើងដោយបានសិក្សា ប្រមូលនិងវិភាគទិន្នន័យប្រជាសាស្ត្រ ទិន្នន័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទិន្នន័យសង្គម ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យបរិស្ថាន និងការស្រង់មតិសមស្របតាមគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" ច្បាប់ស្ដីពីសំណង់ និងអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

ដើម្បីកំណត់ចក្ខុវិស័យប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅដល់ឆ្នាំ២០៣៥ ក្របខណ្ឌសង្គម-សេដ្ឋកិច្ចត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រដោយផ្អែកតាមលទ្ធផលនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ និងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ ខណ្ឌព្រែកព្នៅត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ មានផ្ទៃដីប្រមាណ១១ ៥៦០,៩០ហិកតា និងចែកចេញចំនួន៥សង្កាត់ ដែលកាត់ចេញពីខណ្ឌសែនសុខនិងខណ្ឌពោធិ៍សែនជ័យ។ ប្រជាជននៅឆ្នាំ២០០៨ មានចំនួន៤៧ ៣១៣នាក់ និងនៅឆ្នាំ២០១៩ មានចំនួន១៩១ ៤៣៧នាក់ ហើយតាមការព្យាករណ៍នៅឆ្នាំ២០៣៥ ប្រជាជននឹងថយចុះមកត្រឹមចំនួន១៤៨ ១០៤នាក់ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ខណ្ឌព្រែកព្នៅនៅឆ្នាំ២០០៨ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន១១ ៨២៦នាក់ស្មើនឹង៤៩,៤% វិស័យឧស្សាហកម្មមានចំនួន៥ ៤៤០នាក់ស្មើនឹង២២,៧% និងវិស័យសេវាកម្មមានចំនួន៦ ៦៨២នាក់ស្មើនឹង២៧,៩% ហើយរំពឹងថានៅឆ្នាំ២០៣៥ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងថយចុះមកត្រឹមចំនួន១០ ៩៦០នាក់ស្មើនឹង២០,០% វិស័យឧស្សាហកម្មនឹងកើនឡើងដល់ចំនួន២៥ ៧៥៤នាក់ស្មើនឹង៤៧,០% និងវិស័យសេវាកម្មនឹងកើនឡើងដល់ចំនួន១៨ ០៨៣នាក់ស្មើនឹង៣៣,០%។

### ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅគឺសំដៅរៀបចំនិងអភិវឌ្ឍខណ្ឌព្រែកព្នៅ ជា "**មជ្ឈមណ្ឌលទីក្រុងមាត់ទឹកនៃរាជធានីភ្នំពេញតាមដងទន្លេសាប បឹងធំៗពីរគឺបឹងតាមោកនិងបឹងសំរោង និងជាច្រកចេញចូលខាងជើងនៃរាជធានីភ្នំពេញដែលជាគោលដៅអភិវឌ្ឍប្រកបដោយសក្តានុពលប្រកួតប្រជែងខ្ពស់ និងទាក់ទាញបំផុតសម្រាប់លំនៅឋាន ទេសចរណ៍វប្បធម៌-ធម្មជាតិ ពាណិជ្ជកម្ម ឧស្សាហកម្ម សេដ្ឋកិច្ច កសិកម្ម សិប្បកម្ម និងសេវាកម្មប្រកបដោយគុណភាពបរិស្ថានរស់នៅ និងប្រព័ន្ធគមនាគមន៍ល្អប្រសើរ**" តាមរយៈការជំរុញ៖ ១)លើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍ និងការកែលម្អនគរូបនីយកម្មនិងការគ្រប់គ្រងការប្រើប្រាស់ដីឱ្យបានត្រឹមត្រូវ ចំទិសដៅ មានគុណភាពបរិស្ថានរស់នៅល្អនិងសកម្មភាពទីក្រុងរស់រវើកប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន ២)អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារនិងសេវាទីក្រុងសម្បូរបែបប្រកបដោយគុណភាព សណ្តាប់ធ្នាប់សាធារណៈ និងធ្វើសមាហរណកម្មទៅក្នុងតំបន់ដើម្បីធានាគុណភាពរស់នៅល្អប្រសើរ ៣)អភិវឌ្ឍទេសចរណ៍វប្បធម៌-ធម្មជាតិតាមរយៈការថែរក្សាអត្តសញ្ញាណវប្បធម៌ជាតិ ការពារធនធានធម្មជាតិ និងទេសភាពធម្មជាតិ បរិស្ថានទន្លេសាប បឹងតាមោក បឹងសំរោង និងកសិកម្មបៃតង ៤)អភិវឌ្ឍពាណិជ្ជកម្ម ឧស្សាហកម្ម ធុរកិច្ច និងសេវាកម្មសម្បូរបែប និង៥)លើកកម្ពស់ការគ្រប់គ្រង អភិបាលកិច្ចល្អ ការអភិវឌ្ឍសង្គម និងការផ្តល់សេវាសាធារណៈល្អ កិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈល្អ។

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅ នឹងចូលរួមសម្រេចចក្ខុវិស័យប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ សំដៅធ្វើឱ្យរាជធានីភ្នំពេញដែលជា "**បេះដូងរបស់ព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅលើចំណុចពិសេសនៃប្រសព្វទន្លេបួនមុខហៅថាទន្លេបួនមុខដែលជាអត្តសញ្ញាណតែមួយគ្មានពីរ ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវប្បធម៌ប្រកបដោយសក្តានុពលប្រកួតប្រជែងជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព**"។

### ៣-គោលបំណងនិងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានគោលបំណងនិងគោលដៅដូចខាងក្រោម៖

#### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានគោលបំណងធានាសមាហរណកម្មនៃការអភិវឌ្ឍនិងការអភិរក្សនគរូបនីយកម្ម ការប្រើប្រាស់ដីនិងសក្តានុពលដែលមានស្រាប់ឱ្យបានត្រឹមត្រូវនិងចំទិសដៅ ប្រកបដោយភាពឆ្លាត គុណភាព តុល្យភាព ចីរភាព និងបរិយាបន្ន តាមរយៈការគ្រប់គ្រងនិងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។

#### ៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅមានគោលដៅដូចខាងក្រោម៖

- គ្រប់គ្រងការប្រើប្រាស់ដីនិងការប្រើប្រាស់សក្តានុពលធម្មជាតិនិងនគរូបនីយកម្មស្របទៅនឹងតំបន់លំនៅឋាន សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ រដ្ឋបាល និងសេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងស្របតាមលក្ខណៈពិសេសនៃតំបន់នីមួយៗ

- ជំរុញកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍធុរកិច្ចទាក់ទាញគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជន ដើម្បីសមធម៌សង្គមនិងផ្តល់ការងារ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យដើម្បីធានាភាពសុខដុមរមនាសង្គមនិងការអភិវឌ្ឍប្រកបដោយចីរភាព
- លើកកម្ពស់វិស័យទេសចរណ៍និងសេវាកម្មដោយអភិរក្សតំបន់ទេសចរណ៍ដែលមានស្រាប់ស្របតាមសក្តានុពលធម្មជាតិនិងអភិវឌ្ឍតាមលទ្ធភាពជាក់ស្តែងដោយលៃយ៉ាងណាឱ្យការអភិវឌ្ឍមិនប៉ះពាល់ដល់ការអភិរក្សហើយផ្តល់ប្រយោជន៍សម្រាប់មនុស្សទូទៅ
- លើកកម្ពស់និងអភិវឌ្ឍវិស័យកសិកម្មបែបទំនើប បង្កើនទីផ្សារផលិតផលកសិកម្ម និងបង្កើតទីតាំងបែងចែកផលនេសាទឱ្យបានល្អប្រសើរ
- លើកកម្ពស់បេតិកភណ្ឌ ធនធានធម្មជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធ
- ដោះស្រាយនិងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាជន
- ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាលក៏ដូចជាការគ្រប់គ្រងដែនដី គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅបានកំណត់យកផ្លូវនិងប្រឡាយជាខ្សែបន្ទាត់ព្រំប្រទល់រវាងខណ្ឌនិងខណ្ឌ និងរវាងខណ្ឌនិងស្រុក។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច និងការធ្វើសមាហរណកម្មការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ដូចខាងក្រោម៖

### ៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្ម

#### ៤.១.១-តំបន់នគរូបនីយកម្មបច្ចុប្បន្ន

ដើម្បីជំរុញការគ្រប់គ្រងនិងការកែលម្អតំបន់នគរូបនីយកម្មបច្ចុប្បន្នរបស់ខណ្ឌ សម្រាប់ការរស់នៅប្រកបដោយសុខុមាលភាព ត្រូវអនុវត្តដូចខាងក្រោម៖

- បន្តជំរុញដាក់ឈ្មោះឬលេខផ្លូវនិងលេខផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាលនិងប្រៃសណីយ៍
- កែលម្អនិងអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធរួមមានបណ្តាញផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី បណ្តាញប្រឡាយ និងការប្រមូលសំណល់រឹងនិងរាវឱ្យមានលក្ខណៈសមស្របនិងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភណភាពក្នុងខណ្ឌនិងរាជធានី
- កែលម្អនិងអភិវឌ្ឍផ្លូវសំខាន់ៗដូចជាមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនមានពិការភាព គន្លងផ្លូវទោចក្រយាន ចិញ្ចើមផ្លូវ ភ្លើងបំភ្លឺផ្លូវ ផ្លាកសញ្ញាចរាចរណ៍ ទីធ្លាកម្សាន្តនិងពាណិជ្ជកម្ម នៅក្នុងខណ្ឌស្របទៅតាមតំបន់ប្រើប្រាស់ដី សោភណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថានរស់នៅប្រកបដោយសុខភាពល្អសម្រាប់មនុស្សទាំងអស់គ្នា

- រៀបចំសួនសាធារណៈដោយកំណត់ប្រភេទនិងដាំដើមឈើ សួនច្បារតាមបណ្ដោយផ្លូវ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត និងការអភិវឌ្ឍផ្ទៃបៃតងស្ថិតនៅក្នុងខណ្ឌ
- គ្រប់គ្រងសំណង់ រៀបចំ និងកំណត់ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន សោភណភាពនិងពណ៌សមស្រប និងរបងដីឡូត៍ឱ្យមានសោភណភាពល្អស្របតាមទីតាំងភូមិសាស្ត្រ មជ្ឈមណ្ឌលវប្បធម៌ សន្តិសុខ សេដ្ឋកិច្ចនិងសង្គម
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្មតាមសង្កាត់នីមួយៗ
- គ្រប់គ្រង អភិវឌ្ឍ និងអភិរក្សបឹង ស្ទឹង ប្រឡាយ និងទីទួលបុរាណសម្រាប់សក្ការៈបូជា
- រៀបចំនិងកែលម្អតំបន់អប់រំនិងសិក្សាដូចជាសាកលវិទ្យាល័យ វិទ្យាស្ថាន វិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សា។

### ៤.១.២-ទិសដៅនគរូបនីយកម្ម

អភិវឌ្ឍនគរូបនីយកម្មជាតំបន់កំពុងអភិវឌ្ឍក្នុងរាជធានីភ្នំពេញសម្រាប់រដ្ឋបាល វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ប្រកបដោយគុណភាពបរិស្ថានរស់នៅល្អប្រសើរ ភាពសុខដុមរមនា ភាពឆ្លាត ចីរភាព និងបរិយាបន្ន ដោយៈ

- លើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍ និងការកែលម្អនគរូបនីយកម្មនិងការគ្រប់គ្រងការប្រើប្រាស់ដី ប្រកបដោយសោភណភាព ប្រសិទ្ធភាព និងតុល្យភាព
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាទីក្រុងសម្បូរបែបប្រកបដោយគុណភាព សណ្ដាប់ធ្នាប់សាធារណៈនិងធ្វើសមាហរណកម្មទៅក្នុងតំបន់ដើម្បីធានាគុណភាពនៃការរស់នៅល្អប្រសើរ
- កំណត់និន្នាការនៃការអភិវឌ្ឍខណ្ឌនិងនគរូបនីយកម្មមានលទ្ធភាពពង្រីកតាមវិធីសាស្ត្រនៃការអភិវឌ្ឍបែបលាតសន្ធឹងទៅទិសពាយ័ព្យ និងការអភិវឌ្ឍសំណង់ខ្ពស់ៗ
- គ្រប់គ្រងការអភិវឌ្ឍនិងការធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្មនិងការអភិវឌ្ឍរូបវន្តជាពិសេសបណ្ដាញផ្លូវ បណ្ដាញអគ្គិសនី បណ្ដាញទឹកស្អាត បណ្ដាញលូប្រឡាយ អាងស្តុកទឹក និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់
- ពង្រឹងសមត្ថភាពគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌព្រែកព្នៅដែលមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលខណ្ឌព្រែកព្នៅជាសេនាធិការ នៅក្នុងការគ្រប់គ្រងនិងអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្ម
- បន្តរៀបចំផែនការប្រើប្រាស់ដីនិងប្លង់លម្អិតនគរូបនីយកម្មដើម្បីធានាការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

### ៤.១.៣-ការអភិវឌ្ឍនគរូបនីយកម្មឆ្លាត មានចីរភាព និងប្រកបដោយបរិយាបន្ន

ដើម្បីលើកកម្ពស់ដល់គុណភាពរស់នៅប្រកបដោយភាពងាយស្រួលក្នុងការទំនាក់ទំនងនិងសន្សំសំចៃ ឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ននិងអនាគត ប្លង់គោលប្រើប្រាស់ដីខណ្ឌព្រែកព្នៅចក្ខុវិស័យឆ្នាំ២០៣៥ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍខណ្ឌឆ្លាតតាមរយៈការគិតគូរនិងបំពាក់នូវបរិក្ខារនិងសេវាកម្មសម្រាប់ខណ្ឌឆ្លាត ដូចខាងក្រោមៈ

**ក-វិស័យទូរគមនាគមន៍**

ក.១- សេវាអ៊ីនធឺណិតសាធារណៈ

- ផ្ដល់ការប្រើប្រាស់សេវាអ៊ីនធឺណិតសាធារណៈដល់សាធារណជនទូទៅនិងនៅកន្លែងសាធារណៈ ដូចជាស្ថាប័នរដ្ឋ សួនកម្សាន្ត តំបន់ទេសចរណ៍ តំបន់វប្បធម៌ និងមហាវិថីធំៗដែលផ្ដល់ដោយស្ថាប័នផ្គត់ផ្គង់សេវាទូរគមនាគមន៍ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល
- រៀបចំនិងផ្សព្វផ្សាយផែនទីបង្ហាញទីតាំងដែលមានសេវាអ៊ីនធឺណិតសាធារណៈ។

ក.២- មជ្ឈមណ្ឌលទិន្នន័យសាធារណៈ

- សិក្សានូវលទ្ធភាពក្នុងការកសាងមជ្ឈមណ្ឌលទិន្នន័យសម្រាប់ជំនួយគម្រោងខណ្ឌឆ្លាតដែលអាចគ្រប់គ្រងនិងប្រមូលទិន្នន័យបច្ចុប្បន្នភាពក្នុងខណ្ឌ
- ជាមជ្ឈមណ្ឌលសម្រាប់ដំណើរការប្រព័ន្ធទិន្នន័យរបស់រាជរដ្ឋាភិបាលនៅក្នុងតំបន់ដែលអាចជួយសម្រួលនិងដំណើរការនូវគេហទំព័រ សេវាកម្មដល់ប្រជាពលរដ្ឋ ការងាររដ្ឋបាល និងជាប្រភពទិន្នន័យសម្រាប់ប្រព័ន្ធការងាររដ្ឋបាលអន្តរជាតិផង
- ជាមជ្ឈមណ្ឌលដែលអាចវិភាគនិងដោះស្រាយបញ្ហារបស់ខណ្ឌបានទាន់ហេតុការណ៍ផង។

ក.៣- សេវាផ្ដល់សេចក្ដីជូនដំណឹងពីព័ត៌មានស្ដីពីសេវាសាធារណៈនៅក្នុងខណ្ឌដល់ប្រជាពលរដ្ឋ

- រៀបចំប្រព័ន្ធសេវាផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋឱ្យបានទៀងទាត់និងទាន់ហេតុការណ៍ដូចជាសន្តិសុខ ចរាចរណ៍ សុខាភិបាល រដ្ឋបាល បរិស្ថាន សេដ្ឋកិច្ច និងវប្បធម៌ជាដើម។

**ខ-វិស័យដឹកជញ្ជូន**

ខ.១- កសាងប្រព័ន្ធដឹកជញ្ជូនសាធារណៈឆ្លាត

- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍តាមបែបសមាហរណកម្ម
- ប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសន្សំសំចៃនិងមិនប៉ះពាល់ដល់បរិស្ថាន
- បង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ
- ប្រើប្រាស់គំនូសផ្លូវឆ្លាតដោយលាយសារធាតុបារ៉ែត២០% ជាមួយនឹងទឹកថ្នាំគំនូសផ្លូវដើម្បីមានចំណាំងផ្លាតនិងភ្លឺក្នុងពេលធ្វើចរាចរណ៍នៅពេលយប់
- បំពាក់អំពូលឆ្លាតនៅតាមដងផ្លូវដែលជាប្រភេទអំពូលមានការសន្សំសំចៃខ្ពស់និងគ្រប់គ្រងថាមពលដោយស្វ័យប្រវត្តិ
- បំពាក់កាមេរ៉ាសុវត្ថិភាពតាមដងផ្លូវក្នុងខណ្ឌដើម្បីត្រួតពិនិត្យចរាចរណ៍ជាទូទៅនៅតាមដងផ្លូវក៏ដូចជាទីសាធារណៈនានាដើម្បីធានាសុវត្ថិភាពជូនប្រជាជននិងបង្ក្រាបនូវរាល់សកម្មភាពអវិជ្ជមានដែលកើតមានឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព និងពន្លឿនការស្រាវជ្រាវរកមុខសញ្ញាចំពោះករណីណាមួយដែលកើតមានឡើង។

ខ.២- កសាងផ្លូវដឹកជញ្ជូនសាធារណៈនិងការផ្ដល់ព័ត៌មាននៃពេលវេលាមកដល់

- បង្កើតប្រព័ន្ធព័ត៌មានពេលវេលាដឹកជញ្ជូនសាធារណៈដល់អ្នកដំណើរ
- ផ្ដល់ការពិនិត្យព័ត៌មាននៃការធ្វើដំណើរមកដល់របស់រថយន្តសាធារណៈតាមទូរស័ព្ទដៃទំនើប។

ខ.៣- កសាងប្រព័ន្ធចតយានយន្តឆ្លាត

- កសាងសុវត្ថិភាពនិងបែងចែកចំណតសម្រាប់ចតយានយន្តផ្ទាល់ខ្លួន
- ផ្តល់ព័ត៌មានជាក់លាក់និងទាន់ពេលអំពីកន្លែងចតយានយន្ត។

**គ- ការប្រើប្រាស់ថាមពល**

- រៀបចំសន្សំសំចៃថាមពលដោយផ្តួចផ្តើមការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតាមការិយាល័យ និងស្ថាប័នរដ្ឋ
- តាមស្ថានភាពខណ្ឌអាចធ្វើការផ្គត់ផ្គង់ថាមពលកកើតឡើងវិញដោយប្រើប្រាស់ពន្លឺព្រះអាទិត្យ
- លើកទឹកចិត្តនិងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញដោយប្រើប្រាស់ពន្លឺព្រះអាទិត្យតាមរយៈការបំពាក់ឧបករណ៍បង្កើតថាមពលពន្លឺព្រះអាទិត្យនៅលើដំបូលអគារស្នាក់នៅ អគាររដ្ឋបាល និងកន្លែងចតយានយន្តជាដើម។

**ឃ- ការគ្រប់គ្រងធនធានទឹក**

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងនិងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនិងសន្សំសំចៃ
- រៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ទឹកដែលមានប្រភពមកពីទឹកភ្លៀងតាមរយៈការបង្កើនប្រសិទ្ធភាពអាងស្តុកទឹកភ្លៀងនិងការគ្រប់គ្រងទីជម្រាល។

**ង- ការបង្ការគ្រោះមហន្តរាយ**

- រៀបចំប្រព័ន្ធឆ្លាតនិងផ្លូវសុវត្ថិភាពក្នុងការជម្លៀសចេញពីគ្រោះមហន្តរាយ
- រៀបចំប្រព័ន្ធផ្លូវចេញចូលសម្រាប់រថយន្តពន្លត់អគ្គិភ័យនិងរថយន្តសង្គ្រោះនៅក្នុងតំបន់លំនៅឋាន និងតំបន់ពាណិជ្ជកម្ម
- រៀបចំប្រព័ន្ធតាមដាននិងផ្តល់ព័ត៌មានអំពីគ្រោះមហន្តរាយឱ្យបានទាន់ពេលវេលាដើម្បីជូនដំណឹងដល់សាធារណជននៅពេលមានគ្រោះអាសន្ននានាកើតឡើងតាមរយៈទូរស័ព្ទដៃទំនើបឬតាមបណ្តាញសង្គមនានាឱ្យបានឆាប់រហ័សក្នុងការធានាសុវត្ថិភាពជូនប្រជាជននិងថែរក្សាទ្រព្យសម្បត្តិ។

**ច- ការគ្រប់គ្រងបរិស្ថាន**

- អភិវឌ្ឍប្រព័ន្ធឆ្លាតសម្រាប់គ្រប់គ្រងនិងប្រព្រឹត្តិកម្មទឹកកខ្វក់និងសំណល់រាវ
- អភិវឌ្ឍប្រព័ន្ធឆ្លាតសម្រាប់គ្រប់គ្រងសំណល់រឹង
- រៀបចំដំណើរការមជ្ឈមណ្ឌលគ្រប់គ្រងខណ្ឌតាមបែបសមាហរណកម្ម។

### ៤.២- យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី

អនុលោមតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥ ខណ្ឌព្រែកព្នៅត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់។

## ៤.២.១- ប្រភេទដីអាចសាងសង់បាន

ខណ្ឌព្រែកព្នៅមានផ្ទៃដីសរុបប្រមាណ១១ ៥៦០,៩០ហិកតា ក្នុងនោះប្រភេទដីអាចសាងសង់បានមានផ្ទៃដីប្រមាណ៨ ០៦៧,៥៨ហិកតាស្មើនឹង៦៩,៧៨%នៃផ្ទៃដីសរុប។ ប្រភេទដីអាចសាងសង់បាន ត្រូវបានរៀបចំនិងបែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធ ដូចខាងក្រោម៖

១) តំបន់លំនៅឋានមានផ្ទៃដីប្រមាណ៣ ៣១២,០៩ហិកតាស្មើនឹង៤១,០៥%នៃផ្ទៃដីអាចសាងសង់បាន។ តំបន់លំនៅឋានត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប (ត្រឹមជាន់ទី២) ស្ថិតនៅក្នុងសង្កាត់គោករកា និងសង្កាត់ព្រែកព្នៅដូចជាបុរីពិភពថ្មីឈូកវ៉ា១ កម្ពុបុរី បុរីសុខគុង បុរីសុខសាលី និងមួយផ្នែកទៀតស្ថិតនៅក្នុងសង្កាត់ពន្សាំងផ្នែកខាងជើងជាប់ផ្លូវវត្តភ្លៀតសិម្ពលីមានផ្ទៃដីប្រមាណ១ ៤៦៨,០០ហិកតាស្មើនឹង១៨,២០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាប (ត្រឹមជាន់ទី២) ស្ថិតនៅតំបន់លំនៅឋានជុំវិញផ្សារព្រែកព្នៅមានផ្ទៃដីប្រមាណ៣៧៨,៥៩ហិកតាស្មើនឹង៤,៦៩%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ប្រភេទទី១ (ត្រឹមជាន់ទី១៨) ស្ថិតនៅក្នុងសង្កាត់ទាំងប្រាំនៃខណ្ឌព្រែកព្នៅមានផ្ទៃដីប្រមាណ១០០,៧៤ហិកតាស្មើនឹង១,២៥%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ប្រភេទទី២ (ពីជាន់ទី១៩ឡើងទៅ) ស្ថិតនៅក្នុងសង្កាត់ទាំងប្រាំនៃខណ្ឌព្រែកព្នៅមានផ្ទៃដីប្រមាណ២២៤,៩១ហិកតាស្មើនឹង២,៧៩%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់លំនៅឋានចម្រុះស្ថិតនៅក្នុងសង្កាត់ទាំងប្រាំនៃខណ្ឌព្រែកព្នៅ តាមដងផ្លូវមេសំខាន់ៗ និងនៅតំបន់ទីប្រជុំជន មានផ្ទៃដីប្រមាណ១ ១៣៩,៨៦ហិកតាស្មើនឹង១៤,១៣%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥%។

២) តំបន់ឧស្សាហកម្មមានផ្ទៃដីប្រមាណ១ ០២៦,១៣ហិកតាស្មើនឹង១២,៧២%នៃផ្ទៃដីអាចសាងសង់បាន។ តំបន់ឧស្សាហកម្មត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់ឧស្សាហកម្មស្រាលស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់គោករកា និងសង្កាត់ពន្សាំងមានផ្ទៃដីប្រមាណ១,៥៣ហិកតាស្មើនឹង០,០២%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់ឧស្សាហកម្មចម្រុះស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់សំរោងក្រោម និងដីលិច មានផ្ទៃដីប្រមាណ១ ០២៤,៦១ហិកតាស្មើនឹង១២,៧០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៣) តំបន់ចម្រុះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ផ្នែកខាងលិចមានផ្ទៃដីប្រមាណ៩៤២,៣៥ហិកតា ស្មើនឹង១១,៦៨%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១០,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧០%។

៤) តំបន់ទេសចរណ៍ស្ថិតនៅជុំវិញបឹងតាមោក និងតាមបណ្តោយផ្លូវជាតិលេខ៥ស្របតាមទន្លេបាសាក់ ជុំវិញបឹងសំរោង ភ្នំរាប ភ្នំប្រសិទ្ធិមានផ្ទៃដីប្រមាណ៧០,៣៦ហិកតាស្មើនឹង០,៨៧%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

៥) តំបន់ដឹកជញ្ជូនមានបណ្តាញផ្លូវ ចំណតរថយន្តក្រុង និងកំពង់ផែមានផ្ទៃដីប្រមាណ២ ១៥៥,៧២ ហិកតាស្មើនឹង២៦,៧២%នៃផ្ទៃដីអាចសាងសង់បានក្នុងនោះដីចំណីផ្លូវសាធារណៈមានផ្ទៃដីប្រមាណ ២ ១៣៨,៣៩ហិកតាស្មើនឹង២៦,៥១% ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៦) តំបន់រដ្ឋបាលនិងសេវាសាធារណៈមានគ្រឹះស្ថានសិក្សាធិការ អប់រំ កីឡា សុខភាព សាលប្រជុំ/ពិធីការិយាល័យ និងរដ្ឋបាលសាធារណៈ មានផ្ទៃដីប្រមាណ៤០,១៧ហិកតាស្មើនឹង០,៥០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៧) តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងមានទីតាំងនៅច្រាំងដីចំណីទន្លេ ដីចំណីបឹងសំរោង និងដីចំណីបឹងតាមោកមានផ្ទៃដីប្រមាណ៤៤៨,០២ហិកតាស្មើនឹង៥,៥៥%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា ១០%។ ជំរុញរៀបចំនិងអភិវឌ្ឍសួនសាធារណៈនិងសួនក្នុងតំបន់លំនៅឋានបន្ថែមឱ្យបានយ៉ាងតិច ១០%នៃផ្ទៃដីអាចសាងសង់បាននៅឆ្នាំ២០៣៥។

៨) តំបន់វប្បធម៌និងសាសនាស្ថិតនៅបរិវេណវត្តនិងទីទួលបុរាណដូចជាវត្តចន្ទមុនីវង្ស វត្តអង្គសិរីសួស្តី វត្តប្រាសាទ វត្តបឹងប្រិយ៍ វត្តជុំ វត្តឈូកវ៉ា ត្រពាំងស្វាយធំ ទួលអ្នកតាព្រីងភ្លែក ទួលត្រពាំងសេះ ទួលអង្គ ទួលកន្ទោង១០០ ទួលតាស្គរ និងទួលកំណប់ មានផ្ទៃដីប្រមាណ៧២,៧២ហិកតាស្មើនឹង០,៩០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ដាំដើមឈើ ផ្លូវតម្រង់ ផ្លាតម្លាត កម្ពស់សំណង់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ពណ៌អគារ សោភណភាព និងរចនាបថស្ថាបត្យកម្មខ្មែរនិង/ឬលក្ខណៈធម្មជាតិនៃតំបន់នីមួយៗដូចបានកំណត់ខាងលើ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

## ៤.២.២- ប្រភេទដីកម្រិតការសាងសង់

ប្រភេទដីកម្រិតការសាងសង់ មានផ្ទៃដីប្រមាណ៣ ៤៩៣,៣២ហិកតាស្មើនឹង៣០,២២%នៃផ្ទៃដីសរុប។ ប្រភេទដីកម្រិតការសាងសង់ ត្រូវបានរៀបចំនិងបែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធ ដូចខាងក្រោម៖

១) តំបន់កសិកម្មៈ ស្ថិតនៅសង្កាត់ពន្លឺងផ្នែកខាងជើងជាប់ភូមិបឹង ខាងត្បូងជាប់ភូមិចុងថ្នល់ ខាងលិចជាប់ផ្លូវលេខ៤២ ខាងកើតជាប់បឹងតាមោកមានផ្ទៃដីប្រមាណ៩៨៩,៩១ហិកតាស្មើនឹង២៨,៣៤% នៃផ្ទៃដីកម្រិតការសាងសង់។

២) តំបន់ធនធានទឹកៈ មានតំបន់ទន្លេសាប តំបន់បឹងតាមោក តំបន់បឹងសំរោង តំបន់ព្រែកព្នៅ តំបន់ព្រែកអូរពីមពិស តំបន់អូរផ្សេងៗមានផ្ទៃដីប្រមាណ២ ៣៤៦,៥៩ហិកតាស្មើនឹង៦៧,១៧%នៃផ្ទៃដីកម្រិតការសាងសង់។

៣) តំបន់ការពារៈ មានតំបន់ច្រាំងទន្លេសាបដែលត្រូវរក្សា៥០ម៉ែត្រ បឹងតាមោក បឹងសំរោងមានផ្ទៃដីប្រមាណ១៥៦,៨២ហិកតាស្មើនឹង៤,៤៩%នៃផ្ទៃដីកម្រិតការសាងសង់។

## ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រឹងនិងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើវិស័យវប្បធម៌ សាសនា សេដ្ឋកិច្ចសង្គម ទេសចរណ៍ ពាណិជ្ជកម្ម និងបរិស្ថានក្នុងខណ្ឌព្រែកព្នៅរួមមានៈ

### ៤.៣.១-ផ្លូវថ្នល់

- បន្តការពារនិងជួសជុលផ្លូវមេនិងផ្លូវសំខាន់ៗទៀតក្នុងមូលដ្ឋាន
- បន្តការកសាងផ្លូវតាមបណ្តោយច្រាំងទន្លេក្នុងភូមិ ផ្លូវសង្កាត់ដើម្បីចូលរួមអភិវឌ្ឍវិស័យទេសចរណ៍ សុខុមាលភាព និងសោភណភាពរាជធានីភ្នំពេញ
- បន្តរៀបចំផ្លូវឱ្យល្អប្រណីត អមដោយដើមផ្កាអមសងខាងផ្លូវនិងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនមានពិការភាព គន្លងផ្លូវទោចក្រយាន បរិក្ខារផ្លូវថ្នល់ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង បង្គោលភ្លើងបំភ្លឺផ្លូវ និងភ្លើងលម្អប្រកបដោយក្បូរក្បាច់រចនាបថខ្មែរនិងធម្មជាតិ និងសក្តានុពលទាក់ទាញភ្ញៀវទេសចរនិងអ្នកដំណើរឆ្លងកាត់
- សិក្សាការបើកផ្លូវ ផ្លូវត្រឡប់ក្រោយ ច្រកផ្លូវ និងពង្រីកទ្រូងផ្លូវបន្ថែមដើម្បីបង្កភាពងាយស្រួលដល់ចរាចរណ៍សាធារណៈ
- រៀបចំគន្លងផ្លូវរថយន្តសាធារណៈនៅតាមផ្លូវសំខាន់ៗនិងតំបន់ទីប្រជុំជនដើម្បីសម្រួលដល់ការធ្វើចរាចរណ៍នៃរថយន្តសាធារណៈក៏ដូចជាលើកទឹកចិត្តដល់ប្រជាជនប្រើប្រាស់សេវារថយន្តសាធារណៈ
- ជំរុញអនុវត្តសេចក្តីសម្រេចលេខ០៣៩ សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនមានពិការភាពដើម្បីធានាសោភណភាពសាធារណៈនិងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាពនិងភាពងាយស្រួលដល់សាធារណជននិងជនមានពិការភាព
- រៀបចំកំណត់កម្ពស់ផ្លូវនិងចិញ្ចើមផ្លូវដោយមានកម្ពស់០,២ម៉ែត្រធៀបជាមួយនឹងកម្រិតកម្ពស់ទ្រូងផ្លូវ មានមុំជម្រាល០,១% និងមានបទដ្ឋានបច្ចេកទេសតែមួយដើម្បីមានភាពងាយស្រួលសម្រាប់អ្នកថ្មើរជើងនិងធានាបាននូវសុវត្ថិភាព។

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.–**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ(១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣)ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

-សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៤០.–**

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

**មាត្រា ៤១.–**

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

**មាត្រា ៤២.–**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

ស្ត្រី និងកុមារ និងអនុសាសន៍ ដើម្បីពង្រឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១៣៥._**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញប្រកាសណែនាំអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារតាមការចាំបាច់ ដោយផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ផ្នែកទី ៤
## គណៈកម្មាធិការលទ្ធកម្ម

**មាត្រា ១៣៦._**

គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពកិច្ចលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហ តម្លាភាព មិនលំអៀង ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ១៣៧._**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៥
## គណៈអភិបាល

**មាត្រា ១៣៨._**

ត្រូវរៀបចំឱ្យមានគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ និង/ឬមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៣.–**

អភិបាលរងរាជធានី អភិបាលរងខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរប្រភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃដែលមានលក្ខណ-សម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិ ចាប់ពីវរមន្ត្រីឡើងទៅ

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៤.–**

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរប្រភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង

-មានអាយុ ចាប់ពីសាមសិប(៣០)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៥.–**

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម ៖

-មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង

-មានអាយុចាប់ពីម្ភៃប្រាំ(២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនបី(០៣)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៦.-**

ក្នុងករណីចាំបាច់ អភិបាល អភិបាលរង អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅពីក្របខ័ណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវមានលក្ខណសម្បត្តិ សមស្របតាមមាត្រា ១៤២ មាត្រា ១៤៣ មាត្រា ១៤៤ និងមាត្រា ១៤៥ នៃច្បាប់នេះ ។

**មាត្រា ១៤៧.-**

អភិបាល អភិបាលរង មានអាណត្តិការងារមិនលើសពីបួន(០៤)ឆ្នាំ ។

អភិបាល អភិបាលរងអាចត្រូវបានតែងតាំងបានបួន(០៤)ឆ្នាំទៀត សម្រាប់អាណត្តិទី ២ របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល ។

**មាត្រា ១៤៨.-**

អភិបាល អភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ ។

**មាត្រា ១៤៩.-**

អភិបាល អភិបាលរងអាចចូលរួមគ្រប់អង្គប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គ-ប្រជុំរបស់ក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោតបានឡើយ ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨

នស/រកម.០៥០៨.០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៤ / ២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩៩៩ ។

# សំរេច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

មាត្រា ១ អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

មាត្រា ២ អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

មាត្រា ៣ និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក- " **តំបន់ទឹកសាធារណៈ** " : គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្រ្ត និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ- " **ប្រភពបំពុល** " : គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូននិងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ។

គ- " **សំណល់រាវ** " : គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ- " **ទឹកល្អ** " : គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង- " **សំណល់រឹង** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច- " **សំរាម** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ- "**សារធាតុបំពុល**" : គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទ ដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជាៈ ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹក ដោយចេតនាក្តី ឬអចេតនាក្តី ។

ជ- "**បរិមាណសារធាតុបំពុល**": គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅ ដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ- "**សារធាតុប្រកបដោយគ្រោះថ្នាក់**" : គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមាន គ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬចាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយ ប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុង តារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់ និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤** កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាង ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥** ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់និមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្ស ជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦** ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយ ដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

មាត្រា ៧ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

កំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៧ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៨ ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

មាត្រា ៩ ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកល្អូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣
## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

មាត្រា ១០ ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

មាត្រា ១១ ប្រភេទនៃប្រភពបំពុល ដែលតំរូវឱ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹតនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក- ប្រភពបំពុលប្រភេទថ្នាក់ទី ១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ- ប្រភពបំពុលប្រភេទថ្នាក់ទី ២ ចាំបាច់តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

មាត្រា ៣៧ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៨ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣៩ អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*__កន្លែងទទួល__*
- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣៨*
- *កាលប្បវត្តិ-ឯកសារ*

*បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី*
*ដើម្បីចុះហត្ថលេខា*

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

# អនុក្រឹត្យ លេខ ៣៦ អនក្រ.បក
# ស្តីពីការគ្រប់គ្រងសំណល់រឹង

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៨ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-** អនុក្រឹត្យនេះ មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេស សមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវចំរុះ ។

**មាត្រា ២ .-** អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣ .-** និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក- “**សំណល់រឹង** “ គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទី ដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវអោយបោះបង់ចោល ។

ខ- “**សំរាម** “ គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅដ្ឋាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ ល ។

ឍ- "សំណល់ប្រកបដោយគ្រោះថ្នាក់ " គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬ សារធាតុគីមីដទៃទៀត ដែលអាចនាំអោយមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និង សេវាកម្មអាជីវកម្មរ៉ែ ។ ល ។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## ការគ្រប់គ្រងសំរាម

មាត្រា ៤ .- ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពីគោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាម ប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

មាត្រា ៥ .- ការអនុវត្តន៏ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៏វាក្យខ័ណ្ឌទី១ នៃមាត្រា ៥ នេះ ត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៦ .- ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៏ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

មាត្រា ៧ .- ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរ មានសមត្ថកិច្ច ។

មាត្រា ៨ .- ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន ។

មាត្រា ៩ .- ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលុះត្រាតែណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

មាត្រា ១០ .-ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

មាត្រា ៣០ .–បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣១ .–រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣២ .–អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានយកសេចក្ដីជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ហត្ថលេខា

ម៉ុក ម៉ារ៉េត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖** ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១ ៖ ប្លង់គោលប្រើប្រាស់ដី ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ ២០៣៥



## ឧបសម្ព័ន្ធទី២ ៖ ទិដ្ឋភាពទូទៅក្នុងខណ្ឌព្រែកព្នៅ





រូបភាពទី១ ៖ សាលាខណ្ឌព្រែកព្នៅ

រូបភាពទី២ ៖ ប្រាសាទភ្នំបាសិទ្ធិ





រូបភាពទី៣ ៖ មហាវិថីសំរោង

រូបភាពទី៣ ៖ មហាវិថីឈ្នះឈ្នះ





រូប

ភាពទី៤ ៖ ទិដ្ឋភាពតាមដងមហាវិថី

រូបភាពទី៥ ៖ មន្ទីរពេទ្យជាតិ តេជោសន្តិភាព

# ឧបសម្ព័ន្ធទី៣ ៖ ការបំពុលទឹក










## ឧបសម្ព័ន្ធទី៤ ៖ ការបំពុលខ្យល់





## ប្រភពនៃការបំពុលខ្យល់





# ឧបសម្ព័ន្ធទី៥ ៖ ការបំពុលសំឡេង





## ប្រភពនៃការបំពុលសំឡេង






## ឧបសម្ព័ន្ធទី៦ ៖ ការបំពុលដី





## ប្រភពនៃការបំពុលដី





## ឧបសម្ព័ន្ធទី៧ ៖ ការបំពុលសំណល់រឹង រាវ





ប្រភពនៃការបំពុលសំណល់ រឹង





ប្រភពនៃការបំពុលសំណល់ រាវ

## ឧបសម្ព័ន្ធទី៨ ៖ សកម្មភាពត្រួតពិនិត្យសណ្ដាប់ធ្នាប់សាធារណៈ







